# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Èconomiques

Royal university of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវក្នុងវិស័យសំណង់

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| --- | --- |
| និស្សិតឈ្មោះ **មឿង វីរៈសក្តិ** | **បណ្ឌិត អ៊ុន សកក្ដា** |
| **ក. វី សុគន្ធនិតា** | |


| | | |
| --- | --- | --- |
| ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ | ឆ្នាំចូលរៀន | ២០១៧ |
| ជំនាន់ទី ២១ | ឆ្នាំសរសេរសារណា | ២០២១ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Èconomiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវក្នុងវិស័យសំណង់

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **មឿង វីរៈសក្តិ**

**ក. រី សុគន្ធនិតា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **មឿង វីរៈសក្តិ** និងនាងខ្ញុំឈ្មោះ **រី សុគន្ធនិតា** ជានិស្សិតផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២១។

យើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកឪពុក និងអ្នកម្ដាយ** ដែលជាអ្នកមានគុណដ៏ឧត្តុង្គឧត្តម ដោយលោកបានផ្ដល់កំណើត ព្រមទាំងប្រឹងប្រែងគ្រប់បែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាការពារ អប់រំទូន្មាន ប្រៀនប្រដៅកូន ប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌។ លោកអ្នកមានគុណ បានខិតខំរកថវិកាក្នុងការឧបត្ថម្ភកូនដើម្បីឲ្យកូនទទួលបាននូវចំណេះដឹង និងពុះពារប្រឈមមុខរាល់ទុក្ខលំបាកគ្រប់បែបយ៉ាង ក៏ដូចជាផ្ដល់នូវកម្លាំងចិត្ត រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ជាបន្ទាប់ យើងខ្ញុំទាំងពីរសូមសម្ដែងនូវការគោរពដល់ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្ស**ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមរៀបចំឱ្យសាកលវិទ្យាល័យ មានដំណើរការប្រកបដោយភាពជោគជ័យ ក៏ដូចជាខិតខំសម្រួលការសិក្សារបស់និស្សិត ដោយយកចិត្តទុកដាក់ក្នុងការបង្រៀន ដោយមិនខ្លាចនឿយហត់ និងជួយជំរុញផ្នែកស្មារតីដល់យើងខ្ញុំឲ្យខិតខំរៀនសូត្រ និងក្រេបជញ្ជក់យកចំណេះដឹងឲ្យបានច្រើន។

យើងខ្ញុំទាំងពីរ សូមធ្វើការគោរពយ៉ាងធំធេងបំផុត ជូនចំពោះលោកសាស្ត្រាចារ្យណែនាំ **បណ្ឌិត អ៊ុន សកក្កដា** ដែលលោកសាស្ត្រាចារ្យបានខិតខំអស់ពីកម្លាំងកាយចិត្ត ទាំងប្រាជ្ញា និងស្មារតី និងពេលវេលាដ៏មានតម្លៃក្នុងការជម្រុញណែនាំ លើកទឹកចិត្ត និងបានត្រួតពិនិត្យ កែលំអរជាច្រើនលើក ច្រើនសារដល់រូបយើងខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវ ចងក្រង សរសេរអត្ថបទសារណានេះឡើងរហូតដល់បានបញ្ចប់ស្ពាព។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរ សូមបួងសួងដល់វត្ថុសាកសិទ្ធិទាំងឡាយ សូមមេត្តាបីបាច់ថែរក្សា **អ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ**ទាំងអស់សូមឲ្យជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើន និងពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីទទួលបាននូវការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ៤ឆ្នាំកន្លងមក យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនអំពីមុខវិជ្ជានានានៅក្នុងផ្នែកនីតិសាស្ត្រ។ តាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ ហើយក៏បានសម្រេចចិត្តជ្រើសរើសយកប្រធានបទ ការទទួលខុសត្រូវក្នុងវិស័យសំណង់ ដើម្បីធ្វើជាសារណាបញ្ចប់ឆ្នាំសិក្សារបស់យើងខ្ញុំទាំងពីរនាក់ និងដើម្បីទុកជាស្នាដៃសម្រាប់តម្កល់ទុកជាឯកសារ សម្រាប់ជំនួយដល់និស្សិតជំនាន់ក្រោយ ដែលចង់សិក្សាស្រាវជ្រាវអំពីប្រធានបទមួយនេះសម្រាប់ការយល់ដឹងទៅអនាគត។

ជាការពិតណាស់ ឯកសារនេះ គឺជាស្នាដៃរបស់យើងខ្ញុំទាំងពីរដែលបានខិតខំព្យាយាមនូវក្នុងការសិក្សាស្រាវជ្រាវ ក្នុងការធ្វើអោយលេចចេញជារូបរាងឡើងមក ក៏ដូចជាដោយសារការខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្រៀនណែនាំរបស់លោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សភក្តជា** ផងដែរ។

យ៉ាងណាមិញ ស្នាដៃមួយនេះ មិនអាចមានភាពល្អឥតខ្ចោះបានទាំងស្រុងនោះទេ។ ប៉ុន្តែយើងខ្ញុំទាំងពីរសង្ឃឹមថា សារណាមួយនេះអាចផ្តល់នូវឯកសារដ៏មានតម្លៃ និងការសម្រួលទៅដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ។ ដូច្នេះ ចំពោះចំណុចខ្វះខាតដែលយើងខ្ញុំមិនបានបំពេញអោយគ្រប់ជ្រុងជ្រោយ យើងខ្ញុំទាំងពីរនាក់ នឹងទទួលនូវរាល់កំហុសឆ្គងទាំងឡាយពីសំណាក់ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយជាទីគោរព។

សារណាបញ្ចប់ការសិក្សាមួយនេះ គឺជាសមិទ្ធិផលមួយ ដែលក្រុមយើងខ្ញុំបានខិតខំស្វះស្វែងស្រាវជ្រាវ និងបានធ្វើការវិភាគទៅលើដំណើរការនីមួយៗ ប្រកបដោយការយកចិត្តទុកដាក់បំផុត។ ប៉ុន្តែបើទោះបីជាមានការខិតខំស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏កិច្ចការស្រាវជ្រាវនីមួយៗ រមែងតែងតែជួបប្រទះនូវភាពខ្វះចន្លោះ និងមិនទាន់មានន័យគ្រប់ជ្រុងជ្រោយមួយរយភាគរយនៅឡើយនោះទេ។ ហេតុដូចនេះហើយ យើងខ្ញុំទាំងពីរសង្ឃឹមថា អ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់ធ្វើការអភ័យទោសដល់ក្រុមយើងខ្ញុំ ចំពោះកំហុសដោយអចេតនានៅក្នុងប្រការណាមួយ ហើយក្រុមយើងខ្ញុំក៏សូមធ្វើការស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់អ្នកមាន និងអ្នកស្រាវជ្រាវ ដើម្បីជាជំនួយឱ្យក្រុមយើងខ្ញុំមានការអភិវឌ្ឍខ្លួនកាន់តែប្រសើរ និងមានភាពរីកចម្រើនជាងមុន។

# មាតិកា


**សេចក្ដីផ្ដើម** ........ 1

**ជំពូកទី ១**

**សញ្ញាណទូទៅនៃវិស័យសំណង់**

**១.១. ទិដ្ឋភាពទូទៅនៃវិស័យសំណង់** ........ 6

១.១.១. បរិបទនៃវិស័យសំណង់ ........ 6

១.១.១.១. និយមន័យ ........ 6

១.១.១.២. ការវិវត្តនៃសំណង់នៅកម្ពុជាចាប់ពីឆ្នាំ២០១៩-បច្ចុប្បន្ន ........ 7

១.១.២. នីតិវិធីនៃការរៀបចំក្នុងវិស័យសំណង់ ........ 10

១.១.២.១. នីតិវិធីនៃការស្នើសុំ ........ 10

១.១.២.២. នីតិវិធីនៃការត្រួតពិនិត្យ ........ 12

**១.២. មូលហេតុដែលនាំឱ្យមានការទទួលខុសត្រូវក្នុងវិស័យសំណង់** ........ 12

១.២.១. ការមិនគោរពបញ្ញត្តិបច្ចេកទេសនៃសំណង់ ........ 13

១.២.១.១. សុវត្ថិភាពគ្រឿងផ្គុំ ........ 13

១.២.១.២. សុវត្ថិភាពអគ្គីភ័យ ........ 13

១.២.១.៣. ការដាក់ឱ្យប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ........ 15

១.២.១.៤. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ........ 15

**១.៣. យន្តការនៃការដោះស្រាយវិវាទ** ........ 16

១.៣.១. យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ 16

១.៣.១.១.ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ ........ 17

១.៣.១.២. ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យាម៉ៅការសាងសង ឬរុះរើ ........ 17

១.៣.២. យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ........ 18

១.៣.២.១. ការប្ដឹងតវ៉ាក្នុងវិស័យសំណង់ ........ 18

## ជំពូកទី ២
## ការទទួលខុសត្រូវក្នុងវិស័យសំណង់


**២.១. ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់** ........ 22
២.១.១. អ្នកសិក្សាគម្រោងប្លង់ ........ 22
២.១.២. ម្ចាស់សំណង់ និងអ្នកសាងសង់ ឬរ៉ុយេ ........ 22
២.១.៣. អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ........ 23
២.១.៤. ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួល ........ 23
២.១.៥. ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ........ 23
**២.២. ការទទួលខុសត្រូវក្នុងវិស័យសំណង់** ........ 24
២.២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌ ........ 25
២.២.២. ការទទួលខុសត្រូវរដ្ឋប្បវេណី ........ 29
**២.៣. ការរួចផុតពីការទទួលខុសត្រូវក្នុងវិស័យសំណង់** ........ 29
២.៣.១. ករណីប្រធានសក្តិ និងព្រឹត្តការណ៍រាជសក្តិ ........ 30
២.៣.២. កំហុសរបស់ជនរងគ្រោះ ........ 30
២.៣.៣. កំហុសរបស់តតិយជន ........ 30
**សេចក្តីសន្និដ្ឋាន** ........ 32
**អនុសាសន៍** ........ 34
**ឯកសារយោង** ........ 36
**ឧបសម្ព័ន្ធ** ........ 39

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

គិតចាប់តាំងពីដើម ស.វទី ២១ មកប្រទេសកម្ពុជាហាក់មានសន្ទុះយ៉ាងសន្ធោសន្ធៅក្នុងភាពរីកចម្រើនក្នុងគ្រប់វិស័យ មិនថាក្នុងវិស័យកសិកម្ម ឧស្សាហកម្ម អប់រំ ទេសចរណ៍ ពាណិជ្ជកម្ម និងសំណង់នោះទេ។ យើងសង្កេតឃើញថាវិស័យទាំងអស់នេះសុទ្ធតែមានសារៈសំខាន់ ដែលជាចំណែកនូវក្នុងការអភិវឌ្ឍប្រទេសដូចៗគ្នា ដែលក្នុងនោះវិស័យសំណង់ជាផ្នែកមួយ ដែលទទួលបានការចូលរួមយ៉ាងសម្បើម មិនថានៅក្នុងរាជធានីភ្នំពេញ ឬ តាមបណ្តាខេត្តឡើយ ដើម្បីជួយពន្លឿនភាពរីកចម្រើនជាតិអោយកាន់មានភាពស៊ីវិល័យទៅតាមសម័យកាលទំនើបនាពេលបច្ចុប្បន្ននេះ។ គួរកត់សម្គាល់ថា នាប៉ុន្មានឆ្នាំចុងក្រោយនេះរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ យើងអាចសង្កេតឃើញថាវត្តមាននៃអគារខ្ពស់ៗបានបង្ហាញចេញឡើង និងបង្អួតរាងគ្នាគួរជាទីចាប់អារម្មណ៍។ ដោយយោងទៅតាមទិន្នន័យរបាយការណ៍របស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានឱ្យដឹងថា ទិន្នន័យសំណង់នៅទូទាំងប្រទេសមានចំនួន ៤៥៨ គម្រោង ហើយមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ១.៧៥៥.៩០៧ម$^២$ និងតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ៨៨៨.០៣៤.១១៩ដុល្លារអាមេរិច បើធៀបទៅនឹងខែមករា ឆ្នាំ២០២០ ចំនួន ២០៥ គម្រោង ផ្ទៃក្រឡាកម្រាលសំណង់ចំនួន ១.៨៧៤.២៦៧ម$^២$ ក៏ដូចជាតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ៨៦៩.១១០.៣១០ដុល្លារអាមេរិច ហើយកើនឡើង ២.១៨% បើធៀបទៅនឹងខែធ្នូ ឆ្នាំ ២០២០ មានចំនួន ៥១៣ គម្រោង ផ្ទៃក្រឡាកម្រាលសំណង់ចំនួន ១.៦០២.១៧៨ម$^២$ ថែមទាំងតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ៧៥២.៨០១.៦៦៤ដុល្លារ កើនឡើង ១៧.៩៧% ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្របពេលគ្នាជាមួយនឹងអត្រាកំណើនដ៏ល្អប្រសើរនេះផងដែរ បណ្តាលិខិតបទដ្ឋានគតិយុត្តិ ដែលមានទាក់ទិនទៅនឹងការគ្រប់គ្រងសំណង់ត្រូវបានយកចិត្តទុកដាក់ ធ្វើវិសោធនកម្ម និងតាក់តែងបន្ថែមដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍវិស័យសំណង់នៅកម្ពុជា។ របបគតិយុត្តិ គឺជាវិធានដែលបង្កើតឡើងក្នុងគោលដៅដើម្បីគ្រប់គ្រងសម្របសម្រួល ក៏ដូចជាធានានូវភាពត្រឹមត្រូវ និងស្របច្បាប់នៃការសាងសង់សំណង់អគារ ព្រមជាមួយនឹងការទទួលខុសត្រូវនៃអ្នកសាងសង់ និងអ្នកប្រើប្រាស់ដូចគ្នាដែរ។ បើយើងនិយាយត្រង់ចំណុចនេះប្រាកដជាយើងនឹងមានចម្ងល់មួយថា ស្របពេលជាមួយកំណើនជាលំដាប់នេះ តើការវិវត្តនៃរបៀបរបបក្នុងវិស័យសំណង់ដំណើរការតាមលក្ខណៈបច្ចេកទេសណាខ្លះ? តើការទទួលខុសត្រូវក្នុងវិស័យសំណង់ប្រព្រឹត្តិទៅយ៉ាងដូចម្តេច? ហើយមានបុគ្គលណាខ្លះដែលត្រូវមានកាតព្វកិច្ចក្នុងទំនួលខុសត្រូវ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គួរកត់សម្គាល់ថា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ បុគ្គលម្នាក់ៗមានសេរីភាពក្នុងការធ្វើសកម្មភាព ប៉ុន្តែសេរីភាពទាំងនោះក៏ត្រូវស្ថិតនៅក្នុងដែនកំណត់ណាមួយដែរ ពោលគឺមិនអាចបំពានសេរីភាពរបស់អ្នកដទៃ ហើយប្រសិនបើមានការបំពាន ការទទួលខុសត្រូវនៅចំពោះមុខច្បាប់នឹងកើតមានឡើង។ មិនខុសគ្នាពីវិស័យសំណង់ឡើយ អ្នកដែលចូលរួមក្នុងការសាងសង់ទាំងអស់ ក៏ដូចជាបុគ្គលដែលពាក់ព័ន្ធនឹងវិស័យសំណង់ មានសិទ្ធិក្នុងការសាងសង់សំណង់តាមតម្រូវការរបស់ខ្លួន ប៉ុន្តែត្រូវគោរពទៅតាមបទដ្ឋានដែលច្បាប់បានកំណត់ ពោលគឺ ត្រូវគោរពតាមអ្វីដែលមានចែងក្នុងច្បាប់ ស្តីពី សំណង់ ជាអប្បបរមា។ ដូចគ្នាផងដែរ ការសាងសង់ដោយគ្មានការអនុញ្ញាត ការធ្លាក់វត្ថុរឹង ឬមួយក៏វត្ថុណាមួយពីលើអគារ ការដួលរលំអាគារ ឬបញ្ហាជាច្រើនទៀតបែបនេះ យើងឃើញថាបញ្ហាទាំងប៉ុន្មាននេះ គឺទាក់ទងនឹងការទទួលខុសត្រូវក្នុងវិស័យសំណង់។ ដូចនេះយើងត្រូវលើកយកច្បាប់នានាដែលទាក់ទងនឹងការទទួលខុសត្រូវដែលពាក់ព័ន្ធនឹងសំណង់ ដើម្បីយកមកបកស្រាយ។

ជារួមមក កិច្ចការស្រាវជ្រាវនេះគឺមានគោលបំណងក្នុងការធ្វើការសិក្សាឱ្យបានកាន់តែស៊ីជម្រៅដើម្បីធានាដល់ការរស់នៅប្រជាពលរដ្ឋ ដោយខ្វាយខ្វល់ទៅលើបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងវិស័យសំណង់ មិនថាទ្រព្យសម្បត្តិ ឬសុខុមាលភាពសម្រាប់ម្ចាស់សំណង់ ឬអ្នកប្រើប្រាស់សំណង់ និងសាធារណៈជន រួមទាំងជាការជម្រុញទៅកាន់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ ក៏ដូចជាអ្នកដែលពាក់ព័ន្ធនឹងសំណង់ទាំងអស់ឲ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំង ព្រមទាំងយល់ដឹងបានច្បាស់អំពីកាតព្វកិច្ចនៃការទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់ ជាថ្នូរមកវិញសម្រាប់ការធានានូវសន្តិសុខ សុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាជន និងស្វែងយល់អំពីបញ្ហានានាដែលអាចកើតមានឡើងនាពេលអនាគត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សារណាដែលមានលក្ខណៈជាអត្ថបទស្រាវជ្រាវនេះ មានគោលដៅសិក្សា ចំពោះដំណើរការទទួលខុសត្រូវក្នុងវិស័យសំណង់ ដែលមានរៀបរាប់អំពីទិដ្ឋភាពទូទៅនៃវិស័យសំណង់ ក្នុងអំឡុងចុងឆ្នាំ២០១៩ រហូតមកដល់នាពេលបច្ចុប្បន្ន ដោយក្តោបទាំងនីតិវិធីនៃការរៀបចំក្នុងវិស័យសំណង់ មូលហេតុដែលនាំឱ្យមានការទទួលខុសត្រូវក្នុងវិស័យសំណង់ យន្តការនៃការដោះស្រាយវិវាទ ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណីក្នុងវិស័យសំណង់ និងការរួចផុតពីការទទួលខុសត្រូវក្នុងវិស័យសំណង់ផងដែរ។ ដោយការស្រាវជ្រាវនេះប្រព្រឹត្តិដោយប្រើប្រាស់អស់រយៈពេល៣ (បី) ខែ ដើម្បីឈានដល់ការចងក្រងបានជាអត្ថបទសារណាមួយនេះឡើងមក គឺសម្រាប់ការពារបញ្ចប់ការសិក្សាលើមុខជំនាញថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

បន្ថែមពីលើនេះទៀត នៅក្នុងការសាងសង់មួយ បច្ចេកទេស ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃសំណង់ពិតជាមានសារៈសំខាន់ព្រោះថាប្រសិនបើសំណង់មួយមិនធ្វើទៅតាម បច្ចេកទេស ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃសំណង់ដែលបានកំណត់ទេ នៅពេលកំពុងសាងសង់ ឬ សាងសង់រួច សំណង់នោះអាចនឹងបាក់រលំ ឬប្រើប្រាស់ទៅតាមអាយុកាលមិនបានយូរ។ អាស្រ័យហេតុនេះហើយ ប្រសិនបើការសាងសង់ មិនគោរពទៅតាមបទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ គុណភាព និងសុវត្ថិភាពដែលកំណត់ដោយច្បាប់ ស្តីពី សំណង់នោះទេ នោះនឹងក្លាយជាមូលហេតុដែលត្រូវទទួលក្នុងការសាងសង់ ដោយការមិនគោរពបទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃសំណង់នេះ ដែលត្រូវតែឈានទៅដល់ការទទួលខុសត្រូវចំពោះមុខច្បាប់ដែលជាចំណុចនៃសារៈសំខាន់នៃការស្រាវជ្រាវនេះផងដែរ។ ដោយសារតែសន្តិសុខ និង សុវត្ថិភាពសំណង់ ជាកត្តាដ៏សំខាន់គួរយកចិត្តទុកដាក់ ព្រោះថាវិស័យនេះមានហានិភ័យខ្ពស់ដែលអាចបង្កគ្រោះថ្នាក់ទៅដល់អាយុជីវិតមនុស្សផងដែរ បើយើងមិនគោរពទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

នៅក្នុងដំណើរនៃការស្រាវជ្រាវចំពោះប្រធានបទខាងលើនេះ គឺតម្រូវឱ្យមានការស្វែងរកពត៌មានដែលមានប្រភពទិន្នន័យចម្បងចេញពី ច្បាប់ស្តីពី សំណង់ ឆ្នាំ២០១៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីនោះ ចំពោះប្រភពនៃឯកសារបន្ទាប់បន្សំផ្សេងទៀត គឺយកចេញពីអនុក្រឹត្យ អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងសេចក្តីប្រកាសផ្សេងៗដែលទាក់ទងនឹងវិស័យសំណង់។ ចំពោះការប្រមូលពត៌មាន គឺពឹងផ្អែកយ៉ាងសំខាន់ទៅលើការយកឯកសារដែលមានប្រភពច្បាស់លាស់ ដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងគេហទំព័រផ្លូវការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ចំណែកវិធីសាស្ត្រក្នុងការវិភាគទិន្នន័យ គឺត្រូវមានការយោងយ៉ាងច្បាស់អំពីខ្លឹមសារដែលមាននៅក្នុងច្បាប់ក៏ដូចជាការបូកបញ្ចូលគ្នានូវសេចក្តីពន្យល់ណែនាំបន្ថែម អំពីលោកសាស្ត្រាចារ្យណែនាំ **បណ្ឌិត អ៊ុន សកក្កដា** ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ហេតុដូច្នេះ ដើម្បីឱ្យកាន់តែយល់ច្បាស់ និងជាការបកស្រាយនូវចំណោទបញ្ហាដូចមានរៀបរាប់ខាងលើ ទើបយើងខ្ញុំទាំងពីររូបសម្រេចចិត្តជ្រើសយកប្រធានបទ " **ការទទួលខុសត្រូវក្នុងវិស័យសំណង់**" មកធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សា ដើម្បីឆ្លុះបញ្ចាំងពីខ្លឹមសារដូចមានបែងចែកជា ២ ជំពូកធំៗគឺ៖

**ជំពូកទី ១** ៖ សញ្ញាណទូទៅនៃវិស័យសំណង់

**ជំពូកទី ២** ៖ ការទទួលខុសត្រូវក្នុងវិស័យសំណង់។

# ជំពូកទី១
# សញ្ញាណទូទៅនៃវិស័យសំណង់

# ជំពូកទី១
# សញ្ញាណទូទៅនៃវិស័យសំណង់

## ១.១. ទិដ្ឋភាពទូទៅនៃវិស័យសំណង់

ជាធម្មតាវិស័យសំណង់ ឬការអភិវឌ្ឍនៃអចលនទ្រព្យ ត្រូវបានគេលើកកម្ពស់ថា ជាជនទ្ទល់សេដ្ឋកិច្ចដ៏រឹងមាំមួយចំពោះប្រទេសជាតិ។ ការរីកលូតលាស់របស់ប្រទេសនីមួយៗ គឺមិនអាចរំពឹងតែលើវិស័យតែមួយនោះទេ តួយ៉ាងប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍនេះហើយ ដែលត្រូវពឹងផ្អែកទៅលើវិស័យជាច្រើននូវក្នុងការដឹកនាំប្រទេសជាតិអោយមានការអភិវឌ្ឍន៍ច្រើនជាងនេះ ដែលមួយក្នុងចំណោមវិស័យទាំងអស់នោះ គឺការពឹងផ្អែកទៅលើវិស័យសំណង់។ វិស័យសំណង់ គឺជាវិស័យមួយដែលអាចជាកត្តាជួយទ្រទ្រង់សេដ្ឋកិច្ចរបស់រដ្ឋមួយទាំងមូលដែលក្នុងនោះ វិស័យសំណង់អាចជួយទៅដល់កំណើននៃផលិតកម្ម ការដឹកជញ្ជូន ទំនាក់ទំនងជាតិ និងអន្តរជាតិ ក៏ដូចជាការបង្កើតឡើងនូវឱកាសការងារជាច្រើនទៅកាន់ប្រជាជនផងដែរ។ ម្យ៉ាងទៀត ដោយហេតុថាវិស័យសំណង់ត្រូវបានគេយកចិត្តទុកដាក់ជាខ្លាំង វាក៏អាចពាំនាំនូវវិនិយោគិនជាច្រើនមកវិនិយោគផងដែរ។ ដូច្នេះហើយ វិស័យសំណង់មានសារៈសំខាន់ណាស់សម្រាប់ប្រទេសជាតិនីមួយៗ ក៏ដូចជាប្រទេសកម្ពុជាផ្ទាល់ផងដែរ។[1] ហេតុដូច្នេះហើយទើបវិស័យនេះ ទាមទារឱ្យមានការថែទាំ ក៏ដូចជាច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីការពារនូវវិការៈ ឬគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើង។

### ១.១.១. បរិបទនៃវិស័យសំណង់

ដោយហេតុថា វិស័យសំណង់ជាវិស័យមួយដែលដើរតួយ៉ាងសំខាន់ដោយនេះជាកត្តាមួយដែលអាចលើកស្ទួយការអភិវឌ្ឍប្រទេសជាតិ ដូច្នេះដើម្បីស្វែងយល់អោយកាន់តែច្បាស់អំពីវិស័យសំណង់ រឿងដែលសំខាន់ ក៏ដូចជាចាំបាច់ក្នុងការបកស្រាយនោះ គឺត្រូវសិក្សាអោយស៊ីជម្រៅអំពីនិយមន័យនៃប្រធានបទ ការវិវត្តន៍នៃវិស័យសំណង់នៅក្នុងប្រទេសកម្ពុជាជាមុនសិន។

#### ១.១.១.១. និយមន័យ

ដើម្បីជាស្ពានឈាន ដល់ការស្រាយប្រធានបទការទទួលខុសត្រូវក្នុងវិស័យសំណង់កាន់តែមានភាពស៊ីជម្រៅ យើងគប្បីយល់ន័យនៃពាក្យគន្លឹះនៃពាក្យមួយចំនួនជាមុនសិន។ ចំពោះពាក្យថា "ការទទួលខុសត្រូវ" ដោយយោងតាមគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្ម

[1] គេហទំព័រ https://www.atlantafed.org/regional-economy/econsouth/vol_10_no_2/econsouth-vol_10_no_2-building_a_better_world ដកស្រង់ថ្ងៃទី១ ខែសីហា ឆ្នាំ២០២១

ទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ដោយបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ។[2] ផ្ទុយទៅវិញ ច្បាប់អាចអនុញ្ញាតឲ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីចំពោះអំពើរបស់អ្នកដទៃ ដូចជា ការទទួលខុសត្រូវរបស់ឪពុកម្ដាយ ចំពោះរបស់កូនដែលជាអនីតិជន និងការទទួលខុសត្រូវរបស់និយោជក ពីអំពើរបស់និយោជិតជាដើមនៅក្នុងមាត្រា ៧៤៦ និង មាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណី។[3]

ចំណែកឯពាក្យថា "សំណង់" គឺចង់សម្ដៅលើការសាងសង់ ដែលនៅក្នុងនោះបូករួមទាំងការសាងសង់ផ្ទះ អាគារ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតជាអាទិ៍។ យោងតាមវចនានុក្រម សម្ដេចសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យនៃពាក្យ "សំណង់" ថាជាការសាងសង់ ឬការប្រជុំផ្គុំគ្រឿងសម្ភារៈ ធ្វើឲ្យកើតបានជាលំនៅជាដើម។ យ៉ាងណាមិញបើអនុឡោមតាមសន្ធានុក្រមនៃច្បាប់ស្ដីពីសំណង់ ចំពោះពាក្យថា "សំណង់" គឺចង់សម្ដៅលើដល់ដំណើរការនៃការងារសំណង់ ដល់អាគារ គ្រឿងផ្គុំ ស្ថាបត្យការ្យទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ ឬ បណ្ដោះអាសន្នធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬ ផលិតផលសំណង់។[4]

ក្រោយពីបានបកស្រាយអត្ថន័យនៃពាក្យគន្លឹះខាងលើរួចមកហើយនោះ ប្រធានបទ "ការទទួលខុសត្រូវក្នុងវិស័យសំណង់" គឺចង់មានន័យថា បុគ្គលម្នាក់ៗត្រូវ ទទួលខុសត្រូវទាំងចំពោះអំពើផ្ទាល់ខ្លួន ព្រមទាំងចំពោះអំពើរបស់អ្នកដទៃ នៅក្នុងវិស័យដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យកម្មទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្ន ដែលធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬ ផលិតផលសំណង់។

**១.១.១.២. ការវិវត្តនៃសំណង់នៅកម្ពុជាចាប់ពីឆ្នាំ២០១៩-បច្ចុប្បន្ន**

ដោយគិតចាត់តាំងពីចុងឆ្នាំ២០១៩ ក្រោយពីច្បាប់ស្ដីពីសំណង់បានដាក់អោយប្រើប្រាស់ វិស័យសំណង់នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ចាប់ផ្ដើមមានការរីកចម្រើន និងរីកដុះដាលជាខ្លាំង ដោយសារមូលហេតុនៃកំណើនវិនិយោគិន និងកំណើនប្រជាជនមានការកើនឡើង ដូច្នេះតម្រូវការរបស់មនុស្សក៏កើនឡើងកាន់តែច្រើនដូចគ្នា ដែលក្នុងនោះយើងសង្កេតឃើញថា មានសំណង់លំនៅដ្ឋាន ឬអគារផ្សេងៗត្រូវបាននឹងកំពុងសាងសង់យ៉ាងហូរហៀដើម្បីបំពេញតាមសេចក្ដីត្រូវការស់ប្រជាពលរដ្ឋ ក៏ដូចជាវិនិយោគិនបរទេស។ ទន្ទឹមនឹងនេះ ដើម្បីធានាថាការសាងសង់ និងសំណង់ទាំងនោះ ត្រូវបានធ្វើឡើងដោយស្របទៅតាមបទដ្ឋានគតិយុត្ត ព្រមទាំងមិនបង្កនូវបញ្ហា ឬគ្រោះថ្នាក់ណាមួយជាយថាហេតុ អ្នកដែលមានបំណងចង់សាងសង់នូវសំណង់ថ្មី ត្រូវទទួលបាន

[2] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១

[3] មាត្រា ៧៤៦, មាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[4] សន្ធានុក្រមនៃច្បាប់ស្ដីពីសំណង់

លិខិតអនុញ្ញាតសាងសង់ជាមុនសិន ហើយលក្ខខណ្ឌនៃការស្នើសុំលិខិតនេះទៀតសោតក៏ត្រូវបានបញ្ញត្តិយ៉ាងជាក់លាក់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ដោយសង្កេតឃើញថា ក្រោយពី ច្បាប់ ស្តីពី សំណង់ បានចូលជាធរមានរួចមក ការគ្រប់គ្រងសំណង់ក៏មានការកែសម្រួលផងដែរ។ នៅក្នុងនោះរួមមាន លិខិតអនុញ្ញាតិសាងសង់ ជួលជុល ឬរុះរើ ការគ្រប់គ្រងគម្រោងប្លង់ ការគ្រប់គ្រង់ការងារសាងសង ឬ រុះរើ ការប្រើប្រាស់សំណង់ អធិការកិច្ចសំណង់ និងវិសមតិភាព។

ចំពោះលិខិតអនុញ្ញាតិសាងសង់ ជួលជុល ឬរុះរើ ច្បាប់ ស្តីពី សំណង់ បានចូលជាធរមានកាលពី ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ នេះមក មានបទប្បញ្ញត្តិមួយចំនួនបានបំពេញបន្ថែមទៅអនុក្រឹត្យលេខ៨៦ អនក្រ.ប្រក ស្តីពី លិខិតអនុញ្ញាតសាងសង់។ បទប្បញ្ញត្តិទាំងនោះបានចែងអំពីកាលៈទេសៈខ្លះៗ ចំពោះការសាងសង់ ឬរុះរើសំណង់ ដែលពុំចាំបាច់ត្រូវមានលិខិតអនុញ្ញាតិសាងសង់ជាមុន ពិសេសក៏បានចែងបន្ថែមអំពីប្រភេទសំណង់មួយចំនួនផ្សេងទៀតដែលពុំតម្រូវឱ្យមានលិខិតអនុញ្ញាតិសាងសង់ឡើយ។[5]

ចំណែកឯការគ្រប់គ្រងគម្រោងប្លង់ ដោយគ្រប់គ្រងទៅលើអ្នកសិក្សាគម្រោងប្លង់ កំណត់អំពីបទប្បញ្ញត្តិបច្ចេកទេស កម្មសិទ្ធិបញ្ញា និងការអនុវត្តគម្រោងប្លង់។ រាល់គម្រោងប្លង់ដែលបានសិក្សារួច ហើយសម្រាប់ដាក់ប្រើប្រាស់ក្នុងការងារសាងសង់ ឬរុះរើ អ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាប័ណ្ណ ត្រូវមានការចុះហត្ថលេខាទទួលខុសត្រូវនៅលើប្លង់នោះ ឬមានការអនុញ្ញាតអំពី រដ្ឋមន្ត្រី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃគម្រោងប្លង់ដែលសាងសង់។[6]

តាមរយៈ មាត្រា៣៣ នៃច្បាប់ស្តីពីសំណង់ នៅក្នុងគម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់រុះរើសំណង់គ្រប់ប្រភេទ ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពដោយត្រូវមានផ្លូវ ឬជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ពុំចាំបាច់ត្រូវរៀបចំបែបនេះឡើយ។[7]

រីឯការគ្រប់គ្រង់ការងារសាងសង់ ឬ រុះរើឡើងវិញ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចែងអំពីការគ្រប់គ្រងនេះនៅក្នុង ច្បាប់ ស្តីពី សំណង់ ក្នុងជំពូកទី១០ ដែលមានចំនួន ៨មាត្រា ដោយបានកំណត់យ៉ាងច្បាស់អំពីអ្នកណាជាអ្នកសាងសង់ ឬរុះរើ អ្នកណាដែលច្បាប់បានអនុញ្ញាតឱ្យសាងសង់។ ក្រៅពីនោះក៏

---

[5] មាត្រា ២៧ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[6] មាត្រា ៣២ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[7] មាត្រា ៣៣ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

មានចែងអំពីកាតព្វកិច្ចរបស់ម្ចាស់សំណង់នៅក្នុងដំណើរការនេះដែរ ដើម្បីរួមចំណែកក្នុងការទទួលខុសត្រូវទៅលើសំណង់របស់ខ្លួន។ ម្យ៉ាងវិញទៀតក៏មានចែងអំពីបទប្បញ្ញត្តិដែលត្រូវអនុវត្តដូចការសិក្សាគម្រោងប្លង់ដែរ ហើយនឹងចែងអំពីលិខិតបើកការដ្ឋានសំណង់ ការគ្រប់គ្រងការដ្ឋានសំណង់ ប្រព័ន្ធត្រួតពិនិត្យ និងបញ្ជាក់សំណង់អាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកអនុញ្ញាតនៅក្នុងការសាងសង់ និងពិសេសបទប្បញ្ញត្តិដែលត្រូវអនុវត្ត។

ដូចគ្នាផងដែរ ចំពោះការប្រើប្រាស់សំណង់សព្វថ្ងៃនេះ តម្រូវការនៃភាពស្របច្បាប់នៃសំណង់ ពិតជាមានភាពចាំបាច់ក្នុងការគ្រប់គ្រងគុណភាព សុវត្ថិភាព និងសោភ័ណភាពនៃសំណង់។ ក្នុងនោះផងដែរ វិញ្ញាបនបត្រប្រើប្រាស់សំណង់ គឺជាឯកសារគតិយុត្តដ៏សំខាន់មួយក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិទៅតាមច្បាប់។ វាគឺជាឯកសារដែលចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញប្រកាសលេខ ១៧៧ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ទាក់ទងនឹងបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ សម្រាប់សំណង់ណាដែលបានសាងសង់រួចមុនច្បាប់សំណង់ចូលជាធរមាន។[8] ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក៏បានចេញជាសេចក្តីណែនាំលេខ ០០២ ដនស/ស ណាន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីអំពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់ ផងដែរ។ ការត្រួតពិនិត្យ និងបញ្ជាក់គុណភាពសំណង់បានអនុវត្តទៅតាមគោលការណ៍ និងវិធានការដូចជា ត្រូវតែពិនិត្យថាសំណង់មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ លិខិតបើកការដ្ឋានសំណង់ ការរៀបចំការដ្ឋានដំណើរការការដ្ឋានសំណង់ និងការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់។[9]

ម៉្យាងទៀតចំពោះ អធិការកិច្ចសំណង់ ជាមន្ត្រីនគរបាលយុត្តិធម៌ដែលជួយដល់កិច្ចការតុលាការនៅក្នុងការចាត់ចែងបទល្មើសសំណង់ដែលស្រាលជាងគេ និងមានសិទ្ធិក្នុងការដាក់ពិន័យអន្តរការណ៍ទៅលើបទល្មើសសំណង់ទាំងនោះ។[10]

ចំណែកឯវិសមិតភាពវិញ គឺដើម្បីធានាប្រសិទ្ធិភាពក្នុងការបំពេញការងារឱ្យបានត្រឹមត្រូវ ច្បាប់សំណង់បានកំណត់អំពីគោលការណ៍វិសមិតភាពនៃការអនុវត្តការងារសំណង់ រវាងអ្នកដែលទទួលសមត្ថកិច្ច ឬក៏អ្នកដែលទទួលសម្បទាឱ្យអនុវត្តការងារនៃសំណង់ផ្សេងៗ។ ជាមួយគ្នានោះផងដែរ មន្ត្រីអធិការកិច្ច ឬមួយក៏មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ ត្រូវបានហាមឃាត់ ដោយមិនឱ្យជាម្ចាស់សំណង់ ជាសហព័ទ្ធ ជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង ៣ថ្នាក់ ឬ ញាតិពន្ធក្នុង ៣ថ្នាក់ របស់ម្ចាស់សំណង់ដែលខ្លួន

[8] ប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់

[9] សេចក្តីណែនាំ លេខ ០០២ ដនស/សណន ស្តីអំពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

[10] មាត្រា៩៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

ត្រួតពិនិត្យបានឡើយ ឬក៏មិនអាចជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានដែរ។[11]

### ១.១.២. នីតិវិធីនៃការរៀបចំក្នុងវិស័យសំណង់

នៅក្នុងការរៀបចំសណ្ដាប់ធ្នាប់ ព្រមទាំងជាការធានានូវរបៀបរៀបរយនៃសំណង់សាងសង់ គឺគេតម្រូវឱ្យមានការស្នើសុំ និងការត្រួតពិនិត្យពីរយៈសមត្ថកិច្ច ដែលជាមន្ត្រីអធិការកិច្ចសំណង់ ដើម្បីការថែរក្សា នូវសុខសុវត្ថិភាព និងសុខុមាលភាពដល់ប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលជាម្ចាស់សំណង់ ក៏ដូចជាអ្នកដែលប្រកបអាជីវកម្ម និងអ្នកប្រើប្រាស់ផងដែរ រួមទាំងជាការប្រការការពារនូវការខាតបង់ប្រយោជន៍មួយ ដែលអាចកើតមានឡើងក្នុងអំឡុងពេលសាងសង់សំណង់ជាអាទិ៍។ ដូចនេះហើយ ច្បាប់ស្ដីពីសំណង់ដែលចុះឱ្យប្រើប្រាស់នៅចុងឆ្នាំ២០១៩ បានចែងអំពីការស្នើសុំ និងការត្រួតពិនិត្យនឹងត្រូវអនុវត្តទៅតាម ១. នីតិវិធីនៃការស្នើសុំ និង ២. នីតិវិធីនៃការត្រួតពិនិត្យដូចតទៅៈ

#### ១.១.២.១. នីតិវិធីនៃការស្នើសុំ

តាមរយៈមាត្រា២៦ នៃច្បាប់ ស្ដីពី សំណង់ បានបញ្ញត្តិថា "រាល់ការងារសាងសង់ ឬ រុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច"។[12] ដូចនេះការអនុញ្ញាត ត្រូវធ្វើឡើងជាលិខិតបទដ្ឋានគតិយុត្តពោលគឺលិខិតអនុញ្ញាត។ ក្នុងនោះផងដែរ ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរ មានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។[13] នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ រុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[14] ក្នុងការស្នើសុំលិខិតអនុញ្ញាតសាងសង់ សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់របស់សាមីនោះ សំណើរត្រូវធ្វើជាភាសាខ្មែរ ហើយឯកសារដែលភ្ជាប់មកជាមួយ រួមមាន ច្បាប់ថតចម្លងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ប្លង់ស្ថាបត្យកម្ម សាលាកបត្រដីឡូត៍ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន កិច្ចសន្យាសាងសង់ និងច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ។[15]

---

[11] មាត្រា៦៣ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[12] មាត្រា ២៦ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[13] មាត្រា៣៤ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[14] មាត្រា៤១ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[15] តារាងពិនិត្យឯកសារ និងគម្រោងស្នើសុំលិខិតអនុញ្ញាតសាងសងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជាការកំណត់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្នុងមាត្រា១៧ នៃច្បាប់ស្តីពីសំណង់បានបញ្ជាក់ថា "ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានីខេត្តទៅតាមប្រភេទអាជីវកម្ម។" ដូច្នេះតាមអត្ថន័យនៃមាត្រានេះ មានតែសំណង់ដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្មប៉ុណ្ណោះដែលតម្រូវឱ្យមានអាជ្ញាបណ្ណ ដោយឡែកការសាងសង់ជាលក្ខណៈគ្រួសារមិនតម្រូវឱ្យមានអាជ្ញាបណ្ណឡើយ។ គួរសម្គាល់ថាការតម្រូវឱ្យមានអាជ្ញាបណ្ណនេះ គឺធ្វើឡើងក្នុងគោលបំណង ដើម្បីធានានូវភាពស្មើគ្នានៃផលប្រយោជន៍រវាងអ្នកប្រកបអាជីវកម្ម និងអ្នកប្រើប្រាស់ ក៏ដូចជារួមចំណែកក្នុងការទប់ស្កាត់នូវសកម្មភាពប្រកបអាជីវកម្មខុសច្បាប់ដូចជាករណីលាងសម្អាតប្រាក់ជាអាទិ៍ ផងដែរ។[16]

ដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ នៅពេលដែលរូបវន្តបុគ្គល បានបំពេញលិខិតស្នើសុំ ព្រមទាំងបានរៀបចំសំណុំឯកសារភ្ជាប់រួចរាល់ ត្រូវយកសំណុំឯកសារទាំងនោះ ទៅដាក់នៅការិយាល័យទទួលបន្ទុកលិខិតអនុញ្ញាតសាងសង់។ ចំពោះក្រុងភ្នំពេញ និងទីក្រុងដទៃទៀត សំណុំលិខិតស្នើសុំខិតអនុញ្ញាតសាងសង់ ត្រូវយកដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ចំណែកចំពោះខេត្តវិញ ត្រូវយកដាក់នៅសាលាខេត្ត-ក្រុង។

➢ សំណុំនៃលិខិតស្នើសុំនោះនឹងប្រព្រឹត្តិទៅដូចតទៅ៖

នៅពេលដែលមន្ត្រីទទួលបន្ទុកបានទទួលសំណុំលិខិតស្នើសុំ ព្រមទាំងសំណុំឯកសារភ្ជាប់ផ្សេងៗពីរូបវន្តបុគ្គលរួចហើយ អាជ្ញាធមានសមត្ថកិច្ចនឹងធ្វើការពិនិត្យសំណុំលិខិតទាំងអស់នោះ ដោយធានាថាសំណុំលិខិតទាំងនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមច្បាប់តម្រូវ។ នៅពេលដែលបានដាក់សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់រួចរាល់ និងគ្រប់គ្រាន់ហើយ មន្ត្រីទទួលលិខិត នឹងចេញបង្កាន់ដៃទទួលពាក្យសុំនោះឱ្យទៅអ្នកស្នើសុំ។[17]

ក្រោយពីទទួលបានសំណុំលិខិតស្នើសុំរួចហើយ អាជ្ញាធរមានសមត្ថកិច្ច នឹងធ្វើការផ្សព្វផ្សាយដំណឹងទៅកាន់សាធារណៈជន អំពីការដាក់ពាក្យសុំនេះ ដោយបិទប្រកាសផ្សាយនៅសាលាខណ្ឌ ស្រុក ខេត្ត និងនៅកន្លែងសាង់សង់គម្រោង។

ម្យ៉ាងទៀត ក្នុងករណីចំពោះអគារ និងបណ្តាការ្យធំៗ ដែលមានប្រភេទអាចធ្វើឱ្យរំខានដល់សុវត្ថិភាពសុខុមាលភាពសាធារណៈ អាជ្ញាធរមានសមកិច្ច ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យសុំលិខិត

[16] មាត្រា ១៧ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ វិច្ឆិកា ២០១៩

[17] មាត្រា ៨ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

អនុញ្ញាតសាងសង់ ដោយវិធីណាមួយផ្សេង ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាននៅតាមមូលដ្ឋាន។[18]

**១.១.២.២. នីតិវិធីនៃការត្រួតពិនិត្យ**

នៅក្នុងនីតិវិធីនៃការត្រួតពិនិត្យរបស់អធិការកិច្ចសំណង់នោះ គឺដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

ជាមួយគ្នាផងដែរ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានចេញប្រកាសលេខ ១៤១ ដនស/ប្រកបនី.ក ចុះនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចសំណង់ដែលចែកចេញជា មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ និងមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រោមជាតិ។[19] នៅក្នុងនោះផងដែរបានរៀបរាប់អំពីភារកិច្ច និងសិទ្ធិរបស់មន្ត្រីអធិការកិច្ចសំណង់ដូចជា៖ ទី១. ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ និងទី២. ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ និងទី៣. ចាប់យកវត្ថុតាង និងកសាងសំណុំរឿងនៃបទល្មើសសំណង់ រីឯទី៤. ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។[20] មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។[21]

អាស្រ័យហេតុនេះហើយ ក្នុងការសាងសង់ ឬរុះរើមួយ ដែលចាត់ទុកថាត្រឹមត្រូវ ឬស្របច្បាប់ លុះត្រាតែនៅពេលដែលមន្ត្រីអធិការកិច្ចចុះអធិការកិច្ច ហើយរកមិនឃើញនូវអំពើល្មើស។

## ១.២. មូលហេតុដែលនាំឱ្យមានការទទួលខុសត្រូវក្នុងវិស័យសំណង់

មុននឹងឈានដល់ការសិក្សាអំពីការទទួលខុសត្រូវក្នុងវិស័យសំណង់ យើងគួរគប្បីសិក្សាអំពីមូលហេតុដែលនាំឲ្យមានការទទួលខុសត្រូវក្នុងវិស័យសំណង់ជាមុនសិន ដែលមូលហេតុទាំងនោះស្តីអំពី ការមិនគោរពបទប្បញ្ញត្តិបច្ចេកទេសនៃសំណង់។

[18] មាត្រា ១២ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

[19] ប្រកាសលេខ ១៤១ ដនស/ប្រកបនី.ក ចុះនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចសំណង់

[20] មាត្រា ៥៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[21] មាត្រា ៦០ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

### **១.២.១. ការមិនគោរពបញ្ញាត្តិបច្ចេកទេសនៃសំណង់**

ចំពោះការសាងសង់សំណង់នីមួយៗ ការគោរពតាមបទប្បញ្ញាត្តិបច្ចេកទេសនៃសំណង់ គឺមានសារៈសំខាន់ជាខ្លាំង ដើម្បីជាការធានាដល់ បច្ចេកទេស ស្តង់ដារ គុណភាព ហើយបូករួមទាំងសុវត្ថិភាពនៃសំណង់។ ហេតុដូចនេះហើយទើបគេតម្រូវឱ្យមានការអនុវត្តទៅតាមបទដ្ឋាននៃបច្ចេកទេស ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃសំណង់ ដោយសំអាងថា កាលណាការប្រព្រឹត្តទៅនៃការងារសំណង់មិនបានធ្វើតាមរបៀបរៀបរយនៃបទបញ្ញាត្តិបច្ចេកទេសនោះទេ រមែងតែងបង្កជាមូលហេតុនៃគ្រោះថ្នាក់នានា ដែលអាចនាំឱ្យមានការទទួលខុសត្រូវក្នុងវិស័យសំណង់។ ជាមួយគ្នាផងដែរយើងនឹងលើកយកមូលហេតុទាំងនោះយកមកសិក្សា ដែលជាការមិនគោរពបញ្ញាត្តិបច្ចេកទេសនៃសំណង់ដូចតទៅ៖ ១. សុវត្ថិភាពគ្រឿងផ្គុំ ២. សុវត្ថិភាពអគ្គីភ័យ ៣. ការដាក់ឱ្យប្រើប្រាស់ សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និង៤. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់។

#### **១.២.១.១. សុវត្ថិភាពគ្រឿងផ្គុំ**

ដូចមានចែងក្នុងមាត្រា៨ នៃច្បាប់ស្តីពី សំណង់ បានបញ្ញាត្តិថា "រាល់សំណង់ត្រូវមានគ្រឿងផ្គុំ ដែលអាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។ ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យ និងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។"[22]

តាមរយៈមាត្រា៨ នៃច្បាប់ស្តីពី សំណង់អាចឱ្យដឹងថាការគោរពទៅតាមបទបញ្ញាត្តិបច្ចេកទេសសុវត្ថិភាពគ្រឿងផ្គុំនៃសំណង់ដែលមានកំណត់នៅក្នុងច្បាប់គឺ មានសារៈសំខាន់ណាស់ដល់ការធានានូវសុវត្ថិភាពដល់ការសាងសង់ រួមទាំងដើម្បីការប្រព្រឹត្តិទៅប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដែលរាល់សំណង់ត្រូវមានគ្រឿងផ្គុំ ដែលអាចទ្ររាល់បន្ទុកបាន។

#### **១.២.១.២. សុវត្ថិភាពអគ្គីភ័យ**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការ និងការពន្លត់អគ្គិភ័យ។ ចំណាត់ថ្នាក់ ប្រភេទ និង ទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យ និងបញ្ជាក់អំពីសុវត្ថិភាពអគ្គីភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[23] ក៏ប៉ុន្តែក្នុង

[22] មាត្រា ៨ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[23] មាត្រា ៩ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

ការអនុវត្តជាក់ស្តែងមិនមានប្រកាសណាមួយត្រូវបានចេញនៅពេលដែលច្បាប់ស្តីពី សំណង់ នេះចូលជាធរមាននៅឡើយទេ។

យ៉ាងណាមិញ យើងឃើញមានអនុក្រឹត្យដែលប្រកាសឱ្យប្រើនៅឆ្នាំ២០១៨ ស្តីពី "ចំណាត់ថ្នាក់សំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ។" ក្រសួងមហាផ្ទៃ ត្រូវបានសន្មត់ថា ជាសមត្ថកិច្ចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិសនី។[24]

ជាមួយគ្នានោះផងដែរសំណង់ ត្រូវបានកំណត់ចំណាត់ថ្នាក់ជាប្រាំ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យដែលរួមមាន[25]៖

- ចំណាត់ថ្នាក់ទី១៖ សំណង់ ឬ គោលដៅពាណិជ្ជកម្មទាក់ទងនឹងការផលិត ការលក់ ការកែច្នៃ ការស្តុកស្ថានីយប្រេង និងការប្រើប្រាស់ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះ និងងាយផ្ទុះឆេះ។
- ចំណាត់ថ្នាក់ទី២៖ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពរបស់រដ្ឋ គ្រឹះស្ថានសាធារណៈ និងឯកជន។
- ចំណាត់ថ្នាក់ទី៣៖ សំណង់ ឬគោលដៅនៃទីប្រជុំជនដែលមានប្រជាជនរស់នៅច្រើនកុះករ អគារសហកម្មសិទ្ធិ បុរីលំនៅឋាន ឬលំនៅឋានមានលក្ខណៈជាបុរី បណ្តុំអគារពាណិជ្ជកម្មធំៗ រោងភាពយន្ត រោងមហោស្រព សារមន្ទីរជាតិ បណ្ណសារជាតិ បណ្ណាល័យជាតិ ទីកន្លែងសប្បាយភាព ក្លឹបកំសាន្ត ស្ថានីយវិទ្យុស្ថានីយទូរទស្សន៍ ស្ថានីយទូរគមនាគមន៍ ក្រុមហ៊ុនគោលដៅស្រាវជ្រាវវិទ្យាសាស្ត្រ អាកាសយានដ្ឋាន ស្ថានីយរាជាយស្ម័យយាន កំពង់ផែ យានដ្ឋាន និងចំណតយានយន្ត។
- ចំណាត់ថ្នាក់ទី៤៖ សំណង់ ឬគោលដៅដែលស្ថិតនៅតំបន់ភ្នំ តំបន់ព្រៃ តំបន់អភិរក្ស រមណីយដ្ឋាន ស្ថានីយអគ្គិសនី វារីអគ្គិសនី រោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម និងការដ្ឋានរ៉ែ។
- ចំណាត់ថ្នាក់ទី ៥៖ អគារពាណិជ្ជកម្មខ្នាតតូច និងផ្សារ។

មុនដំណើរការសាងសង់ ម្ចាស់សំណង់ ឬ ម្ចាស់គោលដៅ ត្រូវមានគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យដែលត្រូវបានសិក្សា និងគូសដោយអ្នកជំនាញមានវិជ្ជាជីវៈ ហើយមានការទទួលស្គាល់ ដោយស្ថាប័នដែលមាន

[24] មាត្រា៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ, ២៥ មិថុនា ២០១៨

[25] មាត្រា១២ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ, ២៥ មិថុនា ២០១៨

សមត្ថកិច្ច និងមានការបញ្ជាក់ទទួលស្គាល់អំពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។[26]

ថ្វីត្បិតតែអនុក្រឹត្យនេះ មានចែងពីកាតព្វកិច្ចដែលម្ចាស់សំណង់ ឬម្ចាស់គោលដៅត្រូវតែធ្វើ ប៉ុន្តែចំពោះបទដ្ឋានជាក់លាក់យ៉ាងណា ដែលត្រូវអនុវត្តចំពោះប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យមិនត្រូវបានបញ្ញត្តិឡើយ។

**១.២.១.៣. ការដាក់ឱ្យប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់**

អនុលោមតាមមាត្រា១០ នៃច្បាប់ ស្ដីពី សំណង់ ដែលបានបញ្ញត្តិដូចតទៅ "[...] បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារ សំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដាណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុក វិស័យឧស្សាហកម្មតាមសំណើររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ។ បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀត ដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដារកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់"។[27] ក៏ប៉ុន្តែគិតរហូតមកដល់ពេលបច្ចុប្បន្ន ប្រកាសស្តីពី សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ មិនទាន់បានប្រកាសឱ្យប្រើប្រាស់នៅឡើយទេ។

**១.២.១.៤. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់នេះ គឺសំដៅលើ ស្ថាបត្យករ និងវិស្វករ។[28] ចំពោះ "ស្ថាបត្យករ" ត្រូវចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជា ដែលគណៈស្ថាបត្យករកម្ពុជានេះ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ បង្កើតឡើងក្នុងគោលបំណងដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងស្ថាបត្យករដែលបានចុះបញ្ជីរួមចំណែករៀបចំវិជ្ជាជីវៈស្ថាបត្យកម្មឱ្យកាន់តែល្អប្រសើរ និងចូលរួមចំណែកថែរក្សា ការពារ អភិវឌ្ឍស្ថាបត្យកម្មខ្មែរ ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិជ្ជាជីវៈ ព្រមទាំងធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន។ ចំណែកឯ "វិស្វករ" វិញ ត្រូវចុះបញ្ជីនៅគណៈវិស្វករកម្ពុជា ដែលគណៈវិជ្ជាជីវៈនេះ បង្កើតឡើងក្នុងគោលបំណង ដើម្បីអភិវឌ្ឍសង្គមសេដ្ឋកិច្ច ឱ្យបានល្អប្រសើរឡើង ដោយការចាប់ផ្តើមប្រមូលធនធានបញ្ញវន្តជាតិ មកអភិវឌ្ឍសមត្ថភាពប្រតិបត្តិវិជ្ជាជីវៈ និងការផ្តល់ឱកាសការងារដោយស្របច្បាប់។

[26] អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ, ២៥ មិថុនា ២០១៨, មាត្រា១៦ កថាខណ្ឌទី១ និងទី២

[27] មាត្រា ១០ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[28] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសំណង់ សទ្ទានុក្រម លេខ៣២

លិខិតបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រង អ្នកវិជ្ជាជីវៈក្នុងការសាងសង់ ក៏ត្រូវបានកំណត់នៅក្នុងច្បាប់ ស្តីពី សំណង់ ដែលមិនខុសគ្នាពី សុវត្ថិភាពគ្រឿងផ្គុំ ការបង្ការនិងពន្លត់អគ្គីភ័យ និងសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ទេ ដែលច្បាប់ ស្តីពី សំណង់ បានបញ្ញត្តិនោះទេ។ អនុលោមតាម មាត្រា ១២ កថាខណ្ឌ ទី១ នៃច្បាប់ស្តីពីសំណង់ បានបញ្ញត្តិថា "រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់"។ តាមអត្ថន័យនៃមាត្រានេះ ដើម្បីប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់បាន ដាច់ខាតអ្នកវិជ្ជាជីវៈទាំងនោះ ត្រូវធ្វើការចុះបញ្ជី នៅឯតាមគណៈវិជ្ជាជីវៈវិស័យសំណង់នីមួយៗ។[29]

## ១.៣. យន្តការនៃការដោះស្រាយវិវាទ

ជាធម្មតាកាលណាមានការវិវាទណាមួយកើតឡើង ដែលទាក់ទងទៅនឹងការងារសំណង់ អ្នកដែលពាក់ព័ន្ធទាំងអស់អាចមានសិទ្ធិស្របច្បាប់យ៉ាងពេញលេញ ក្នុងការស្វះស្វែងរកយន្តការ នៃការដោះស្រាយនូវវិវាទនានាដែលកំពុងជួបប្រទះ។ អាស្រ័យហេតុនេះ ដើម្បីជាប្រយោជន៍ និងជាភាពងាយស្រួលទៅដល់ការស្វែងរកដំណោះស្រាយឱ្យកាន់តែមានភាពឆាប់រហ័ស ព្រមទាំងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ការដោះស្រាយវិវាទត្រូវបានបែងចែកជា ២ វិធីសាស្ត្រ ដូចជា ១.យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង ២.យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។

### ១.៣.១. យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺចង់សំដៅលើការដោះស្រាយវិវាទ ដោយមិនឆ្លងកាត់នីតិវិធីតុលាការ ឬជាជម្រើសដ៏ល្អប្រសើររបស់គូភាគីវិវាទដែលបានឯកភាពគ្នាធ្វើការដោះស្រាយវិវាទដោយមិនចូល ឬមុននឹងចូលទៅតុលាការ។ វាជាការដោះស្រាយវិវាទដោយការជ្រើសរើសរបស់គូភាគីវិវាទក្នុងការដោះស្រាយវិវាទណាមួយដោយមិនឆ្លងកាត់តុលាការ ហើយទាមទារឱ្យគូភាគីត្រូវតែព្យាយាមដោះស្រាយដោយសន្តិវិធី ដើម្បីទទួលបានជោគជ័យ។ ប៉ុន្តែវិធីសាស្ត្រនេះ មិនមែនជាជម្រើសចុងក្រោយរបស់គូភាគីវិវាទឡើយ ព្រោះគូភាគីវិវាទអាចធ្វើការជ្រើសរើស នូវការដោះស្រាយវិវាទតាមផ្លូវតុលាការដោយផ្ទាល់ ឬបន្ទាប់ពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនទទួលបានជោគជ័យ។

[29] មាត្រា ១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

**១.៣.១.១.ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់**

អនុឡោមតាមមាត្រា៨៦ នៃច្បាប់ស្ដីពី សំណង់ ឆ្នាំ២០១៩ បានបញ្ញត្តិដូចតទៅ៖

បុគ្គលដែលរងការខូចខាត ឬមានការបារម្ភណ៍ជាក់ស្ដែងថា នឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិ ឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ នៅក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការ។

សំណើសុំ សម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទ សំណើ ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគី នៃវិវាទក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលឱ្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់ សម្រេចបដិសេធសំណើសុំសម្រុះសម្រួល នោះគណៈកម្មការដោះស្រាយវិវាទសំណង់ ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះ ម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួល ក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នា ជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។[30]

**១.៣.១.២. ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យាម៉ៅការសាងសង់ ឬរុះរើ**

ជាមួយគ្នាផងដែរ តាមរយៈមាត្រា៨៧ នៃច្បាប់ស្ដីពីសំណង់ បានបញ្ញត្តិដូចតទៅ៖

ភាគី ឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ ឬរុះរើ អាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើនោះ។ នៅក្នុងនោះរាល់ សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃ ដែលវិវាទបានកើតឡើង។ ម្យ៉ាងទៀតគណៈកម្មការដោះស្រាយវិវាទសំណង់ ត្រូវធ្វើការ

[30] មាត្រា ៨៦ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

សម្រុះសម្រួលជាមួយគូភាគីនៃវិវាទ និងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។[31]

គួរកត់សម្គាល់ថា ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួល និងដោះស្រាយវិវាទ របស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាល នៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូន ដំណឹងជាលាយលក្ខណ៍អក្សរ ទៅកាន់គណៈកម្មការដោះស្រាយវិវាទសំណង់ អំពីការឈប់ទទួលយកការ សម្រុះសម្រួល និងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទ សំណង់មុននឹង ប្ដឹងទៅដល់តុលាការ។

មិនតែប៉ុណ្ណោះអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីដែលមាននូវសំណើសុំ សម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។[32]

រចនាសម្ព័ន្ធនៃគណៈកម្មការ ស្រាយវិវាទសំណង់មានដូចតទៅ៖

១- គណៈកម្មការដោះស្រាយវិវាទ សំណង់ ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទ សំណង់ ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទ សំណង់ ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈកម្មការដោះស្រាយវិវាទ សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។[33]

### ១.៣.២. យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ

ក្នុងករណីដែលភាគីទាំងអស់មិនបានព្រមព្រៀងគ្នា ក្នុងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទេ នោះ ភាគីអាចធ្វើការប្ដឹងតវ៉ា នៅក្នុងប្រព័ន្ធតុលាការបាន ដើម្បីឲ្យតុលាការ ក៏ដូចជាចៅក្រមជំនុំជម្រះក្ដី និងស្វែង រកយុត្តិធម៌ផ្សេងៗទៅតាមការអះអាងរបស់ភាគីមានជម្លោះ។

#### ១.៣.២.១. ការប្ដឹងតវ៉ាក្នុងវិស័យសំណង់

ដោយផ្អែកតាម ច្បាប់ស្ដីពី សំណង់ នៅក្នុងមាត្រា៨៣ បានបញ្ញត្តិយ៉ាងជាក់លាក់ថា៖ បុគ្គលដែលមាន ទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ា ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដី សម្រេចនោះ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្ដីសម្រេចនោះ ឬទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ មិនតែប៉ុណ្ណោះអាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្ដឹងត្រូវចេញសេចក្ដីសម្រេច

[31] មាត្រា ៨៧ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[32] មាត្រា ៨៨ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[33] មាត្រា ៨៩ នៃច្បាប់ស្ដីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

ជាលាយលក្ខណ៍អក្សរលើបណ្តឹងតវ៉ា ដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។ យ៉ាងណាមិញ ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ច ទទួលបណ្តឹង មិនសម្រេចលើបណ្តឹងតវ៉ា ក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។ ដូចគ្នាផងដែររដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃ ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលបានពាក្យបណ្តឹង។ ក្នុងករណីមានបុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ា គឺមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ចំណែកឯក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ានៅក្នុងរយៈពេលដូចមានកំណត់ក្នុង កថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។[34]

ជាមួយគ្នាផងដែរ បុគ្គលដែលមានទំនាក់ទងទៅនឹងផលប្រយោជន៍ក៏ដូចជា ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុង រយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ជាមុន មុននឹងប្តឹងទៅតុលាការ។ ក្រោយមករដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យ។ ក្នុងករណីបុគ្គលណាមួយមិនសុខចិត្ត ចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។[35]

ក្រៅពីនោះរាល់បុគ្គល ដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬ អាចប្តឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។ ហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពី

[34] មាត្រា ៨៣ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[35] មាត្រា ៨៤ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

មូលហេតុក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។ ដូចគ្នាផងដែរនៅក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ចំពោះករណីនេះកាលណាដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការបាន ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។[36]

[36] មាត្រា ៨៥ នៃច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

# ជំពូកទី២
# ការទទួលខុសត្រូវក្នុងវិស័យសំណង់

# ជំពូកទី២

# ការទទួលខុសត្រូវក្នុងវិស័យសំណង់

## ២.១. ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

បន្ទាប់ពីបានសិក្សាអំពីសញ្ញាណទូទៅនៃវិស័យសំណង់រួចមក ផ្នែកនេះនឹងរៀបរាប់អំពីការទទួលខុសត្រូវនៅក្នុងវិស័យសំណង់ ដែលលើកយកបុគ្គលដែលពាក់ព័ន្ធទាំងឡាយនៅក្នុងវិស័យសំណង់យកមកសិក្សា និងស្វែងយល់ថាបុគ្គលណាត្រូវទទួលខុសត្រូវយ៉ាងដូចម្តេចខ្លះ ក្នុងករណីសំណង់មានវិការៈ ហើយបង្កព្យសនកម្មដល់អ្នកដទៃ។

### ២.១.១. អ្នកសិក្សាគម្រោងប្លង់

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ប្រសិនបើគម្រោងប្លង់នៃសំណង់មានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

ដូច្នេះហើយ ប្រសិនបើក្នុងករណី ដែលសំណង់មានបញ្ហាដែលភស្តុតាងបានចង្អុលបង្ហាញថាមកពីគម្រោងប្លង់នៃសំណង់មានវិការៈ នោះអ្នកសិក្សាគម្រោងប្លង់នឹងត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយ លុះត្រាតែអ្នកសិក្សាគម្រោងប្លង់អាចស្វែងរកភស្តុតាងក្នុងការបញ្ជាក់អំពីគម្រោងប្លង់របស់ខ្លួនថាធ្វើដោយយោងតាមបទប្បញ្ញត្តិបច្ចេកទេស។[37]

### ២.១.២. ម្ចាស់សំណង់ និងអ្នកសាងសង់ ឬរុះរើ

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់ និងអ្នកសាងសង់ ឬរុះរើ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានដល់អ្នកដទៃ ក្នុងករណីដែលការសាងសង់ ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់មានវិការៈ។

បានសេចក្តីថា នៅពេលដែលសំណង់កំពុងត្រូវបានសាងសង់ ឬរុះរើ ម្ចាស់សំណង់ ព្រមទាំងអ្នកសាងសង់ត្រូវតែសាមគ្គីគ្នាក្នុងការទទួលខុសត្រូវរាល់ការខូចខាតដែលកើតមានទៅលើអ្នកដទៃ ប្រសិនបើសំណង់មានវិការៈ។[38]

[37] មាត្រា ៧៦ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[38] មាត្រា ៧៧ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

### ២.១.៣. អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់

អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ត្រូវតែទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យ និងបញ្ជាក់របស់ខ្លួន។

ដោយផ្អែកទៅលើបទប្បញ្ញត្តិមួយនេះ អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ត្រូវតែត្រួតពិនិត្យ និងបញ្ជាក់សំណង់ឲ្យបានហ្មត់ចត់ ជៀសវាងកើតមានឡើងនូវវិការៈផ្សេងៗ ដែលជាហេតុដែលនាំឲ្យមានការទទួលខុសត្រូវចំពោះសំណង់ដែលខ្លួនបានពិនិត្យ និងបញ្ជាក់។[39]

### ២.១.៤. ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួល

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។[40]

ក្នុងករណីនេះ វានឹងនាំឲ្យកើតមាននូវការទទួលខុសត្រូវជាសាមគ្គីភាពរវាង ម្ចាស់សំណង់ និងអ្នកជួល ប្រសិនបើភស្តុតាងបានចង្អុលបង្ហាញថាសំណង់មានវិការៈ ហើយធ្វើអោយប៉ះពាល់ដល់អ្នកដទៃ។

ម៉្យាងទៀត សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១. រយៈពេល ៣ (បី) ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២. រយៈពេល ១០ (ដប់) ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូចខាតបានកើតឡើង" ។[41]

### ២.១.៥. ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃ ដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

[39] មាត្រា ៧៨ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[40] មាត្រា ៧៩ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[41] មាត្រា ៨០ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

១. នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឲ្យមានការខូចខាត។

២. សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។[42]

ដោយឡែក សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១. រយៈពេល ៣ (បី) ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២. រយៈពេល ១០ (ដប់) ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឲ្យមានការប៉ះពាល់ ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម ២០ (ម្ភៃ) ឆ្នាំទៀត។[43]

## ២.២. ការទទួលខុសត្រូវក្នុងវិស័យសំណង់

សម្រាប់ការទទួលខុសត្រូវនៅក្នុងវិស័យសំណង់មានដូចជា ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណី ដែលនៅក្នុងនោះមានដូចជា ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិនិយអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឲ្យរុះរើ និង/ឬសាងសង់ឡើងវិញឲ្យដូចសភាពដើម ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។[44]

[42] មាត្រា ៨១ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩,

[43] មាត្រា ៨២ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[44] មាត្រា ៩០ នៃ ច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

### ២.២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌ

ប្រសិនបើយើងក្រឡេកមកមើលទៅលើបទល្មើសក្នុងវិស័យសំណង់វិញនោះ យើងអាចយោងទៅតាម មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ដែលបានចែងថា "មូលទោសរួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យ។ ការពិន័យត្រូវគិតជាប្រាក់រៀល"។[45]

ដូច្នេះ ការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងវិស័យសំណង់ គឺមានដូចតទៅ៖

ចំពោះជនណាដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។ ក្នុងករណីនៅប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល ១ (មួយ) ឆ្នាំ នោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង។[46]

ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនៅប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល ១ (មួយ) ឆ្នាំ នោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ។[47]

ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យ ឬដោយគ្មានអាជ្ញាបណ្ណនឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល។ ក្នុងករណីនៅប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល ១ (មួយ) ឆ្នាំត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង។[48]

ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឲ្យមានរបួស ឬបណ្តាលឲ្យខូចសុខភាពដល់អ្នកដទៃ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។[49]

ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឲ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ

[45] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១

[46] មាត្រា ៩៣ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[47] មាត្រា ៩៤ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[48] មាត្រា ៩៥ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[49] មាត្រា ៩៦ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

៤០.០០០.០០០ (សែសិបលាន) រៀល។ ក្នុងករណី ដែលជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទី ២ របស់អាជ្ញាធរមានសមត្ថកិច្ចឲ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ទ្វេដង។[50]

ចំពោះជនណាដែលបានប្រើ ឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឲ្យអនុវត្តតាមស្តង់ដាណាមួយជាកំណត់ ហើយបណ្តាលឲ្យមានរបួស ឬបណ្តាលឲ្យខូចសុខភាពដល់អ្នកដទៃនោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល។[51]

ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្តាលឱ្យមានរបួស ឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ នោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល។[52]

ចំពោះអ្នកសាងសង់ដែលបានសាងសង់ ឬរុះរើមិនអនុលោមតាមគម្រោងប្លង់ និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្តាលឱ្យមានរបួស ឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល។[53]

ចំពោះអ្នកត្រួតពិនិត្យ និងបញ្ជាក់ដែលបានបញ្ជាក់លើគម្រោងប្លង់ ឬការងារសាងសង់ ឬរុះរើ ថាត្រឹមត្រូវដែលតាមជាក់ស្តែង គម្រោងប្លង់ ឬការងារសាងសង់ ឬរុះរើនោះ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល។[54]

---

[50] មាត្រា ៩៧ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[51] មាត្រា ៩៨ ណៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[52] មាត្រា ៩៩ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[53] មាត្រា ១០០ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[54] មាត្រា ១០១ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

ចំពោះជនណាដែលប្រើប្រាស់ ឬដាក់ឱ្យប្រើប្រាស់ ក្នុងគោលដៅអាជីវកម្មនូវសំណង់ ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួស ឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ នោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល។[55]

កាលបើអំពើនេះបណ្តាលឲ្យមានការកាត់អវយវៈ ឬនាំឲ្យមានពិការភាពអចិន្ត្រៃយ៍ដល់ជនរងគ្រោះ នោះអំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២នៃច្បាប់ស្តីពីសំណង់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ។ ក្នុងករណីដែលអំពើនេះបាន បណ្តាលឲ្យមានមនុស្សស្លាប់ អំពើល្មើសដែលមានចែងក្នុង មាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ នៃច្បាប់ស្តីពីសំណង់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ។[56]

កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ នឹងត្រូវផ្តន្ទាទោសដូចទៅនឹងមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា ១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់ស្តីពីសំណង់។[57]

ចំពោះនីតិបុគ្គលណា ដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដោយគ្មានអាជ្ញាបណ្ណ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល។ នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុង មាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះ បទល្មើសដែលមានចែង ក្នុងមាត្រា ៩៧ មាត្រា ៩៨ មាត្រា ៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់ ស្តីពី សំណង់។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៦០.០០០.០០០ (ហុកសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ៖

១. ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយនីតិបុគ្គល និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

[55] មាត្រា ១០២ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[56] មាត្រា ១០៣ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

[57] មាត្រា ១០៤ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩

២. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ។

៣. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយ មាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ។

៤. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយ មាត្រា១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ។

៥. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ទៅតាមបែបបទកំណត់ដោយ មាត្រា១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ"។

៦. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ។[58]

ក្រឡេកមកកាន់ក្រមព្រហ្មទណ្ឌវិញម្តងនោះ គឺបទមនុស្សឃាតដោយអចេតនាដែលនេះគឺជាអំពើដែលបណ្តាលឲ្យស្លាប់អ្នកដទៃដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ឬក៏ការបំពានទៅលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។ ប្រសិនបើមានករណីនេះកើតឡើង ការផ្តន្ទាទោសដាក់ពន្ធនាគារគឺចាប់ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។[59]

ប្រសិនបើការខូចខាតដែលកើតមានមិនបានប៉ះពាល់ដល់អាយុជីវិតនោះទេ នោះករណីនេះអាចនឹងក្លាយជាបទបង្កឲ្យមានរបួសស្នាមដោយអចេតនា ដែលជាអំពើដែលបណ្តាលឲ្យមានរបួសដល់អ្នកដទៃដោយ ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ដែលបង្កឲ្យមានអសមត្ថភាព ក្នុងការធ្វើការងារស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ ឬការបំពានទៅលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។ ហើយបទល្មើសនេះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។[60]

[58] មាត្រា ១០៥ នៃច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩
[59] មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១
[60] មាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១

### ២.២.២. ការទទួលខុសត្រូវរដ្ឋប្បវេណី

ប្រសិនបើមានការខូចខាតដល់អ្នកដទៃនៅក្នុងវិស័យសំណង់ បន្ទាប់ពីការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងវិស័យសំណង់ បុគ្គលទាំងនោះក៏ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ចំពោះបុគ្គលទាំងឡាយដែលបានបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬអចេតនា នឹងត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។[61]

ម្យ៉ាងទៀត មាត្រា ៧៥៤ នៃក្រមរដ្ឋប្បវេណីក៏បានចែងអំពីអំពើអនីត្យានុកូលរួមផងដែរ ដែលក្នុងនោះអត្ថន័យនៃមាត្រានេះបានសបញ្ជាក់ថាបើមានការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗនឹងត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។[62]

ដោយផ្អែកទៅលើករណីជាក់ស្តែង និងបទប្បញ្ញត្តិច្បាប់ដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណីក៏បានចែងយ៉ាងជាក់លាក់អំពីការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដីផងដែរ ដែលខ្លឹមសារនោះគឺ ក្នុងករណីដែលការសាងសង់សំណង់ជាប់ដី ឬការគ្រប់គ្រងសំណង់នោះមានវិការៈ ហើយបានបណ្តាលឲ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ។ ប៉ុន្តែក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន។ រីឯបន្ទុករបស់កម្មសិទ្ធិករ នៃសំណង់ជាប់នឹងដី និងអ្នកគ្រប់គ្រងសំណង់នោះត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឲ្យមានវិការៈនៃការសាងសង់ ឬការគ្រប់គ្រង។[63]

បានសេចក្តីយ៉ាងខ្លីថា ប្រសិនបើកើតមាននូវការខូចខាតដល់អ្នកដទៃ នោះអ្នកប្រព្រឹត្តអំពើបំពានត្រូវទទួលខុសត្រូវរដ្ឋប្បវេណី ដោយការផ្តល់សំណងការខូចខាតទៅឲ្យជនរងគ្រោះដោយសារអំពើបំពានរបស់ខ្លួន។

## ២.៣. ការរួចផុតពីការទទួលខុសត្រូវក្នុងវិស័យសំណង់

បើទោះបីជាមានបទប្បញ្ញត្តិច្បាប់បានចែងយ៉ាងច្បាស់ថា ប្រសិនបើមានវិការៈនៅក្នុងវិស័យសំណង់ ហើយបានបង្កជាព្យសនកម្ម ឬការខូចខាតដល់អ្នកដទៃយ៉ាងណាក្តី បទប្បញ្ញត្តិច្បាប់ក៏បានចែងផងដែរអំពីលក្ខខណ្ឌនៅក្នុងការរួចផុតអំពីការទទួលខុសត្រូវក្នុងវិស័យសំណង់ផងដែរ។

ចំពោះអំពើដែលនាំឲ្យមានការខូចខាតទាំងឡាយ គឺត្រូវបានច្បាប់តម្រូវឲ្យរួចផុតពីកាតព្វកិច្ចទទួលខុសត្រូវលើព្យសនកម្មទាំងស្រុង ឬមិនទាំងស្រុង បើទោះបីជាមានចំណងហេតុផលច្បាស់លាស់យ៉ាងណាក៏ដោយ

[61] មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[62] មាត្រា ៧៥៤ នៃក្រមរដ្ឋប្បវេណី នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[63] មាត្រា ៧៥៣ នៃក្រមរដ្ឋប្បវេណី នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដែលតម្រូវអោយអ្នកដែលត្រូវទទួលខុសត្រូវស្វែងរកភស្តុតាងថាការខូចខាតនោះ គឺបណ្តាលមកពីករណីប្រធានសក្តិ រាជសក្តិ កំហុសជនរងគ្រោះ ឬជាអំពើរបស់តតិយជន។

### ២.៣.១. ករណីប្រធានសក្តិ និងព្រឹត្តការណ៍រាជសក្តិ

នៅពេលដែលមានព្រឹត្តិការណ៍ប្រធានសក្តិ ឬរាជសក្តិបានកើតឡើង ហើយបណ្តាលឲ្យសំណង់មានបញ្ហាដែលបង្កអោយមានគ្រោះថ្នាក់ ឬព្យសនកម្មផ្សេងៗទៅលើអ្នកដទៃ នោះអ្នកទទួលខុសត្រូវនៃព្យសនកម្មទាំងឡាយត្រូវរួចផុតពីកាតព្វកិច្ចទទួលខុសត្រូវ ព្រោះថាប្រធានសក្តិ គឺជាព្រឹត្តការណ៍ដែលមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជំនះបាន ដែលបណ្តាលមកពីគ្រោះធម្មជាតិ រីឯរាជសក្តិ គឺជាព្រឹត្តិការណ៍ដែលកើតឡើងពីទង្វើរបស់មនុស្សដូចជាសង្គ្រាមជាដើម។ ដូច្នេះហើយបានសេចក្តីថា ក្នុងករណីដែលកើតមាននូវគ្រោះធម្មជាតិ ឬក៏សង្គ្រាមបានកើតមានឡើង បុគ្គលដែលពាក់ព័ន្ធទៅនឹងវិស័យសំណង់ មិនត្រូវទទួលខុសត្រូវចំពោះព្យសនកម្មនោះទេ។[64]

### ២.៣.២. កំហុសរបស់ជនរងគ្រោះ

ប្រសិនបើព្យសនកម្មទាំងឡាយត្រូវបានបង្កឡើងទាំងស្រុងដោយសារតែជនរងគ្រោះ នោះវាមានន័យថាព្យសនកម្មទាំងស្រុងគ្មានចំណងហេតុ និងផលនោះទេ ដែលជាហេតុដែលនាំអោយមានការមិនទទួលខុសត្រូវរដ្ឋប្បវេណីសម្រាប់ព្យសនកម្មទាំងអស់នោះ។ នេះក៏ព្រោះតែជនរងគ្រោះបានបង្កព្យសនកម្មដោយខ្លួនឯង ដោយមិនមានពាក់ព័ន្ធជាមួយនឹងបុគ្គល ដែលពាក់ព័ន្ធនឹងវិស័យសំណង់នោះទេ ហើយក៏បានន័យថាមិនមានការទទួលខុសត្រូវក្នុងវិស័យសំណង់ផងដែរ។[65]

### ២.៣.៣. កំហុសរបស់តតិយជន

ចំពោះកំហុសដែលបណ្តាលមកពីអំពើរបស់តតិយជន ឬជនដែលមិនមែនជាជនរងគ្រោះ ឬមិនមែនជាជនដែលពាក់ព័ន្ធនឹងវិស័យសំណង់ នោះការទទួលខុសត្រូវក្នុងវិស័យសំណង់ គឺត្រូវធ្លាក់ទៅលើតតិយជនដែលបង្កព្យសនកម្មនោះ ហើយអ្នកពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបានរួចផុតពីការទទួលខុសត្រូវទាំងឡាយ។ នេះសបញ្ជាក់ឲ្យឃើញថា បុគ្គលដែលពាក់ព័ន្ធទៅនឹងវិស័យសំណង់ពុំបានធ្វើអោយមានវិការៈដែលនាំឲ្យកើតមាននូវទំនាក់ទំនងហេតុ និងផលក្នុងការទទួលខុសត្រូវឡើយ។[66]

---

[64] សៀវភៅ នីតិកាតព្វកិច្ច (ភាគទី ២), សាស្ត្រាចារ្យ ញឹក វុទ្ធី ទំព័រទី ២២

[65] សៀវភៅ នីតិកាតព្វកិច្ច (ភាគទី ២), សាស្ត្រាចារ្យ ញឹក វុទ្ធី ទំព័រទី ២៣

[66] សៀវភៅ នីតិកាតព្វកិច្ច (ភាគទី ២), សាស្ត្រាចារ្យ ញឹក វុទ្ធី ទំព័រទី ២៣

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបកស្រាយយ៉ាងស៊ីជម្រៅទៅលើប្រធានបទខាងលើរួចមក យើងអាចកត់សម្គាល់បានថា ការទទួលខុសត្រូវទៅលើវិស័យសំណង់ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងបរិបទសង្គមរបស់ប្រទេសកម្ពុជា។ ជាក់ស្តែង ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសកំពុងតែអភិវឌ្ឍ ហើយរាជរដ្ឋាភិបាលបានស្វះស្វែងនូវក្នុងការស្វែងរកវិនិយោគិន ទាំងក្នុង និងក្រៅប្រទេស អោយមកវិនិយោគនៅទឹកដីរបស់ប្រទេសកម្ពុជា។ ស្របពេលដែលប្រទេសកំពុងតែមានសន្ទុះនៃការអភិវឌ្ឍន៍ ការសាងសង់ជាច្រើនក៏ត្រូវបានបង្កើតឡើងព្រមគ្នា ដែលមានដូចជា ហេដ្ឋារចនាសម្ព័ន្ធទាំងសាធារណៈ និងឯកជន អគារពាណិជ្ជកម្ម រោងចក្រ និងសំណង់ជាច្រើនទៀត។

ដូច្នេះហើយ យើងអាចសន្និដ្ឋានបានថា ច្បាប់ស្តីពីសំណង់ ក៏ដូចជាឯកសារគតិយុត្តផ្សេងៗទៀត ដែលទាក់ទិនទៅនឹងសំណង់ បានដើរតួយ៉ាងសំខាន់ នៅក្នុងការសម្រួលទៅដល់ការអភិវឌ្ឍប្រទេសជាតិទាំងមូល។ តួយ៉ាង មួយផ្នែកនៃច្បាប់ស្តីពីសំណង់ បានចែងអំពីការទទួលខុសត្រូវក្នុងវិស័យសំណង់ ដែលនេះជាភាពចាំបាច់ក្នុងដំណើរការនៃការសាងសង់សំណង់ជាក់លាក់ណាមួយ ដែលអាចបញ្ចៀសបានរាល់បញ្ហាដែលអាចកើតមាន។ ម៉្យាងវិញទៀត បើសិនជាមានលក្ខខណ្ឌផ្ទុយពីបញ្ញត្តិច្បាប់ ឬគ្រោះថ្នាក់ណាមួយដែលអាចកើតមានឡើង នោះយើងអាចយោងទៅតាមបញ្ញត្តិដែលច្បាប់បានចែង ក្នុងការស្វែងរកបុគ្គលណាដែលត្រូវទទួលខុសត្រូវ ហើយការទទួលខុសត្រូវនោះមានលក្ខខណ្ឌអ្វីខ្លះ។

សរុបសេចក្តីមក ការទទួលខុសត្រូវក្នុងវិស័យសំណង់ ប្រៀបបានដូចជាគ្រឹះមួយដ៏រឹងមាំ ដែលដើរតួយ៉ាងសំខាន់នូវក្នុងការសម្រួលដល់ការរីកលូតលាស់របស់ប្រទេសកម្ពុជា។ ការទទួលខុសត្រូវទាំងឡាយ គឺជាការទទួលទាំងខុស និងទទួលទាំងត្រូវ ដែលនេះ គឺជាភាពចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍព្រមទាំង ការពង្រឹងឯកភាពជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវកន្លងមកនេះ ដោយមើលឃើញការប្រែប្រួលនៃវិស័យនេះ និងដើម្បីជាការចូលរួមជាចំណែកមួយ នៅក្នុងការជម្រុញឱ្យការទទួលខុសត្រូវក្នុងវិស័យសំណង់កាន់តែមានប្រសិទ្ធិភាព នោះយើងខ្ញុំមានគំនិតស្ទួចស្ទើងនូវក្នុងការបញ្ចេញជាយោបល់ និងសំណូមពរទៅកាន់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាសមត្ថកិច្ចពាក់ព័ន្ធដូចជា៖

- ធានាឱ្យបាននូវដំណើរការនៃការទទួលខុសត្រូវសំណង់ របស់បុគ្គលទាំងឡាយដែលពាក់ព័ន្ធទាំងអស់ប្រកបដោយតម្លាភាព និងត្រឹមត្រូវតាមច្បាប់ ដោយធ្វើការចាត់វិធានការតឹងរឹងទៅលើរាល់អំពើកេញប្រវ័ញ្ច ការប្រកាន់បក្សពួកនិយម ការបំពានអំណាច និងការផ្តល់កម្រៃក្រៅផ្លូវការ ព្រមទាំងអំពើផ្សេងៗទៀតដែលប៉ះពាល់ដល់ការងាររបស់អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងសំណង់ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាសាធារណៈរបស់ប្រជាពលរដ្ឋគ្រប់រូប។
- ពង្រឹងនូវការអនុវត្តច្បាប់ស្តីពីសំណង់ឱ្យប្រើ ឱ្យបានកាន់តែតឹងរឹងដើម្បីធានាឱ្យបាននូវការគ្រប់គ្រងសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាកាន់តែមានប្រសិទ្ធិភាព។
- ធានាឱ្យបាននូវការត្រួតពិនិត្យដំណើរការសាងសង់រាល់សំណង់ទាំងអស់ និងប្រកបដោយប្រសិទ្ធិភាព ក្នុងគោលដៅធានានូវគុណភាព និងសុវត្ថិភាពសំណង់ដើម្បីជៀសវាងការកើតមាននូវវិវាទ
- ផ្តល់នូវវគ្គបណ្តុះបណ្តាល ដើម្បីឱ្យសាធារណៈជនចូលរួមស្វែងយល់ និងយល់ដឹងអំពីការងារនានានៃវិស័យមួយនេះ ដោយអាចធ្វើឡើងលក្ខណៈការផ្សព្វផ្សាយជាសាធារណៈ ដោយផ្ទាល់និងតាមប្រព័ន្ធអេឡិចត្រូនិចផងដែរ។
- ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីការងារនៅក្នុងវិស័យសំណង់នេះ តាមគ្រប់មធ្យោបាយដើម្បីបង្កើននូវការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅព្រមទាំងអ្នកវិនិយោគ។

យើងខ្ញុំទាំងពីរសង្ឃឹមថា សំណូមពរទាំងប្រាំចំនុចខាងលើរបស់យើងខ្ញុំនឹងអាចជួយដល់ការងារគ្រប់គ្រងសំណង់នៅព្រះរាជាណាចក្រមកម្ពុជាកាន់តែប្រសើរឡើង និងកាន់តែមានប្រសិទ្ធភាព ដើម្បីឆ្លើយតបយ៉ាងទាន់ពេលស្របទៅនឹងការវិវឌ្ឍយ៉ាងខ្លាំងខ្លានៅពេលបច្ចុប្បន្ន និងនាពេលអនាគតលើវិស័យសំណង់នេះ។ យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថាយោបល់ខាងលើនឹងត្រូវបានយកទៅពិនិត្យ និងពិភាក្សាដោយអាជ្ញាធរពាក់ព័ន្ធផងដែរ៕

# ឯកសារយោង

# ឯកសារយោង

## វចនានុក្រម

- វចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត**

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ ស្តីពី សំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩
- តារាងពិនិត្យឯកសារ និងគម្រោងស្នើសុំលិខិតអនុញ្ញាតសាងសង់ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- សទ្ទានុក្រម នៃច្បាប់ស្តីពីសំណង់
- សទ្ទានុក្រម នៃក្រមរដ្ឋប្បវេណី
- សេចក្តីណែនាំ, លេខ ០០២ ដនស/សណន ស្តីអំពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០២០
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ, ២៥ មិថុនា ២០១៨
- ប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់
- សេចក្តីណែនាំ លេខ ០០២ ដនស/សណន ស្តីអំពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០២០

## សៀវភៅ និងគេហទំព័រផ្សេងៗ

- សៀវភៅ នីតិកាតព្វកិច្ច (ភាគទី ២), សាស្ត្រាចារ្យ **ញឹក ឧុទ្ធី**
- ក្រសួងដែនដីនគរូបនីយកម្ម និង សំណង់, *វិស័យសំណង់*, http://www.mlmupc.gov.kh/?page=detail&menu1=373&menu2=424&menu3=440&ctype=article&id=440&lg=kh

- ក្រសួងដែនដីនគរូបនីយកម្ម និង សំណង់, *របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែមករា ឆ្នាំ ២០២១ និងលើកទិសដៅការងារបន្ត*, https://docs.google.com/a/servingweb.com/viewer?url=http://mlmupc.gov.kh/items/MLMUPC_Report%2001-2021.pdf
- គេហទំព័រ https://www.atlantafed.org/regional-economy/econsouth/vol_10_no_2/econsouth-vol_10_no_2-building_a_better_world

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី ១ | ច្បាប់ |
| ឧបសម្ព័ន្ធទី ២ | លិខិតបទដ្ឋានគតិយុត្តិផ្សេងៗ |
| ឧបសម្ព័ន្ធទី ៣ | គំរូពាក្យស្នើសុំ និងកិច្ចសន្យាសំណាក់ |
| ឧបសម្ព័ន្ធទី ៤ | វិញ្ញាបនបត្រវិស័យសំណាក់ |

# ឧបសម្ព័ន្ធទី ១

# ក្រម

# ព្រហ្មទណ្ឌ

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

កុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែល

ល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣

## ទោស

## ជំពូកទី ១

## ប្រភេទនៃទោស

### ផ្នែកទី ១

### មូលទោស

**មាត្រា ៤៣.–** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.–** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.–** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬ បន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.–** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវ

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការប៉ះពាល់ដោយអចេតនាដល់ជីវិតមនុស្ស

**មាត្រា ២០៧.–** បទមនុស្សឃាតដោយអចេតនា

បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយ :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជា ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២០៨.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសចំពោះបទមនុស្សឃាតដោយអចេតនា :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៤

## ការបង្កឱ្យមានរបួសដោយអចេតនា

**មាត្រា ២៣៦.–** បទបង្កឱ្យមានរបួសដោយអចេតនា

បទល្មើសបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃដោយ :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជាដែលបង្កឱ្យមានអសមត្ថ-ភាពក្នុងការធ្វើការងារស្មើ ឬ លើសពី ៨ (ប្រាំបី) ថ្ងៃ ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

បទបង្កឱ្យមានរបួសដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៣៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៣៦ (បទបង្កឱ្យមានរបួសដោយអចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

# ក្រមរដ្ឋប្បវេណី

**មាត្រា ៧៤៣.-** ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

**មាត្រា ៧៤៤.-** សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

**មាត្រា ៧៤៥.-** អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្តាលមក ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

**មាត្រា ៧៥២.-** ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើង ដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

**មាត្រា ៧៥៣.-** ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះ មានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះ ត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ នៃការសាងសង់ ឬ ការគ្រប់គ្រង ។

**មាត្រា ៧៥៤.–** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.–** និយមន័យនៃការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.–** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ

# ច្បាប់
# ស្តីពី
# សំណង់

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤
## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ .-**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ .-**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ឧស្សាហកម្ម តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀតដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដាកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាននិងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

**មាត្រា១២ .-**

រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈនីមួយៗពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១៣ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤ .-**

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

**មាត្រា១៥ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលអាចប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យបាន ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ។

នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

**មាត្រា១៦ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៧ .-**

រាល់ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្តទៅតាមប្រភេទអាជីវកម្ម។

**មាត្រា១៨ .-**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិត្តបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៩ .-**

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។

កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង សំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈឬអ្នកប្រកបអាជីវកម្មនិងអតិថិជនរបស់ខ្លួន។

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥ .-**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧ .-**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ .-**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

## ជំពូកទី៩
## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

រាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០
## ការគ្រប់គ្រងការងារសាងសង់ឬរុះរើ

**មាត្រា៣៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬរុះរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬរុះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា៣៧ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

**មាត្រា៣៨ .-**

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩ .-**

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់របស់ខ្លួន។

**មាត្រា៤០ .-**

ម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់និងមានការឯកភាពពីម្ចាស់សំណង់។

បែបបទនិងនីតិវិធីនៃការផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤១ .-**

នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើត្រូវធ្វើរបាយការណ៍និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចនិងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

**មាត្រា៤២ .-**

ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ឬរុះរើ។

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

**មាត្រា៤៣ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារសាងសង់ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១

## ការប្រើប្រាស់សំណង់

**មាត្រា៤៤ .-**

ការប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់នោះ។

រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

**មាត្រា៤៥ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្តោះអាសន្នបាន ចំពោះសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា៤៦ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧ .-**

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់ក្នុងរយៈពេលរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២(ពីរ)ឆ្នាំម្តង។

បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្តង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យអនុវត្តការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៨ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ក្នុងករណីមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៤៩ .-**

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

ចំពោះអគារសហកម្មសិទ្ធិ ម្ចាស់នៃចំណែកឯកជនទាំងអស់ត្រូវទទួលបន្ទុករួមគ្នាលើរាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ស្របតាមសមាមាត្រទៅនឹងទំហំនៃចំណែកឯកជន។

**មាត្រា៥០ .-**

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី១២
## សំណង់ដែលមានសភាពគ្រោះថ្នាក់

**មាត្រា៥១ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៥២ .-**

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងតម្រូវឱ្យរុះរើសំណង់។

រាល់ការចំណាយក្នុងការបញ្ចៀសគ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា៥៣ .-**

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១៣
## សំណង់ដែលសាងសង់ឬរុះរើដោយគ្មានឬខុសពីលិខិតអនុញ្ញាត

**មាត្រា៥៤ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ឬរុះរើដែលគ្មានលិខិតអនុញ្ញាត ក្នុងករណីការសាងសង់ឬរុះរើនោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

**មាត្រា៥៥ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ឬរុះរើដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឱ្យម្ចាស់សំណង់កែតម្រូវឱ្យស្របតាមលិខិតអនុញ្ញាត។

**មាត្រា៥៦ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួលឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

## ជំពូកទី១៤
## អធិការកិច្ចសំណង់

**មាត្រា៥៧ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥៨ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសំណង់ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៩ .-**

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ចនិងសិទ្ធិដូចខាងក្រោមៈ

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ .-**

មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៦១ .-**

រាល់ប្រតិបត្តិការអធិការកិច្ចសំណង់ក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែងឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី១៥
## វិសមិតភាព

**មាត្រា៦២ .-**

មន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យនិង/ឬសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សាឬត្រួតពិនិត្យនិងបញ្ជាក់បានឡើយ។

**មាត្រា៦៣ .-**

មន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនអាចជាម្ចាស់សំណង់ ឬជាសហព័ន្ធ ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣(បី)ថ្នាក់ ឬញាតិពន្ធក្នុង៣(បី)ថ្នាក់របស់ម្ចាស់សំណង់ ឬជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។

**មាត្រា៦៤ .-**

ការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់របស់ខ្លួន។

**មាត្រា៦៥ .-**

ការបំពេញមុខងារជាអ្នកសាងសង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិង បញ្ជាក់លើការងារសាងសង់របស់ខ្លួន។

**មាត្រា៦៦ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី)ថ្នាក់របស់ម្ចាស់សំណង់បានឡើយ។

សមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែល មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានឡើយ។

## ជំពូកទី១៦

## កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៦៧ .-**

កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចខាង ក្រោម៖

- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យានិងកាលបរិច្ឆេទនិងរបៀបនៃការទូទាត់
- ការធានារបស់ភាគីនៃកិច្ចសន្យាចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌបច្ចេកទេសនិងលក្ខខណ្ឌសុវត្ថិភាពនៃការងារ
- លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬឧបករណ៍និងគ្រឿងចក្រសម្រាប់ បម្រើឱ្យការងារសាងសង់ឬរុះរើនិងសម្រាប់បំពាក់លើសំណង់
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងឬបញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើង ដោយការងារ
- ការអះអាងអំពីអនុលោមភាពនៃគម្រោងប្លង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ តាមមុខមុខញ្ញត្តិជាធរមាន
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់ការងារនិងកាលបរិច្ឆេទប្រគល់ទទួល

- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

**មាត្រា៦៨ .-**

ចំពោះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន ខដែលរំលោភបំពានត្រូវទុកជាមោឃៈ។

ខដែលរំលោភបំពាននៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន មានដូចខាងក្រោម៖

១- ខដែលតម្រូវឱ្យម្ចាស់សំណង់ផ្តល់អាណត្តិឱ្យអ្នកម៉ៅការស្វែងរកកម្ចីចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់។

២- ខដែលតម្រូវឱ្យម្ចាស់សំណង់ធ្វើការទូទាត់តម្លៃនៃកិច្ចសន្យាទាំងស្រុងជាមុនដើម្បីឱ្យអ្នកម៉ៅការប្រគល់សំណង់មកម្ចាស់សំណង់។

៣- ខដែលហាមឃាត់ម្ចាស់សំណង់ឬតំណាងមិនឱ្យចូលពិនិត្យក្នុងការដ្ឋាន មុនការទូទាត់តម្លៃនៃកិច្ចសន្យាក្នុងដំណាក់កាលនីមួយៗនិងមុនការប្រគល់ទទួល។

៤- ខដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តការងារសាងសង់ឬរុះរើ តាមលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ដែលលក្ខខណ្ឌបច្ចេកទេសមានការប្រែប្រួលធ្ងន់ធ្ងរខុសពីលក្ខខណ្ឌបច្ចេកទេសនៃគម្រោងសាងសង់ ជួសជុល ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យា។

៥- ខដែលដោះបន្ទុកអ្នកម៉ៅការពីកាតព្វកិច្ចអនុវត្តការងារពេញលេញតាមពេលកំណត់ក្នុងកិច្ចសន្យាដោយទទួលស្គាល់មូលហេតុនៃការយឺតយ៉ាវផ្សេងៗ លើកលែងតែមូលហេតុប្រធានសក្តិនិងមូលហេតុដែលបង្កដោយម្ចាស់សំណង់ផ្ទាល់។

**មាត្រា៦៩ .-**

ភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ចឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដូចខាងក្រោម៖

១- លទ្ធកម្មដីឬសិទ្ធិប្រត្យក្សដែលអនុញ្ញាតឱ្យសាងសង់ ក្នុងករណីដែលម្ចាស់សំណង់ទទួលបានការសន្យាលក់។

២- ការទទួលបានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ឬការអនុញ្ញាតផ្សេងទៀតរបស់អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវបញ្ជាក់កាលបរិច្ឆេទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យបានច្បាស់លាស់។

៣- ការទទួលបានកម្ចីដើម្បីធ្វើហិរញ្ញប្បទានដល់ការងារសាងសង់ឬរុះរើ។

៤- ការទទួលបាននូវការធានារ៉ាប់រងចំពោះការខូចខាតបង្កដោយការងារសាងសង់ឬរុះរើ។

៥- ការទទួលបាននូវការធានាការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ការដ្ឋានសំណង់។

**មាត្រា៧០ .-**

ករណីយកិច្ចសម្រេចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឃ្ស្រះរើដោយគ្មានវិការៈមានដូចខាងក្រោម៖

១- ការងារសាងសង់ត្រូវបានអនុវត្តស្របតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងសេចក្តីណែនាំជាធរមានដទៃទៀត។

២- ការងារសាងសង់ត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រសមស្របនិងប្រកបដោយសមត្ថភាពជំនាញ។

៣- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវសមស្របតាមមុខងារប្រើប្រាស់អនុលោមតាមគម្រោងប្លង់និងមានគុណភាពត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេស។

៤- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវតែជាសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ថ្មី លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា។

**មាត្រា៧១ .-**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងផ្គុំសំណង់ធ្វើពីបេតុងសរសៃដែក បេតុងដែក ឬដែក។

ខ- ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ- ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

គូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់អាចព្រមព្រៀងគ្នាកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារវែងជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

ការកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារខ្លីជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវចាត់ទុកជាមោឃៈ។

## ជំពូកទី១៧

## ការធានារ៉ាប់រង

**មាត្រា៧២ .-**

អ្នកម៉ៅការសាងសង់ឃ្ស្រះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឃ្ស្រះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឃ្ស្រះរើ ដើម្បីផ្តល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារនិងតតិយជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។

**មាត្រា៧៣ ._**

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរុះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្ដប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរុះរើបន្តទាំងអស់។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។

**មាត្រា៧៤ ._**

ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរុះរើរបស់គម្រោងអភិវឌ្ឍអចលនវត្ថុ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។

**មាត្រា៧៥ ._**

ប្រភេទនិងទំហំសំណង់ដែលតម្រូវឱ្យមានការធានារ៉ាប់រងចំពោះការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៨
## ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

**មាត្រា៧៦ ._**

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

**មាត្រា៧៧ ._**

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរុះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។

**មាត្រា៧៨ ._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន។

**មាត្រា៧៩ ._**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

**មាត្រា៨០ .-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើៈ

- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ
- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូតខាតបានកើតឡើង។

**មាត្រា៨១ .-**

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោមៈ

១- នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។

២- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

**មាត្រា៨២ .-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើៈ

១- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី១៩
## ការដោះស្រាយវិវាទក្នុងវិស័យសំណង់
## ផ្នែកទី១
## ការប្ដឹងតវ៉ាក្នុងវិស័យសំណង់

**មាត្រា៨៣ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្ដីសម្រេចនោះ ឬទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្ដឹងត្រូវចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្ដឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបណ្ដឹង មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាមានសិទ្ធិប្ដឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៤ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន មុននឹងប្ដឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

**មាត្រា៨៥ .-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬអាចប្ដឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្ដឹងតវ៉ា។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ផ្នែកទី២
## ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៨៦ .-**

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការ។

សំណើសុំសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់សម្រេចបដិសេធសំណើសុំសម្រុះសម្រួល គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួលក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៧ .-**

ភាគីឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះរើអាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរះរើនោះ។

សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលវិវាទបានកើតឡើង។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយគូភាគីនៃវិវាទនិងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។

ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដោះស្រាយវិវាទសំណង់អំពីការឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ មុននឹងប្តឹងទៅតុលាការ។

**មាត្រា៨៨ .-**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីមានសំណើសុំសម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។

**មាត្រា៨៩ .-**

គណៈកម្មការដោះស្រាយវិវាទសំណង់មានរចនាសម្ព័ន្ធដូចតទៅៈ

១- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី២០
## ទោសប្បញ្ញត្តិ

**មាត្រា៩០ .-**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់និងទោសដាក់ពន្ធនាគារ។

**មាត្រា៩១ .-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩២ .-**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យសំណង់។

**មាត្រា៩៣ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៤ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៥ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យដោយគ្មានអាជ្ញាបណ្ណ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៦ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៧ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៣(បី)ខែ និងពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទីពីររបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

**មាត្រា៩៨ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលបានប្រើឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដាណាមួយជាក់លាក់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៩ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០០ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសាងសង់ដែលបានសាងសង់ឬរះរើមិនអនុលោមតាមគម្រោងប្លង់និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០១ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៣០ ០០០ ០០០(សាមសិបលាន)រៀលទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលបានបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់ឬរះរើថាត្រឹមត្រូវ ដែលតាមជាក់ស្តែង គម្រោងប្លង់ឬការងារសាងសង់ឬរះរើនោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០២ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០៣ .-**

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានការកាត់អវយវៈឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានមនុស្សស្លាប់។

**មាត្រា១០៤ ._**

ត្រូវផ្តន្ទាទោសដូចមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់នេះ កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់។

**មាត្រា១០៥ ._**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀលទៅ៨០ ០០០ ០០០(ប៉ែតសិបលាន) រៀល ចំពោះនីតិបុគ្គលណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានអាជ្ញាបណ្ណ។

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុង មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ ០០០ ០០០(ហុកសិបលាន)រៀលទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី២១

## អន្តរប្បញ្ញត្តិ

**មាត្រា១០៦ ._**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ម្ចាស់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ត្រូវមកដាក់ពាក្យស្នើសុំ

វិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងរយៈពេលកំណត់ខាងលើ រាល់ទោសប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបន្តអនុវត្តចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន។

**មាត្រា១០៧.-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០៨.-**

ក្រោយច្បាប់នេះចូលជាធរមានក្នុងរយៈពេល២(ពីរ)ឆ្នាំ មន្ទីរពិសោធន៍សំណង់ដែលបាននិងកំពុងប្រតិបត្តិការឬប្រកបអាជីវកម្មត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៩.-**

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចដកយកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាពឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។

អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

លក្ខខណ្ឌនិងនីតិវិធីនៃការតម្កល់ប្រាក់ ការដកប្រាក់តម្កល់ និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ទៅតាមប្រភេទនៃអាជ្ញាបណ្ណដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសំណង់

## សទ្ទានុក្រម

១. **ការងារសំណង់**(construction work) សំដៅដល់ការងារសិក្សាគម្រោងប្លង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២. **ការងារសិក្សាគម្រោងប្លង់**(design work) សំដៅដល់ការងារគូរប្លង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្តីណែនាំបច្ចេកទេស និងការងារគូរប្លង់លម្អិត។

៣. **ការងារវាស់វែង**(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើប៉ាន់លេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្លង់ និងការងារសាងសង់។

៤. **ការងារសាងសង់**(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការដំឡើង។

៥. **ការងារជួសជុល**(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៦. **ការងារកែប្រែ**(modification work) សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៧. **ការងាររុះរើ**(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

៨. **ការងារត្រួតពិនិត្យនិងបញ្ជាក់**(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

៩. **ការងារសិក្សាពិសោធ**(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

១០. **ការងារគ្រប់គ្រងគម្រោងសាងសង់**(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រង គម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

១១. **ការដកហូត**(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ដោយអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ច។

១២. **កិច្ចសន្យាម៉ៅការសាងសង់**(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ឬរុះរើបន្តដើម្បីអនុវត្តការងារសាងសង់ឬរុះរើ។

១៣. **គម្រោងប្លង់**(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្តីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ឬរុះរើនិងការប្រើប្រាស់សំណង់។

១៤. **តម្លៃនៃកិច្ចសន្យា**(contract fee) សំដៅដល់កម្រៃឬតម្លៃថ្នូរដទៃទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

១៥. **ប្រធានសក្តិ**(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

១៦. **បទប្បញ្ញត្តិបច្ចេកទេសសំណង់**(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេស លក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ញា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

១៧. **បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម**(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

១៨. **បន្ទុក**(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

១៩. **បរិក្ខារសំណង់**(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡារ៉ាបូ រ៉ូប៊ីណេ ជើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត ទុយោ។

២០. **ផលិតផលសំណង់**(construction product) សំដៅដល់ផលិតផលសម្រេចឬពាក់កណ្តាលសម្រេចដែលកើតចេញពីការបង្កើតឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្នាងសិលា ស័ង្កសី ស្វាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតការ៉ូ។

២១. **ផលិតករ**(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករឬជាអ្នកលក់។

២២- **ម្ចាស់សំណង់**(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួល អចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

២៣- **មន្ត្រីត្រួតពិនិត្យសំណង់**(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំង ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាព សំណង់។

២៤- **វិការៈ**(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

២៥- **វិញ្ញាបនបត្រប្រើប្រាស់សំណង់**(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមាន សមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

២៦- **សំណង់ដែលមានសភាពគ្រោះថ្នាក់**(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬ សម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

២៧- **សំណង់**(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការ ទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារ សំណង់ ឬផលិតផលសំណង់។

២៨- **សម្ភារៈសំណង់**(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើ ប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

២៩- **អ្នកសាងសង់**(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬ ក្រុមជាងសំណង់។

៣០- **អ្នកអភិវឌ្ឍអចលនវត្ថុ**(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែល ប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

៣១- **អាជ្ញាធរមានសមត្ថកិច្ច**(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣២- **អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបាន ចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

៣៣- **អ្នកជំនាញក្នុងវិស័យសំណង់**(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្តុះបណ្តាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធ ក្នុងការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤. **អ្នកគ្រប់គ្រងសំណង់**(building manager) សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។

# ឧបសម្ព័ន្ធទី ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០០៤ ដនស/សណន

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំសំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីសំណង់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ហាមដាច់ខាតការសាងសង់សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។
- ហាមដាច់ខាតការអនុវត្តការងារសាងសង់ឬរុះរើ ដោយអ្នកសាងសង់ដែលគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ហាមដាច់ខាតការដ្ឋានសំណង់ដែលដំណើរការសាងសង់ឬរុះរើដោយគ្មានវិស្វករប្រចាំការដ្ឋានជាអ្នកទទួលខុសត្រូវ។
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ ទោះបីជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសំណង់។
- ហាមការប្រើប្រាស់សំណង់គ្រប់ប្រភេទ ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬលិខិតបិទការដ្ឋានផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីពិនិត្យឃើញអំពើល្មើសនឹងបម្រាមខាងលើ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញលិខិតផ្អាកការសាងសង់ជាបន្ទាន់។ ក្នុងករណីការសាងសង់នៅតែបន្ត អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីជាធរមាន។

ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៃការដ្ឋានសំណង់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវយកចិត្តទុកដាក់អនុវត្តគោលការណ៍និងវិធានការដូចខាងក្រោម៖

**១) លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ**

អាសយដ្ឋាន៖ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាស្ថាបត្យករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់វិស្វកម្មត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីគម្រោងប្លង់អនុញ្ញាត មិនត្រូវបានអនុញ្ញាតឡើយក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

**២) លិខិតអនុញ្ញាតបើកការដ្ឋានសំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវមានបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វករប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។

**៣) ការរៀបចំការដ្ឋាន**

- មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះវាស់វែងនិងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។
- ការដ្ឋានសំណង់ត្រូវមានផ្ទាំងព័ត៌មានអំពីគម្រោងសាងសង់នៅពីមុខការដ្ឋានសំណង់ ជាអាទិ៍ ឈ្មោះគម្រោងសាងសង់ ឈ្មោះក្រុមហ៊ុនសាងសង់ ឈ្មោះមេក្រុមជាង ឈ្មោះម្ចាស់សំណង់ ឈ្មោះរបស់វិស្វករប្រចាំការដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រូបភាពនេត្រាទស្សន៍នៃគម្រោងសាងសង់ និងអាសយដ្ឋានទីតាំងសំណង់។
- ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមវិធានសុវត្ថិភាពដូចមានកំណត់ក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ (ឆ្នាំ២០១៨) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ៤) ដំណើរការការដ្ឋានសំណង់

- មានតែក្រុមហ៊ុនសាងសង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចទទួលម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារមួយផ្នែកឬច្រើនទៅឱ្យក្រុមជាងសំណង់។ ក្នុងករណីនេះ ក្រុមជាងសំណង់ត្រូវអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។
- ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចទទួលម៉ៅការសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ ការងាររបស់ក្រុមជាងសំណង់ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច ០១ (មួយ) រូប ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។
- គ្រប់ការដ្ឋានសំណង់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ឬរះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។
- ក្រុមហ៊ុនសាងសង់ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោម÷
    - ក្នុងពេលកំណត់ទីតាំងសាងសង់
    - ក្នុងពេលអនុវត្តការងារគ្រឹះ
    - ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
    - ក្នុងពេលអនុវត្តការងារគ្រឿងផ្គុំបន្តបន្ទាប់ទៀត។
- នៅរាល់ពេលចុះត្រួតពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និងវិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធ។
- ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់ឬរុះរើមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ គម្រោងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាតហើយ និងបទប្បញ្ញត្តិជាធរមានដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើឬវិធានការចាំបាច់ផ្សេងទៀត។

- អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចងក្រងនិងរក្សារាល់កំណត់ហេតុ របាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយៗ ទាំងជាឯកសាររឹងនិងទាំងជាឯកសារអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។

**៥) ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់និងការងារសាងសង់ ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ ដែលជាក្រុមហ៊ុនសិក្សាគម្រោងប្លង់ឬក្រុមហ៊ុនសាងសង់ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង។
- ការត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តដាច់ខាតលើគម្រោងប្លង់ផ្នែកគ្រឹះ ជើងតាង សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាលសំខាន់ៗនៃការងារគ្រឿងផ្គុំ ជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។
- វិញ្ញាបនបត្រត្រួតពិនិត្យនិងបញ្ជាក់សំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ គឺជាឯកសារដែលអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់ក្នុងការសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលមានតម្លៃសម្រាប់ការចូលប្រើប្រាស់ ការដាក់ជួល ការលក់ ឬប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតពាក់ព័ន្ធនឹងសំណង់។
- ក្នុងករណីពិនិត្យឃើញការងារសាងសង់មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចាត់វិធានការសមស្រប។

ទទួលបានសេចក្តីណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  “**ដើម្បីជូនជ្រាប**”
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០០៥ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- យោងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**ប្រការ ១** : ចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម៖

**១. មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆេព ឆន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ឡៅ ឋិពួសីហា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **លាង មុនីរិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម **ឌុច វនធីតូ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥. ឯកឧត្តម **ធា ច័ន្ទលីដា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦. ឯកឧត្តម **កើត សារ៉ែត** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧. ឯកឧត្តម **ប៊ិន សម្បត្តិថារ័ត្ន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨. ឯកឧត្តម **លី វណ្ណាសូត្រ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩. ឯកឧត្តម **ខ្លូត រតនា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០. លោកជំទាវ **សេរី សូរិយា** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ១១. ឯកឧត្តម **សេង ឡូត** | អគ្គនាយករដ្ឋបាល | សមាជិក |
| ១២. ឯកឧត្តម **ឆាយ ឫទ្ធិសែន** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ១៣. ឯកឧត្តម **ឡោ ជាវុធ** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ១៤. ឯកឧត្តម **បេងហុង សុជាតិខេមរ៉ូ** | អគ្គនាយកលំនៅឋាន | សមាជិក |
| ១៥. ឯកឧត្តម **ឆាន់ សូរ្យផល** | អគ្គនាយកសំណង់ | សមាជិកអចិន្ត្រៃយ៍ |
| ១៦. លោក **អ៊ុត សំអាន** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៧. លោក **អេ ប៊ុនធឿន** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |

**២. មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត**

**ក. ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ**

| | | |
|---|---|---|
| ១. ឯកឧត្តម **កើត សារ៉ែត** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **សាយ និដ្ឋា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **ជា ផលរី** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ផល សុភ័ណ** | អនុប្រធានមន្ទីរពិសោធន៍ | សមាជិក |
| ៥. លោក **ចាន់ ភ្នកអួន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ហ៊ុន សត្យា** | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក **ដួង ស៊ីវុធ** | អនុប្រធានការិយាល័យ | សមាជិក |

| | | |
|---|---|---|
| ៨. លោក **កែវ ដារ៉ែន** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **ហ៊ី ចន្ថា** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **ហុង ស្រ៊ុន** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **ចាន់ ធម្ម** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ឈឹង សុគន្ធា** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **ឥន ធវី** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤. លោក **ផាត់ បូរី** | មន្ត្រី | សមាជិក |
| ១៥. លោក **នៀម ប្រាក់តូ** | មន្ត្រី | សមាជិក |
| ១៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**ខ.ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង**

| | | |
|---|---|---|
| ១. ឯកឧត្តម **លាង មុនីរិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ហាក់ ប៊ុណ្ណាក់** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **នេង វ៉ាន់ថា** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ម៉ាឃ ពន្លក** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ប៊ុល ថាវ័ន្ត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ប៊ុន ធារមី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **យ៉េង សុបញ្ញា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨. លោក **ហេង សុតា** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **ម៉ិល រ៉ានី** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **រ៉េន កែវខ្មៅ** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **សួរ សាមី** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ហេង ហាក់** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **ខួន សុខវិសាល** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤. លោក **អ៊ុំ ខួនសុខ** | មន្ត្រី | សមាជិក |
| ១៥. លោក **ម៉ាច ហ៊ឺ** | មន្ត្រី | សមាជិក |
| ១៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**គ.រាជធានីភ្នំពេញ**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឌុច វនធីតូ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **អ៊ឹម ចំរុង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម **ម៉ម សុផាណា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៤. ឯកឧត្តម **ម៉ិញ សំអឿន** | ទីប្រឹក្សាក្រសួង | សមាជិក |
| ៥. លោក **ឆាន់ សុជាតិ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ម៉ីប៉ុក ពន្លឺ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **ឈុត សៅ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨. លោក **យី ទុត្ថា** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **គង់ សុគន្ធា** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **កែវ វណ្ណារិន** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **តាំង ប៊ុណ្ណារិទ្ធ** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ថន វិទ្យា** | មន្ត្រី | សមាជិក |
| ១៣. លោក **តាំង វីណា** | មន្ត្រី | សមាជិក |
| ១៤. លោក **ខួន សុភបុណ្ណមី** | មន្ត្រី | សមាជិក |
| ១៥. លោក **ពៅ បណ្ឌុល** | មន្ត្រី | សមាជិក |
| ១៦. លោក **សៅ សារពត្តម** | មន្ត្រី | សមាជិក |
| ១៧. លោក **ថាច់ មនោរក្ស** | មន្ត្រី | សមាជិក |
| ១៨. លោក **ខឹម ពិសី** | មន្ត្រី | សមាជិក |
| ១៩. លោក **ច្រាក់ សុផល** | មន្ត្រី | សមាជិក |
| ២០. លោក **ពៅ សុខនី** | មន្ត្រី | សមាជិក |
| ២១. លោក **រឹម រាជ** | កម្មសិក្សាការី | សមាជិក |
| ២២. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | | សមាជិកអចិន្ត្រៃយ៍ |
| ២៣. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខណ្ឌគោលដៅ | | លេខាធិការ |

**ឃ. ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆា ច័ន្ទលីដា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ញ៉ូន ស៊ី** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **រ័ត្ន ពិសិដ្ឋ** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ចាប់ ច័ន្ទថេរា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **សេក ច័ន្ទមុន្នី** | អនុប្រធានការិយាល័យ | សមាជិក |
| ៦. លោក **គីម សុគន្ធា** | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក **សាន សុតី** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **មាស ថន** | អនុប្រធានការិយាល័យ | សមាជិក |

| | | |
|---|---|---|
| ៩. លោក **សួន ឌី** | មន្ត្រី | សមាជិក |
| ១០. លោក **ធិ គុណវិចិត្រ** | មន្ត្រី | សមាជិក |
| ១១. លោក **គិត នាគសែន** | មន្ត្រី | សមាជិក |
| ១២. លោក **ភាំង កោសល្យ** | មន្ត្រី | សមាជិក |
| ១៣. លោក **គង់ ចាន់ថន** | មន្ត្រី | សមាជិក |
| ១៤. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៥. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**ង. ខេត្តព្រះសីហនុ**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឡៅ ធិពូសីហា** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **យស់ ឆោមណារ៉ាឌី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ហងៀ សុគសំភារ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤. លោក **លី រស្មី** | អគ្គនាយករង | សមាជិក |
| ៥. លោក **ម៉ៅ គ្រឹង** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **លឹម ម៉ូ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **ឃួន សេរី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨. លោក **ឃួន ចាន់** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **តោគ សេរីវុធ** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **វ៉ុយ ថា** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **សាន ស៊ីវត្ថា** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **អន ស៊ីថន** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **នូ សុផុន** | មន្ត្រី | សមាជិក |
| ១៤. លោក **ម៉ុយ ម៉ាច** | មន្ត្រី | សមាជិក |
| ១៥. លោក **មិន សាមេន** | មន្ត្រី | សមាជិក |
| ១៦. លោក **ទូច ហួសេង** | មន្ត្រី | សមាជិក |
| ១៧. លោក **ដែក ជឿន** | មន្ត្រី | សមាជិក |
| ១៨. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ | | សមាជិកអចិន្ត្រៃយ៍ |
| ១៩. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**ច. ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន**

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ិន សម្បត្តិថារ័ត្ន** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ហ៊ុយ ណារ៉ា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម **ជា ស្រ៊ុន** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៤. លោក **ជា សំអាត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ឡេង សេដ្ឋា** | អនុប្រធានការិយាល័យ | សមាជិក |
| ៦. លោក **ម៉ុន សីហាមានី** | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក **សុក ធី** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **តូច សុផាន់ណារ៉ាក់** | មន្ត្រី | សមាជិក |
| ៩. លោក **ទើ សុថា** | មន្ត្រី | សមាជិក |
| ១០. លោក **ម៉ូច រ៉ូណាល់** | មន្ត្រី | សមាជិក |
| ១១. លោក **នី សុបញ្ញា** | មន្ត្រី | សមាជិក |
| ១២. លោក **លី សុវណ្ណា** | មន្ត្រី | សមាជិក |
| ១៣. លោក **រស់ សារ៉ាក់មុនី** | មន្ត្រី | សមាជិក |
| ១៤. លោក **ម៉ុម ថារ៉ូ** | មន្ត្រី | សមាជិក |
| ១៥. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៦. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**ឆ. ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី**

| | | |
|---|---|---|
| ១. ឯកឧត្តម **លី វណ្ណាសូត្រ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. លោក **សារេត បូរាមី** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ឃី យ៉ាណារតន៍** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ញ៉ូ ហេង** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **អ៊ុំ សារុំ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ដួរ ជិនសុធា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **មុខ ថារិទ្ធ** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **ជាង ផល្លាយ** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **សិទ្ធ សុភា** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **ហោ ផាន់នី** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **អ៊ុំ ម៉ុនថន** | មន្ត្រី | សមាជិក |
| ១២. លោក **យក់ សំណាង** | មន្ត្រី | សមាជិក |
| ១៣. លោក **អី ឆវីរ៉ា** | មន្ត្រី | សមាជិក |
| ១៤. លោក **ឃុន សុធី** | មន្ត្រី | សមាជិក |
| ១៥. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៦. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

១៣.លោក **ជៀវ សេដ្ឋី** មន្ត្រី សមាជិក

១៤.ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ សមាជិកអចិន្ត្រៃយ៍

១៥.ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ លេខាធិការ

**ប្រការ ២** : មន្ត្រីត្រួតពិនិត្យសំណង់នេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

**១.មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម**

- ដឹកនាំកំណត់ទិសដៅអនុវត្តដល់មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត បន្ទាប់ពីទទួលបានគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង
- តាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត
- ធ្វើរបាយការណ៍គោរពស្នើសុំការពិនិត្យ និងសម្រេចពីថ្នាក់ដឹកនាំក្រសួងលើការផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឱ្យរុះរើ និងចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណីការងារសាងសង់ ឬរុះរើ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួង
- បំពេញការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**២.មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត**

- ពិនិត្យ និងផ្តល់យោបល់ទាំងលើទិដ្ឋភាពច្បាប់និងបច្ចេកទេសលើគម្រោងសាងសង់ និងតាមដានត្រួតពិនិត្យការសាងសង់
- ចុះត្រួតពិនិត្យ និងបោះបង្គោលព្រំកំណត់ទីតាំងស្នើសុំសាងសង់ ឬរុះរើ
- ចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេចលើការផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឱ្យរុះរើ ចាត់វិធានការចាំបាច់ផ្សេងទៀត ឬលើកសំណើសុំធ្វើអធិការកិច្ចសំណង់ ក្នុងករណីរកឃើញថាការងារសាងសង់ ឬរុះរើ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលដៅ ដើម្បីចុះតាមដាន និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិនគរូបនីយកម្មចំពោះគម្រោងសាងសង់រហូតដល់បញ្ចប់ការដ្ឋាន
- ប្រមូលនិងចងក្រងទិន្នន័យ និងធ្វើរបាយការណ៍តាមការដ្ឋាននីមួយៗ ដែលបានចុះត្រួតពិនិត្យបោះបង្គោលព្រំកំណត់ទីតាំងស្នើសុំសាងសង់ ឬរុះរើ
- បំពេញការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**ជ. ខេត្តតាកែវ ខេត្តកែប ខេត្តកំពត និងខេត្តកោះកុង**

| | | |
|---|---|---|
| ១. ឯកឧត្តម **ខ្លូត រតនា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. លោក **លឹម អ៊ីវ** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ឈឹម សុគន្ធ** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **តាន់ហ៊ាង ហានីដា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ជិន ឡេវិប** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **អ៊ិច រដ្ឋា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **អ៊ុំ សុពុត្រា** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **ម៉ែន បូរ៉ាត** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **យិន គីមហុង** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **ស៊ាង គីមលាង** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **ខៀវ ចិត្រា** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ម៉ូច ច័ន្ទម៉ារ៉ា** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **ម៉េង អាន** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤. លោក **យន់ លីហួរ** | មន្ត្រី | សមាជិក |
| ១៥. លោក **លី លីណា** | មន្ត្រី | សមាជិក |
| ១៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**ឈ. ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ**

| | | |
|---|---|---|
| ១. លោកជំទាវ **សេរី សូរិយា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ជី ស៊ីថា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **ង៉ាក់ ចាន់ផល** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ខ្វិ ទឡ្ហន:** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **អ៊ុំច ណារ៉េត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **អ៊ុំ បូរិទ្ធ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **សេក ច័ន្ទមុនី** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **ញៀម ចាន់តារ៉ា** | មន្ត្រី | សមាជិក |
| ៩. លោក **កៅ ទ្រូក** | មន្ត្រី | សមាជិក |
| ១០. លោក **នង ម៉ាយូរ៉ា** | មន្ត្រី | សមាជិក |
| ១១. លោក **ឡូន សម្ផស្ស** | មន្ត្រី | សមាជិក |
| ១២. លោក **ឃាង វិច្ឆរ:** | មន្ត្រី | សមាជិក |

**ប្រការ ៣** : មន្ត្រីត្រួតពិនិត្យសំណង់នេះអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ឱ្យជួយបំពេញភារកិច្ចតាមការចាំបាច់។

**ប្រការ ៤** : សេចក្ដីសម្រេចលេខ ០២០ សសរ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៩ ស្ដីពីការបង្កើតក្រុមការងារចុះពិនិត្យតាមដានការដ្ឋានសំណង់ និងចុះដោះស្រាយវិវាទសំណង់, សេចក្ដីសម្រេចលេខ ០៩១ សសរ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៨ ស្ដីពីការកែសម្រួលក្រុមការងារចុះពិនិត្យទីតាំងស្នើសុំសាងសង់ និងចុះបោះបង្គោលព្រំកំណត់ទីតាំងសាងសង់អគារនៅតាមភូមិសាស្ត្ររាជធានីខេត្ត, សេចក្ដីសម្រេចលេខ ០៦៧ សសរ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០១៨ ស្ដីពីការបង្កើតក្រុមការងារចំពោះកិច្ចចុះតាមដាន និងត្រួតពិនិត្យការដ្ឋានសំណង់ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥** : នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងសាមីខ្លួន ដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ឆ្លុង

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល** ÷

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

(២៦១)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ៣២ ប្រ.ក/សណ.

២១.៦.០១

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងការដ្ឋានសំណង់

រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ ០៤ /នស /៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ /បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៨៦ / អនក្រ / បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ / បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានីភ្នំពេញ និង ខេត្ត ក្រុង
- បានឃើញប្រកាស លេខ ៧៥ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់
- បានឃើញប្រកាស លេខ ៧៦ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទី ភារកិច្ចរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- ផ្អែកលើសភាពការណ៍នៃស្ថានភាពសំណង់បច្ចុប្បន្ន ។

សម្រេច

៥៤១(៥៦២)

ប្រកាសនេះ មានគោលបំណងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ និង សុវត្ថិភាព ក្នុងការដ្ឋានសំណង់ ព្រមទាំងពង្រឹងការអនុវត្តបទប្បញ្ញត្តិនានាដែលទាក់ទងនឹងការសាងសង់សំដៅបង្កើនគុណភាព និង សោភ័ណភាព ។

ប្រការ ២.-

អាចអនុញ្ញាតឱ្យបើកការដ្ឋានដំណើរការបានចំពោះតែសំណង់ណាដែល សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងម៉ៅការសាងសង់ មានលិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ចេញឱ្យដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ។

ប្រការ ៣.-

ការដ្ឋានទីមួយៗ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។

លិខិតអនុញ្ញាតបើកការដ្ឋានត្រូវសុំនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ក្នុងរយៈពេលមួយខែយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ។

សំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានមាន ៖

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតសាងសង់

៣-កិច្ចសន្យារវាងម្ចាស់សំណង់ និង សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងម៉ៅការសាងសង់

៤-លិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ របស់សហគ្រាស ក្រុមហ៊ុន ឬក្រុមជាងម៉ៅការសាងសង់ ដែលទទួលសំណង់នោះ ។

ប្រការ ៤.-

ការដ្ឋានសំណង់នីមួយៗត្រូវ ៖

-តំកល់ជាប្រចាំ លិខិតបើកការដ្ឋាន . គំនូរប្លង់តាមមុខជំនាញការងារសំណង់ . ផែនការអនុវត្តការងារក្នុងដំណាក់កាលនីមួយៗនៃការសាងសង់ . និង ឯកសារ ពាក់ព័ន្ធ ទុកសម្រាប់ភ្នាក់ងារសំណង់តាមដានត្រួតពិនិត្យ

-មានអ្នកបច្ចេកទេសសំណង់សម្រាប់ទទួលខុសត្រូវក្នុងការងារសាងសង់ ហើយមានកាតព្វកិច្ចឆ្លើយបំភ្លឺ ផ្តល់ព័ត៌មានជូនដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ

-ដាក់ផ្ទាំងគំនូរសំណង់ ដែលមានឈ្មោះសំណង់ នៃអគារត្រូវសាងសង់ . ក្រុមហ៊ុនសំណង់ . ម្ចាស់សំណង់ . ស្ថាបត្យករ . វិស្វករ . ថ្ងៃក្រឡាសំណង់ . លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានតាំងនៅ

-មានភ្លើងដើម្បីបំភ្លឺ និង ត្រូវមានប្រដាប់សម្រាប់ពន្លត់អគ្គិភ័យជាប្រចាំ

-បន្ថយការរំខានដោយសូរសំលេង ផ្សែង ធូលី និង ផលប៉ះពាល់ដទៃទៀត ឱ្យស្ថិតនៅក្នុងកំរិត និង ពេល

វេលាមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន ។

ប្រការ ៥.-

ការដ្ឋានទីមួយៗ ត្រូវហ៊ុមព័ទ្ធដោយរបងមានកម្ពស់ ២ម៉ែត្រ យ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឱ្យធ្វើលើចិញ្ចើមថ្នល់ ។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមថ្នល់សាធារណៈ ត្រូវរក្សាឱ្យមានចន្លោះផ្លូវដើរលើចិញ្ចើមថ្នល់ និង ធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬ កំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី ៥ម៉ែត្រឡើងទៅ ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព ។

ប្រការ ៦.-

ការដ្ឋានត្រូវមានសណ្តាប់ធ្នាប់ និង អនាម័យ ជាប្រចាំ តាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់ពេលបញ្ចប់ការដ្ឋាន ។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការ រៀបចំសណ្តាប់ធ្នាប់ និង អនាម័យដែលបណ្តាលមកពីការទុកដាក់សម្ភារៈ ឬ ភាគសំណល់ឱ្យប៉ះពាល់ផ្លូវសាធារណៈ ឬ ហូរធ្លាក់ចូលក្នុងអាងត្រួតពិនិត្យ នៃបណ្តាលូ និង ប្រឡាយទឹក ។

ប្រការ ៧.-

ការិយាល័យការងារ ឃ្លាំងផ្ទុកសម្ភារៈ ជម្រកកម្មករ គ្រឿងចក្រ និង សកម្មភាពសាងសង់ត្រូវរៀបចំ និងប្រព្រឹត្តទៅនៅក្នុងរបងហ៊ុមព័ទ្ធនៃការដ្ឋាន ឬ ការដ្ឋានរណប ឬទីកន្លែងដែលធានាបានសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ប្រការ ៨.-

ចំពោះសំណង់ដែលត្រូវប្រើគ្រឿងចក្របរិក្ខារលើកស្ទូច ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវ :

-សុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងផ្គុំសំណង់ ហើយធ្វើផ្លូវវាងជាបណ្តោះអាសន្ន

-បំពាក់ភ្លើងសញ្ញាសម្គាល់ លើផ្លូវដែលបិទ ដើម្បីសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈនៅពេលយប់ ។

ប្រការ ៩.-

ក្នុងករណីការសាងសង់មានបុគ្គលសរគ្រោះ ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវ :

-មានកាតព្វកិច្ចអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ដែលមានសមត្ថកិច្ចចូលពិនិត្យក្នុងការដ្ឋាន

-ជៀសវាងការប៉ះពាល់ដល់គ្រឿងផ្គុំផ្នែកក្រោមដី

-ធានាសុវត្ថិភាពអគារដែលស្ថិតនៅជុំវិញបរិវេណការដ្ឋាន

-រៀបចំសណ្តាប់ធ្នាប់ការងារឱ្យបានសមស្រប តាមលក្ខណៈបច្ចេកទេស ។

4-(458)

ប្រការ ១០.-

ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវបំពាក់ប្រដាប់ការពារសុវត្ថិភាព មានមួកសុវត្ថិភាព ស្រោមដៃ ស្បែកជើង ខ្សែក្រវ៉ាត់សុវត្ថិភាពសម្រាប់ឈរនៅទីខ្ពស់ និង ឧបករណ៍ការពារដទៃទៀតដល់បុគ្គលិក កម្មករជាប្រចាំក្នុងការដ្ឋាន ។

ប្រការ ១១.-

ពេលសាងសង់រួចជាស្ថាពរ ម្ចាស់សំណង់ត្រូវផ្ញើរបាយការណ៍ស្តីពីដំណើរការសាងសង់របស់ខ្លួន និង សុំលិខិតបិទការដ្ឋានសំណង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ។

សំណុំឯកសារដើម្បីសុំលិខិតបិទការដ្ឋាន :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋាន

៣-របាយការណ៍អំពីដំណើរការសាងសង់ ។

ប្រការ ១២.-

ពេលទទួលបានលិខិតបិទការដ្ឋានរួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៃ សំណង់នោះទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តក្រុង មុនបើកការប្រើប្រាស់ ។

ប្រការ ១៣.-

ពេលបញ្ចប់ការដ្ឋានសាងសង់ជាស្ថាពរ ម្ចាស់សំណង់ត្រូវរុះរើ របងហ៊ុមព័ទ្ធការដ្ឋាន និង ដឹកជញ្ជូនកាកសំណល់ឱ្យបានស្អាត។

ប្រការ ១៤.-

ការដ្ឋានដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិដូចមានចែងក្នុងប្រការ៣ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការងារការដ្ឋានជាបណ្តោះអាសន្ន។ក្នុងករណីម្ចាស់ការដ្ឋានរឹងរូសនៅតែបន្តការសាងសង់អាជ្ញាធរមានសមត្ថកិច្ចត្រូវមានវិធានការដកហូត សម្ភារៈសាងសង់ទាំងនោះ ហើយប្តឹងទៅតុលាការ ។

ការដ្ឋានដែលប្រព្រឹត្តល្មើសនឹងករណីដូចមានចែងក្នុងប្រការ៤.៧.៩.១០.១១ និង ប្រការ១២ មន្ត្រីជំនាញមានសមត្ថកិច្ចត្រូវធ្វើការណែនាំឱ្យម្ចាស់សំណង់បំពេញលក្ខខណ្ឌខ្វះខាតទាំងនោះ ឬ ធ្វើលិខិតជូនដំណឹងឱ្យកែតម្រូវចំណុចខុសឆ្គងនឹងប្លង់ដែលបានអនុញ្ញាត ឬខុសនឹង នគរូបនីយប្បញ្ញត្តិ ។ ក្រោយបានទទួលលិខិតជូនដំណឹងរយៈពេល១៥ថ្ងៃ បើគ្មានការកែតម្រូវទេ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការដ្ឋានជាបណ្តោះអាសន្ន។ក្នុងករណីម្ចាស់សំណង់

(៤៥៧)

មិនព្រមអនុវត្តតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរុះរើ រឹបអូសសម្ភារៈសាងសង់ទាំងអស់ ហើយប្តឹងទៅតុលាការ ។

ការដ្ឋានដែលល្មើសទឹងករណីដូចមានចែងក្នុងប្រការ ៥ . ៦ និងប្រការ ៨ អាជ្ញាធរមានសមត្ថកិច្ចត្រូវជាកពិន័យ ហើយបង្ខំឱ្យម្ចាស់ការដ្ឋានអនុវត្តតាមការណែនាំអំពីរបៀបរបបសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ។ ក្នុងករណីម្ចាស់សំណង់នៅតែមិនគោរពតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរឹបអូសសម្ភារៈសំណង់ទាំងនោះ ។

## ប្រការ ១៥.-

ការដ្ឋានដែលត្រូវបានផ្អាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ក្នុងប្រការទី ១៤ នៃប្រកាសនេះត្រូវបានអនុញ្ញាតឱ្យបើកតាមផ្លូវច្បាប់ជាថ្មីឡើងវិញ លុះត្រាតែបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ។

សំណុំបែបបទនៃការបើកការដ្ឋានឡើងវិញ មានដូចខាងក្រោម :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋានចាស់

៣-លិខិតផ្អាកការដ្ឋាន

៤-លិខិតបញ្ជាក់អំពីការបំពេញបានសព្វគ្រប់ នៃ លក្ខខណ្ឌខ្វះខាត ។

## ប្រការ ១៦.-

ម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់ ត្រូវគោរពច្បាប់ការងារ នៃ ព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១៧.-

នាយកខុទ្ទកាល័យ អគ្គនាយក នៃ គ្រប់អគ្គនាយកដ្ឋាន ប្រធាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ. ថ្ងៃទី ២០ ខែ [illegible]......ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ: ...០៧៤....... ប្រក/អសណ

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតជួសជុលសំណង់អគារ

---

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- បានឃើញប្រកាសរួមលេខ ១២២៩ ប្រក.មផ.ដនស រវាងក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត
- តាមការចាំបាច់របស់ក្រសួង

## សម្រេច



អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet Com. Kh

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណង៖

- ផ្តល់ភាពស្របច្បាប់នៃសំណង់
- ធានាសុវត្ថិភាពលើការងារជួសជុលកែលម្អសំណង់អគារ
- បង្កើនការជឿទុកចិត្តពីសាធារណជននិងម្ចាស់សំណង់លើគុណភាពសំណង់តាមរយៈការតាមដានត្រួតពិនិត្យរបស់អ្នកបច្ចេកទេសជំនាញលើការជួសជុលអគារ ។

**ប្រការ៣.-**

ប្រកាសនេះមានគោលដៅដូចតទៅ ៖

- ទប់ស្កាត់ការជួសជុលសំណង់អគារដែលគ្មានលិខិតអនុញ្ញាតជួសជុល ឬខុសពីលិខិតអនុញ្ញាតជួសជុល
- ពង្រឹងអនុវត្តការងារបទប្បញ្ញត្តិនានា ដែលទាក់ទងនឹងសុវត្ថិភាពសណ្តាប់ធ្នាប់ សោភ័ណភាព គុណភាពសំណង់ បរិស្ថាននិងជៀសវាងផលប៉ះពាល់ផ្សេងៗបណ្តាលមកពីការជួសជុលកែលម្អសំណង់អគារដែលមិនស្របតាមគំនូរប្លង់ នគរូបនីយប្បញ្ញត្តិ បទដ្ឋានបច្ចេកទេស រចនាសម្ព័ន្ធក្រោមដី និងឯកសារនានាដែលបានអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជាលើកលែងតែសំណង់ជារាសាស្ត្រ សំណង់ស្ពានថ្នល់ សំណង់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ សំណង់ពាក់ព័ន្ធវិស័យការពារជាតិ រាល់ការជួសជុលអគារទាំងឡាយដែលមិនបណ្តាលឲ្យប៉ះពាល់ដល់សំណង់ជិតខាង ឬសមត្ថភាពគ្រឿងផ្គុំសំណង់ និងរាល់ការជួសជុលតូចតាច ។

**ប្រការ៤.-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

- ការជួសជុលសំណង់ សំដៅដល់ការជួសជុលនូវចំណែកណាមួយនៃសំណង់ដែលខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ
- គំនូរប្លង់ សំដៅដល់គំនូរប្លង់ស្ថាបត្យកម្មនិងប្លង់វិស្វកម្ម ដែលគូរដោយអ្នកបច្ចេកទេសជំនាញស្របតាមបទដ្ឋានបច្ចេកទេសសំណង់និងមានមាត្រដ្ឋានកំណត់ច្បាស់លាស់
- គ្រឿងផ្គុំសំណង់ សំដៅដល់រចនាសម្ព័ន្ធអគាររួមមាន គ្រឹះ សសរ ធ្នឹម កម្រាល គ្រឿងផ្គុំដំបូល ជណ្តើរ ជញ្ជាំងរងបន្ទុក និងគ្រឿងផ្គុំសំណង់ផ្សេងទៀត ដែលគ្រោងឡើងសម្រាប់ទ្រទម្ងន់

- ស្ថាប័នមានសមត្ថកិច្ចឬស្ថាប័នជំនាញ សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ
- ស្ថាបត្យកម្ម សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារ និងការសាងសង់ទាំងក្នុងនិងក្រៅនៃសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេស និងតាមសំណុំសោភ័ណភាពដែលបានគ្រោងទុក ដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន
- អ្នកបច្ចេកទេសជំនាញ សំដៅដល់មន្ត្រីជំនាញរបស់រដ្ឋនិងអ្នកបច្ចេកទេសជំនាញរបស់ក្រុមហ៊ុន មានជាអាទិ៍ ស្ថាបត្យករ វិស្វករ អ្នកបច្ចេកទេសខាងវិស័យសំណង់
- អ្នកពាក់ព័ន្ធ សំដៅដល់អ្នកបច្ចេកទេសជំនាញ ក្រុមហ៊ុនត្រួតពិនិត្យការដ្ឋាន សហគ្រាសទទួលការសាងសង់ រូបវន្តបុគ្គលប្រចាំការដ្ឋាន ភ្នាក់ងារអង្កេតការដ្ឋាន និងអ្នកជិតខាង
- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់ក្រសួងស្ថាប័នរដ្ឋ ឬរដ្ឋបាលមូលដ្ឋានថ្នាក់ក្រោមជាតិ
- ថ្ងៃធ្វើការ សំដៅដល់ថ្ងៃធ្វើការជាផ្លូវការកំណត់ដោយរាជរដ្ឋាភិបាល
- ការជួសជុលតូចតាច សំដៅដល់ការកោសលាប និង/ឬការសម្អាតខាងក្នុងអគារ ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**ប្រការ៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលមានសិទ្ធិស្នើសុំធ្វើការជួសជុលសំណង់អគារគ្រប់ប្រភេទលើកលែងតែសំណង់ណាដែលមានចែង លើកលែងក្នុងប្រការ៣ ។ លិខិតអនុញ្ញាតជួសជុល ត្រូវបានផ្តល់ជូនដោយស្ថាប័នមានសមត្ថកិច្ចតាមការស្នើសុំរបស់ម្ចាស់សំណង់ ឬតំណាងស្របច្បាប់របស់ខ្លួន មុនចាប់ផ្តើមដំណើរការជួសជុល។

ឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុល មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៦.-**

លិខិតអនុញ្ញាតជួសជុលត្រូវចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចរៀងៗខ្លួន។

ចំពោះអគារដែលបានសាងសង់មុនឆ្នាំ១៩៩៨ ការស្នើសុំជួសជុលអគារទាំងនោះមិនតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ទេ ។

ចំពោះអគារដែលបានសាងសង់ក្នុងចន្លោះឆ្នាំ១៩៩៨ ដល់មុនពេលចេញប្រកាសនេះ ហើយគ្មានលិខិតអនុញ្ញាតសាងសង់និងគ្មានទំនាស់ ស្ថាប័នមានសមត្ថកិច្ចអាចចេញលិខិតអនុញ្ញាតជួសជុលជូនម្ចាស់សំណង់បាន ដោយម្ចាស់សំណង់ត្រូវធ្វើកិច្ចសន្យាធានានិងទទួលខុសត្រូវលើគុណភាពសំណង់ សុវត្ថិភាពអ្នកជិតខាង និងសណ្តាប់ធ្នាប់សាធារណៈ។

ប្រការ៧.-

ចំពោះសំណង់អគារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ននានា មុនពេលជួសជុល ម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតជួសជុលពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ លើកលែងតែសំណង់ដែលមានចែង លើកលែងក្នុងប្រការ៣នៃប្រកាសនេះ ឬសំណង់អគារណាដែលមានលិខិតបទដ្ឋានគតិយុត្តកំណត់ដោយឡែក ។

ប្រការ៨.-

សេចក្តីជូនដំណឹងស្តីពីការស្នើសុំជួសជុល ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃចាប់ ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំដោយបិទផ្សាយនៅកន្លែងគ្រោងធ្វើការជួសជុល។ ក្នុងករណីចាំបាច់បន្ទាន់ ការជួសជុលអាចប្រព្រឹត្តទៅបានមុនផុតកំណត់រយៈពេល១៥(ដប់ប្រាំ) ថ្ងៃនៃសេចក្តីជូនដំណឹងខាងលើដោយយោងទៅលើការវាយតម្លៃរបស់ស្ថាប័នមានសមត្ថកិច្ច។

សេចក្តីជូនដំណឹងខាងលើត្រូវធ្វើឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាល ក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចសម្រេចលើលិខិតអនុញ្ញាតជួសជុលរៀងៗខ្លួន ។

## ជំពូកទី៣
## បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុល

ប្រការ៩.-

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានសំណង់ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរ ឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់
- ការិយាល័យកិច្ចការទូទៅត្រូវបញ្ជូនពាក្យស្នើសុំ និងឯកសារភ្ជាប់ទៅការិយាល័យជួសជុល និងថែទាំ នៃនាយកដ្ឋានសំណង់ ដើម្បីពិនិត្យ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថាពាក្យស្នើសុំ និងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ

- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុលត្រូវចាប់រាប់ពីថ្ងៃទទួលឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ការិយាល័យជួសជុលនិងថែទាំ ត្រូវចុះពិនិត្យទីតាំងជួសជុលជាក់ស្តែងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ០៨ (ប្រាំបី)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់ពិនិត្យសម្រេច
- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

**ប្រការ១០.-**

បរិបទនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត មានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរឬបកប្រែជាភាសាខ្មែរចំនួន ០៧ច្បាប់
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថា ពាក្យស្នើសុំនិងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំនៅមានលក្ខណៈពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ
- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវចាប់រាប់ពីថ្ងៃទទួលឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទាំងនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ដើម្បីពិនិត្យសម្រេចតាមសមត្ថកិច្ច
- ការិយាល័យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ក្នុងរយៈពេល០២(ពីរ)ថ្ងៃ ។ បើមានការខ្វះខាតអាចស្នើឲ្យ

អ្នកស្នើសុំលិខិតអនុញ្ញាតជួសជុលបំពេញបន្ថែមក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ (រយៈពេលនេះមិនរាប់បញ្ចូលក្នុងបរិបថនៃការចេញលិខិតអនុញ្ញាតជួសជុល១៥(ដប់ប្រាំ)ថ្ងៃទេ )

- ការិយាល័យសំណង់ត្រូវចុះពិនិត្យទីតាំងជាក់ស្តែងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំមន្ទីរពិនិត្យនិងសម្រេច
- ថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ ។

**ប្រការ១១.-**

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌមានដូចតទៅ ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរ ឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថាពាក្យស្នើសុំនិងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំនៅមានលក្ខណៈពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឱ្យបានគ្រប់គ្រាន់និង/ឬឱ្យបានត្រឹមត្រូវ
- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់ និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវចាប់រាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ផ្នែកសំណង់នៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យទីតាំងជាក់ស្តែងនិងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច
- ថ្នាក់ដឹកនាំនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ១២.-

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌដែលទទួលបានប្រតិភូកម្មមុខងារមានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យច្រកចេញចូលតែមួយរបស់សាលាក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់ ។ ការទទួលពាក្យសុំត្រូវចុះកាលបរិច្ឆេទនិងចេញបង្កាន់ដៃទទួលពាក្យ
- រាល់ការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវអនុវត្តតាមបែបបទរដ្ឋបាលរបស់សាលាក្រុង ស្រុក ខណ្ឌ បន្ទាប់ពីបានទទួលយោបល់របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ
- រាល់លិខិតអនុញ្ញាតជួសជុលដែលផ្តល់ដោយសាលាក្រុង ស្រុក ខណ្ឌ ច្រកចេញចូលតែមួយត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារទាំងនេះចំនួន០១ច្បាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និង០១ច្បាប់មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ។

ប្រការ១៣.-

លិខិតអនុញ្ញាតជួសជុល ត្រូវចាត់ទុកថាបានយល់ព្រម បើពុំមានចម្លើយណាមួយពីស្ថាប័នមានសមត្ថកិច្ចក្រោយពីថ្ងៃដាក់ពាក្យស្នើសុំចំនួន២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ១៤.-

សោហ៊ុយសេវានៃការចេញលិខិតអនុញ្ញាតជួសជុល ត្រូវអនុវត្តតាមស្មារតីនៃប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ១៥.-

លិខិតអនុញ្ញាតជួសជុលអស់សុពលភាព ប្រសិនបើការងារជួសជុលពុំដំណើរការក្នុងរយៈពេល០៣(បី)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតជួសជុល ។

លិខិតអនុញ្ញាតនេះ អាចពន្យាពេលបានតែមួយដងគត់ ប្រសិនបើម្ចាស់សំណង់មានមូលហេតុសមស្រប ។

ក្នុងករណីដែលការងារជួសជុលត្រូវបានផ្អាកលើសពី៣០(សាមសិប)ថ្ងៃ ដោយគ្មានមូលហេតុសមស្រប ស្ថាប័នមានសមត្ថកិច្ចត្រូវបង្ខំឲ្យម្ចាស់សំណង់បញ្ចប់ការងារជួសជុលនេះក្នុងរយៈពេលមួយជាកំណត់ អាស្រ័យលើទំហំការងារ និងការវាយតម្លៃជាក់ស្តែងរបស់មន្ត្រីជំនាញ ដើម្បីរក្សានូវសោភ័ណភាព សុវត្ថិភាពការដ្ឋាននិងសណ្តាប់ធ្នាប់សាធារណៈ ។

## ជំពូកទី៤
## ការត្រួតពិនិត្យការដ្ឋានជួសជុល ភារកិច្ចរបស់ម្ចាស់សំណង់ និងបណ្តឹងតវ៉ា

**ប្រការ១៦.-**

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិត្រួតពិនិត្យតាមដានការដ្ឋានជួសជុលនិងឯកសារពាក់ព័ន្ធនឹងការជួសជុលបានគ្រប់ពេលវេលា។ បើពិនិត្យឃើញថា ការជួសជុលមិនស្របតាមលិខិតអនុញ្ញាតជួសជុល និងមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសជំនាញ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ឬអគ្គនាយកដ្ឋានសំណង់ ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរឲ្យម្ចាស់សំណង់ធ្វើការកែតម្រូវជាបន្ទាន់ឲ្យស្របតាមលិខិតអនុញ្ញាតជួសជុលនិងតាមបទដ្ឋានបច្ចេកទេសជំនាញ ។

ក្នុងករណីដែលម្ចាស់សំណង់មិនព្រមធ្វើតាមការណែនាំខាងលើនេះ ស្ថាប័នជំនាញមានសិទ្ធិបញ្ឈប់ការជួសជុល ឬចេញលិខិតផ្អាកការដ្ឋាន និងឲ្យម្ចាស់សំណង់ធ្វើការកែតម្រូវជាលើកទី២ឲ្យបានត្រឹមត្រូវក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលលិខិតណែនាំជាផ្លូវការ។

ប្រសិនបើម្ចាស់សំណង់ នៅតែរឹងរូសមិនព្រមអនុវត្តទៅតាមការណែនាំខាងលើនេះ មន្ត្រីជំនាញមានសិទ្ធិស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយដល់ការអនុវត្តន៍ឲ្យមានប្រសិទ្ធភាព។

**ប្រការ១៧.-**

ត្រូវបានហាមឃាត់ ៖

- ការដាក់តាំងគរសម្ភារៈសំណង់លើផ្លូវសាធារណៈ
- ការតាំងការដ្ឋានលយទៅលើចិញ្ចើមផ្លូវសាធារណៈលើសពីពីរភាគបីនៃចិញ្ចើមផ្លូវ
- ការបង្ហូរនិងការចោលកាកសំណល់ពីការដ្ឋានសំណង់មកផ្លូវនិងទីសាធារណៈ ។

ម្ចាស់ការដ្ឋានសំណង់ត្រូវ ៖

- ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់ក្នុងរយៈពេលដំណើរការជួសជុល
- រុះរើ សម្អាតការដ្ឋានជួសជុល និងយកចេញនូវសម្ភារៈបរិក្ខាគ្រឿងចក្រ និងកាកសំណល់ពីការដ្ឋានជួសជុលក្នុងរយៈយ៉ាងយូរពីរសប្តាហ៍ក្រោយពេលចប់ការងារជួសជុល ។

**ប្រការ១៨.-**

ក្នុងពេលដំណើរការជួសជុល ម្ចាស់សំណង់និងអ្នកពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងវិវាទផ្សេងៗដែលបណ្តាលមកពីការធ្វេសប្រហែស ឬការជួសជុលមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសំណង់ ។

**ប្រការ១៩.-**

ក្នុងករណីមានបណ្តឹងតវ៉ាដែលទាក់ទងនឹងការស្នើសុំជួសជុលឬការជួសជុល អ្នកប្តឹងតវ៉ាអាចប្តឹងទៅស្ថាប័នមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតជួសជុលឲ្យជួយដោះស្រាយទំនាស់ ។ ស្ថាប័នមានសមត្ថកិច្ចត្រូវផ្អាកដំណើរការនៃការស្នើសុំលិខិតអនុញ្ញាតជួសជុលឬផ្អាកការជួសជុលជាបណ្តោះអាសន្នសិន ដើម្បីធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់នេះ ។

ក្នុងករណីដែលការសម្របសម្រួលខាងលើមិនអាចធ្វើបាន អ្នកប្តឹងតវ៉ាអាចប្តឹងទៅតុលាការដើម្បីដោះស្រាយតាមនីតិវិធីនៃច្បាប់ ។

## ជំពូកទី៥
## អំពីសំណង់ចាស់

**ប្រការ២០.-**

រាល់សំណង់អគារចាស់ទ្រុឌទ្រោមមិនអាចស្នាក់នៅបាន និងអាចបង្កគ្រោះថ្នាក់ដោយប្រការណាមួយដែលមានការវាយតម្លៃច្បាស់លាស់ពីស្ថាប័នជំនាញ អាជ្ញាធរមានសមត្ថកិច្ចតាមសំណើរបស់ស្ថាប័នជំនាញត្រូវជូនដំណឹងដល់ម្ចាស់សំណង់ ឬកម្មសិទ្ធិករដែលស្នាក់នៅក្នុងអគារនោះ ដោយបង្ខំឲ្យធ្វើការរុះរើ ឬជួសជុលជាបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងជៀសវាងគ្រោះថ្នាក់ជាយថាហេតុ ។ ការជួសជុលត្រូវធ្វើឲ្យស្របតាមបទដ្ឋានបច្ចេកទេសសំណង់ ។

ក្នុងករណីដែលម្ចាស់សំណង់មិនព្រមជួសជុលតាមសេចក្តីជូនដំណឹងខាងលើចំនួន២(ពីរ)ដង ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះការខូចខាតឬគ្រោះថ្នាក់ទាំងឡាយដែលកើតឡើងដោយការមិនព្រមជួសជុលសំណង់របស់ខ្លួន ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២១.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ២២.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ.កុម្ភៈ.. ឆ្នាំ២០១៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលារាជធានីខេត្ត
- ដូចប្រការ២១
- ឯកសារ-កាលប្បវត្តិ

5

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ ១៩២.ប្រក.ដនស/អសណ

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/ន.ស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដជដជី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**ប្រការ ១.-**

ប្រកាសនេះមានវិសាលភាពអនុវត្តលើរូបវន្តបុគ្គលជាស្ថាបត្យករ ឬវិស្វករ ដែលធ្វើការសិក្សាគំរោងប្លង់នៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។ រូបវន្តបុគ្គលទាំងនោះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ២.-**

ក្នុងន័យនៃប្រកាសនេះ វាក្យស័ព្ទ :

- រូបវន្តបុគ្គលសំដៅដល់អ្នកសិក្សាគំរោងប្លង់ មានលក្ខណៈជាបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស
- សិក្សាគំរោងប្លង់សំដៅដល់ការសិក្សាគំរោងប្លង់ដែលពាក់ព័ន្ធនឹងការសាងសង់ ។

**ប្រការ ៣.-**

ស្ថាបត្យករ ឬវិស្វករដែលធ្វើការសិក្សាគំរោងប្លង់តាមមុខជំនាញរបស់ខ្លួនជារូបវន្តបុគ្គល ត្រូវមកបំពេញបែបបទសុំចុះឈ្មោះជារូបវន្តបុគ្គលសិក្សាគំរោងប្លង់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (នាយកដ្ឋានសិក្សាគំរោងប្លង់នៃអគ្គនាយកដ្ឋានសំណង់) ដើម្បីមានសិទ្ធិក្នុងការសិក្សាគំរោងប្លង់សំណង់ផ្សេងៗ និងមានការទទួលស្គាល់ពីក្រសួងនូវបទពិសោធន៍មុខវិជ្ជាជីវៈជំនាញដែលខ្លួនមាន ។

ក្រសួងមិនទទួលស្គាល់រាល់ការចុះហត្ថលេខាបញ្ជាក់លើរាល់ឯកសារ គំរោងប្លង់របស់ស្ថាបត្យករ ឬវិស្វករណាដែលមិនបានមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះទេ ។

**ប្រការ ៤.-**

រាល់រូបវន្តបុគ្គលដែលមានបំណង ឬកំពុងធ្វើការសិក្សាគំរោងប្លង់នៅព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែរ ។

**ប្រការ ៥.-**

ដើម្បីចុះបញ្ជីរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ស្ថាបត្យករ ឬវិស្វករត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

- មានសញ្ញាបត្រស្ថាបត្យករ ឬសញ្ញាបត្រវិស្វករ
- មានបទពិសោធន៍ការងារក្នុងមុខជំនាញ ដែលធ្លាប់បានអនុវត្តការងារសិក្សាគំរោងប្លង់កន្លងមក នៅតាមបណ្តាអង្គភាព ស្ថាប័ន ក្រុមហ៊ុនឯកជន អង្គការនានា ។ល។
- មានលិខិតបញ្ជាក់ការសិក្សា ឬវិញ្ញាបនបត្រផ្សេងៗនៃវគ្គបំពាក់បំប៉ន ឬបណ្តុះបណ្តាលបន្ថែមផ្នែកមុខជំនាញផ្ទាល់ខ្លួនប្រសិនបើមាន ។

**ប្រការ ៦.-**

១- ស្ថាបត្យករជារូបវន្តបុគ្គលសិក្សាគំរោងប្លង់ស្ថាបត្យកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

**ក- កំរិតទី១** : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

**ខ- កំរិតទី២** : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

គ- កំរិតទី៣ : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ ឆ្នាំ ។

២- វិស្វករជារូបវន្តបុគ្គលសិក្សាគំរោងប្លង់គ្រឿងផ្គុំសំណង់ ឬប្លង់វិស្វកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

ក- កំរិតទី១ : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

ខ- កំរិតទី២ : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

គ- កំរិតទី៣ : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ ឆ្នាំ ។

## ប្រការ ៧.-

ការកំណត់កំរិតរូបវន្តបុគ្គលត្រូវពិនិត្យសំរេចដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ប្រការ ៨.-

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចដូចតទៅ :

- វាយតំលៃរូបវន្តបុគ្គលដែលស្នើសុំចុះបញ្ជី
- តាមដានត្រួតពិនិត្យសកម្មភាពរបស់រូបវន្តបុគ្គលក្នុងពេលសិក្សាគំរោងប្លង់
- ស៊ើបអង្កេតពេលមានបណ្តឹងតវ៉ាចំពោះរូបវន្តបុគ្គល និងធ្វើការសំរបសំរួលការងារពាក់ព័ន្ធផ្នែកវិស្វកម្មនិងស្ថាបត្យកម្ម
- ស្នើសុំព្យួរ ឬដកយកវិញ្ញាបនបត្រពីរូបវន្តបុគ្គលណាដែលប្រព្រឹត្តខុសលក្ខណៈបច្ចេកទេស មិនគោរពកាតព្វកិច្ច និងសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ។

## ប្រការ ៩.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចចេញវិញ្ញាបនបត្រសិក្សាគំរោងប្លង់ និងចេញលិខិតបិទឬផ្អាក ការសិក្សាគំរោងប្លង់របស់រូបវន្តបុគ្គល ។

## ប្រការ ១០.-

សំណុំឯកសារនៃពាក្យសុំសិក្សាគំរោងប្លង់របស់រូបវន្តបុគ្គលរួមមាន :

| | |
|---|---|
| - ពាក្យសុំសិក្សាគំរោងប្លង់ | ៣ច្បាប់ |
| - ជីវប្រវត្តិសង្ខេបរបស់រូបវន្តបុគ្គល មានបិទរូបថតទំហំ ៤ x ៦ | ៣ច្បាប់ |
| - អត្តសញ្ញាណប័ណ្ណរបស់រូបវន្តបុគ្គល (ថតចំលង) | ៣ច្បាប់ |
| - លិខិតបញ្ជាក់ទីលំនៅរបស់រូបវន្តបុគ្គល ពីឃុំ សង្កាត់ (ច្បាប់ដើម) | ១ច្បាប់ |
| - សញ្ញាបត្ររបស់រូបវន្តបុគ្គលដែលមានធ្វើនីត្យានុកូលកម្មបញ្ជាក់ពីសាលាខេត្ត ក្រុង | ១ច្បាប់ |
| - កិច្ចសន្យាការងាររវាងរូបវន្តបុគ្គលជាមួយនឹងអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៣ច្បាប់ |

- បញ្ជីសំភារៈបរិក្ខារសិក្សាគំរោងប្លង់ ៣ច្បាប់
- ឯកសារស្នាដៃ សំរាប់រូបវន្តបុគ្គលកំរិតទី១ និងកំរិតទី២ ៣ច្បាប់

**ប្រការ ១១.–**

សំណុំឯកសារពាក្យសុំសិក្សាគំរោងប្លង់ ត្រូវដាក់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ក្នុងករណីសំណុំឯកសារនៃពាក្យសុំចុះបញ្ជីមានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់ និងបន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងផ្តល់ជូនវិញ្ញាបនបត្រសិក្សាគំរោងប្លង់ ជូនម្ចាស់សំណើក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីពិនិត្យឃើញថា លិខិតស្នាមណាមួយនៃសំណុំឯកសារពាក្យសុំ មានភាពមិនច្បាស់លាស់ ឬមិនគ្រប់គ្រាន់ សាមីខ្លួនត្រូវបំពេញបន្ថែមតាមការណែនាំរបស់នាយកដ្ឋានសិក្សាគំរោងប្លង់ ។

**ប្រការ ១២.–**

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រសិក្សាគំរោងប្លង់ នឹងអាចចូលរួមក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាលនានាតាមការអញ្ជើញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីលើកកំពស់សមត្ថភាព និងគុណភាពវិជ្ជាជីវៈលើការងារជំនាញ ។

**ប្រការ ១៣.–**

រាល់រូបវន្តបុគ្គលសិក្សាគំរោងប្លង់អាចសុំតម្លើងឋានៈកំរិតរបស់ខ្លួន នៅពេលណាដែលរូបវន្តបុគ្គលនោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយការវាយតំលៃក្នុងការតំលើងឋានៈនេះ ត្រូវពិនិត្យសំរេចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ១៤.–**

រូបវន្តបុគ្គលដែលប្រកបអាជីវកម្មសិក្សាគំរោងប្លង់ ត្រូវបង់ពន្ធអាករតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ១៥.–**

វិញ្ញាបនបត្រសិក្សាគំរោងប្លង់របស់រូបវន្តបុគ្គលមានសុពលភាព ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។ ក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព រូបវន្តបុគ្គលត្រូវដាក់ពាក្យសុំបន្តសុពលភាពសិក្សាគំរោងប្លង់ សាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

រូបវន្តបុគ្គលត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅរាល់ដំណាច់ឆ្នាំនីមួយៗ ។

## ប្រការ ១៦.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបិទឬផ្អាកការសិក្សាគំរោងប្លង់ ចំពោះរូបវន្តបុគ្គល ដែលគ្មានវិញ្ញាបនបត្រសិក្សាគំរោងប្លង់ និងចំពោះរូបវន្តបុគ្គលទាំងឡាយណាដែលវិញ្ញាបនបត្រសិក្សាគំរោងប្លង់ហួសសុពលភាព ឬមិនគោរពតាមសីលធម៌វិជ្ជាជីវៈ និងតាមការណែនាំរបស់សមត្ថកិច្ចជំនាញ ។

## ប្រការ ១៧.-

ស្ថាបត្យករ ឬវិស្វករដែលបានចុះបញ្ជី និងបានបំពេញកាតព្វកិច្ចស្របតាមគោលការណ៍សីលធម៌វិជ្ជាជីវៈមានទេពកោសល្យ មានស្នាដៃឆ្នើម មានគុណបំណាច់ និងមនសិការបំរើប្រទេសជាតិក្នុងការងារវិជ្ជាជីវៈរបស់ខ្លួន នឹងត្រូវទទួលស្គាល់ និងលើកសរសើរ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថាជាស្ថាបត្យករឆ្នើម ឬជាវិស្វករឆ្នើម ។

## ប្រការ ១៨.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

កន្លែងទទួល :
- ...ការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ១៨
- គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ក្រសួង.រ.ន.ស.
ចូល លេខ 3009
ថ្ងៃខែឆ្នាំ 05.07.19 18:18
បញ្ជូន សរុប

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ៩៤៨ សជណ

ថ្ងៃសុក្រ ៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**
- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍សម្រេចលើវិធានការចាំបាច់សំដៅទប់ស្កាត់ការដ្ឋានសំណង់ខុសច្បាប់ ដើម្បីធានាអាយុជីវិតមនុស្ស ទ្រព្យសម្បត្តិ សុវត្ថិភាព និងគុណភាពសំណង់ទូទាំងប្រទេស។

**យោង ៖**
- លិខិតលេខ១៩៨១ ដនស/អរប. ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ៤២៧ ខន/០១៩ សជណ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការចាំបាច់មួយចំនួន ចំពោះការដ្ឋានសំណង់សណ្ឋាគារ អគារស្នាក់នៅរួម អគារពាណិជ្ជកម្ម អគាររោងចក្រ អគារសិប្បកម្ម និងសំណង់ផ្សេងទៀត ដែលគ្មានលិខិតអនុញ្ញាតនិង/ឬសាងសង់ខុសលក្ខណៈបច្ចេកទេសលើកលែងតែសំណង់លំនៅឋានផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋដូចខាងក្រោម៖

១. ក្រសួងរ៉ែ និងថាមពល ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ការដ្ឋានសំណង់។

២. ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ការដ្ឋានសំណង់។

៣. ក្រសួងសាធារណការ និងដឹកជញ្ជូន មិនត្រូវអនុញ្ញាតឱ្យតភ្ជាប់លូចូលបណ្តាញលូសាធារណៈ។

៤. ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវផ្តល់លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម។

៥. ក្រសួងព័ត៌មាន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
- ក្រសួង ស្ថាប័ន និងអង្គភាពមានសម្ព័ន្ធកិច្ច
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ០០១.ដ.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០០

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងក្រុមជាងសំណង់

អនុលោមទៅតាមប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ និង ដើម្បីគ្រប់គ្រង អោយមានប្រសិទ្ធភាពការងារសាងសង់ ដែលអនុវត្តដោយក្រុមជាងសំណង់នៅតាមបណ្តា ខេត្ត ក្រុង ដែលបច្ចុប្បន្ននេះក្រុមជាងសំណង់ទាំងនេះប្រកបរអាជីវកម្មសាងសង់តាមទ្រង់ទ្រាយអាជីវកម្មតូច និង មិនទាន់មានប្រកាសអនុញ្ញាតនៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំដូចតទៅ :

I - <u>សិទ្ធិរបស់ក្រុមជាងសំណង់</u>

ការប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់ ត្រូវបានប្រគល់សិទ្ធិអោយអនុវត្តការងារតាមការកំណត់ និង មុខជំនាញដូចខាងក្រោម ហើយដែលមានទំហំបច្ចេកទេសមិនលើសពីកំរិតកំណត់ដូចតទៅ :

- ផ្ទៃក្រឡាសំណង់សរុប 80 ម៉ែត្រទ្វេគុណ
- ផ្ទៃក្រឡាសំណង់ ដែលត្រូវសង់ថ្មីបន្ត ឬពង្រីកបន្ថែម ត្រូវបូកបញ្ចូលនឹងផ្ទៃក្រឡាសំណង់ចាស់មានស្រាប់
- ផ្ទៃក្រឡាសំណង់ត្រូវគិតបញ្ចូលគ្នា ចំពោះសំណង់ដែលមានគ្រឿងផ្គុំជាប់គ្នា ទោះបីមានកម្មសិទ្ធិដោយឡែកពីគ្នា ឬពេលវេលានៃការអនុញ្ញាតអោយសាងសង់ខុសគ្នាក៏ដោយ
- កំពស់អគារមួយជាន់ ( ជាន់ផ្ទាល់ដី )
- អគារពុំមានត្រៀមលក្ខណៈសង់បន្ថែមច្រើនជាន់
- សំណង់អគារពុំស្ថិតនៅតំបន់ដី បាក់ស្រុត តំបន់ដីបានកំរិតទ្រខ្សោយ
- ធ្នឹមកំរាល ធ្នឹមទ្រផ្សេងៗ មានប្រវែង 4 ម៉ែត្រ ហ្វ្រេមគ្រោងដំបូលមានប្រវែង 8 ម៉ែត្រ ធ្នឹមអណ្តែតមាន ប្រវែង 1,50 ម៉ែត្រ
- អាងកប់ដី ដែលមានចំណុះ 10 ម៉ែត្រត្រីគុណ អាងទឹកខ្ពស់ពីដី 4 ម៉ែត្រ ដែលមានចំណុះ 8 ម៉ែត្រត្រីគុណ

- របងកំពស់ 2,5 ម៉ែត្រ គិតពីនីវ៉ូ ដីត្រង់ជើងរបង
- សំណង់ជាល់នៅឋានរបស់ប្រជាពលរដ្ឋធ្វើពីឈើ ( ដោយមិនគិតពីផ្ទៃក្រឡា និងកំពស់នៃសំណង់ )
- ម៉ៅការបន្ត ការងារជុសជុល និង សាងសង់ពី សហគ្រាស ក្រុមហ៊ុនសាងសង់នានា ដែលមានលិខិតអនុញ្ញាត ប្រកបអាជីវកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយមានការទទួលខុសត្រូវលើ លក្ខណៈបច្ចេកទេសពីសហគ្រាស ក្រុមហ៊ុនសាងសង់នោះ
- ក្រុមជាងសំណង់ កាលណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចសុំតំឡើងឋានៈប្រភេទជាសហគ្រាស ក្រុមហ៊ុន សាងសង់បាន ដោយត្រូវធ្វើបែបបទស្នើសុំមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដើម្បី ពិនិត្យសំរេច ។

## II. សមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ខេត្ត ក្រុង

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មអោយដល់ក្រុមជាងសំណង់
- ចេញលិខិត បិទ ផ្អាក អាជីវកម្ម ក្រុមជាងសំណង់
- ស្រង់ស្ថិតិ សហគ្រាស ក្រុមហ៊ុនរួមទាំងក្រុមជាងសំណង់ និង ក្រុមជាងតាមមុខជំនាញ ដែលធ្វើអាជីវកម្ម ក្នុងមូលដ្ឋានរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ គ្រប់គ្រងសកម្មភាពអាជីវកម្ម
- ត្រូវផ្អាក ឬ បិទសកម្មភាពអាជីវកម្មរបស់ក្រុមជាងសំណង់ណា ដែលប្រកបអាជីវកម្មជុសជុល និងសាងសង់ គ្មានលិខិតអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឬ ក្នុងករណីដែលក្រុមជាងសំណង់នោះមិនគោរពតាមការកំណត់ ការណែនាំ បទប្បញ្ញត្តិផ្សេងៗ ពីក្រសួង ស្ថាប័ន និង មន្ទីរខេត្ត ក្រុងមានសមត្ថកិច្ច ។

## III. លក្ខខ័ណ្ឌសុំប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់

១- ប្រធានក្រុមជាងសំណង់ ដែលជាមេជាងសំណង់ត្រូវមានសញ្ជាតិខ្មែរ

២- ប្រធានក្រុមជាងសំណង់ត្រូវមកដាក់ពាក្យសុំប្រកបអាជីវកម្មដោយខ្លួនឯងផ្ទាល់

៣- នាមករណ៍របស់ក្រុមជាងសំណង់មិនអនុញ្ញាតអោយប្រើពាក្យថា សហគ្រាស ឬ ក្រុមហ៊ុនឡើយ

៤- ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥- ក្រុមជាងសំណង់ ត្រូវតំកល់ទុករបាយការណ៍ សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួននៅមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង តាមការណែនាំរបស់មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង

៦- ក្នុងករណីមានការផ្លាស់ប្តូរអាស័យដ្ឋាន ឬ ប្រធានក្រុមជាងសំណង់ ត្រូវជូនដំណឹងមកមន្ទីររៀបចំដែន ដី

នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង យ៉ាងយូរ២សប្តាហ៍ក្រោយការផ្លាស់ប្តូរ ។

IV- ទំរង់បែបបទ សុំប្រកបអាជីវកម្ម

- ពាក្យសុំប្រកបអាជីវកម្ម ៤ច្បាប់
- ជីវប្រវត្តិសង្ខេប របស់ប្រធានក្រុមជាងសំណង់ដោយមានបិទរូបថតទំហំ ៤ x ៦ ៤ច្បាប់
- ជីវប្រវត្តិសង្ខេប របស់ ជាង តាមមុខជំនាញ មានបិទរូបថត ៤ x ៦ ៤ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ របស់ប្រធានក្រុមជាងសំណង់ ដែលមានធ្វើនិត្យានុកូលកម្ម នៅសាលា ខេត្ត ក្រុង ៤ច្បាប់
- សេចក្តីប្រកាសពីភាពគ្មានទោសពៃរ៍ របស់ប្រធានក្រុមជាងសំណង់ ៤ច្បាប់
- លក្ខន្តិកៈរបស់ក្រុមជាងសំណង់ ៤ច្បាប់
- កិច្ចសន្យារវាងក្រុមជាងសំណង់ និង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដែលចេញលិខិតអនុញ្ញាតអោយប្រកបអាជីវកម្ម ៤ច្បាប់
- បញ្ជីរាយឈ្មោះជាងសំណង់តាមផ្នែកជំនាញ និង អង្គការលេខ របស់ក្រុមជាងសំណង់ ៤ច្បាប់
- ឯកសារស្នាដៃ (បើមាន) ២ច្បាប់
- បញ្ជីគ្រឿងចក្រសំណង់ (បើមាន) និង សំភារៈបរិក្ខារ ៤ច្បាប់
- ឯកសារធនាគារ (បើមាន) ១ច្បាប់
- បង្កាន់ដៃបង់ពន្ធ (ប័ណ្ណប៉ាតង់ ) ១ច្បាប់
- វិញ្ញាបនប័ត្រ ចុះបញ្ជីពាណិជ្ជកម្ម (បើមាន) ១ច្បាប់

រាល់ការបំពេញបែបបទដូចមានចែងក្នុងចំណុច IV ខាងលើ ត្រូវបំពេញតាមសំណុំឯកសារសុំប្រកបអោជីវកម្ម ដូចមានជូនភ្ជាប់ជាមួយ ។

V- សុពលភាព នៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម

លិខិតអនុញ្ញាតប្រកបអោជីវកម្ម ដល់ក្រុមជាងសំណង់ មានសុពលភាពបីឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ហើយក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាពក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតជាថ្មី ពីមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដោយភ្ជាប់មកជាមួយនូវ លិខិត អនុញ្ញាតចាស់ និង បង្កាន់ដៃបង់ ពន្ធអាករជាថ្មី ។

ទទួលបានសារាចរណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន និង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និង មានប្រសិទ្ធភាព ។

អ៊ឹម ឈុនលឹម

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័ន ពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន
- សាលាខេត្ត-ក្រុង
- គ្រប់មន្ទីរ ដ.ន.សសខេត្ត ក្រុង
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៦ អនក្រ · បក

2 5 DEC 1997

# អនុក្រឹត្យ
## ស្តីពី
## លិខិតអនុញ្ញាតសាងសង់

* * * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៨៩៧/ ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

## សំរេច

<u>មាត្រា ១</u> : រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញអោយមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី ១ នៃអនុក្រឹត្យនេះ ។

ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់<u>សំណង់តូចតាចធ្វើអំពីឈើ</u> ឬស្លឹក <u>រុក្ខជាតិនានា</u> ពុំទាមទារអោយសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខមាលភាពនៃសំណង់ និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារជីផ្លីសាធារណៈចាំបាច់ សំរាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទបញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និង សំណង់ឯកជន ។

រាល់ការគោរពនូវបទបញ្ញត្តិដែលមានចែងក្នុងវគ្គទី ២នៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទបញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និង ប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទបញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីឱ្យស្របទៅស្ថានភាពមូលដ្ឋាន ដោយស្ថិតក្នុងបទបញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្ត-ក្រុង ។

អនុក្រឹត្យនេះពុំងយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។ ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងក្លាដល់ប្រយោជន៍ ឬសោភ័ណភាពសាធារណៈ ការរុះរើត្រូវសំរេចដោយរាជរដ្ឋាភិបាល ឬតំណាងដែលបានទទួលសិទ្ធិប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

# វគ្គទី ១

# លិខិតអនុញ្ញាតសាងសង់ និង លិខិតអនុញ្ញាតរុះរើ

## ជំពូក ១

## ការតម្រូវនៃលិខិតអនុញ្ញាតសាងសង់

មាត្រា ២: **សំណង់ដែលតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ជាមុន**

រាល់ការសាងសង់ក្នុងទីក្រុង និង ទីប្រជុំជន ត្រូវមានលិខិតអនុញ្ញាតសាងសង់

រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ ។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និង ការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ដែរ ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការងារនេះកែប្រែ :

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ ( Aspect des Bâtiments )
- ការធ្វើបង្គន់អនាម័យ និង ការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន ( Locaux ouverts au public )
- ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីរួមណាមួយ ដូចជាលប់បំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ ល ។

ការសាងសង់ ឬ ការកែទ្រង់ទ្រាយសំណង់ផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ (ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងផ្ទុះ កន្លែងទទួលសាធារណៈជន) ។ ល ។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ផ្លាកយីហោ ផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ផ្លាកស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និង សាលាខេត្តនឹងធ្វើសេចក្តីណែនាំដោយឡែក ។

មាត្រា ៣: **សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់**

- សំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់ឡើយ ។

- ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើលែងតែការជួសជុលនោះអាចបណ្តាលអោយប៉ះពាល់ដល់អ្នកជិតខាង ។

- បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ :

- ទីសក្ការៈបូជា
- សាលាសំណាក់សាធារណៈ
- បណ្តាការស្ថាបនាដ៏សិល្បៈរបស់រដ្ឋសំរាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ

## ជំពូក ២

## សមត្ថកិច្ច ដែលចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៤ : **សមត្ថកិច្ចរបស់សាលាខេត្ត និង សាលាក្រុង**

៤.១ ខេត្ត-ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២ លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រធានរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬ ដោយអភិបាលខេត្ត-ក្រុង ឬ អភិបាលរងដែលបានទទួលសិទ្ធិប្រទាន ។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយល័ក្ខណ៍អក្សរ នូវមូលហេតុច្បាស់លាស់ ។

មាត្រា ៥ : **សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល**

៥.១ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសំរេចផ្តល់ លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ :

- បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែលមានផ្ទៃក្រឡាក្រោលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ។
- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។
- បណ្តាអគារសំរាប់ការបង្កបង្កើនផលកសិកម្ម សំរាប់ធ្វើអាជីវកម្មពី ៥០០ហិចតាឡើងទៅ ។
- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និង ស្ថានីយរថយន្ត ។
- បណ្តាសំណង់សាធារណៈ និង ឯកជន ដែលមានផ្ទៃក្រឡាក្រោលលើសពី ៣.០០០

ម៉ែត្រទ្វេគុណ និងផ្ទៃកញ្ចក់បន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ( វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក...) ។

- បណ្តាសំណង់សំខាន់ៗ ក្នុងទីដ្ឋានការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភ័ណ្ឌ ប្រវត្តិសាស្ត្រ បូរាណវត្ថុ និង វប្បធម៌ ។

- ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភ័ណ្ឌដែលបានកំណត់ទុក ។

- បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ។

- បណ្តាសំណង់ និង ការ្យ សំរាប់ការពារ និង អគារយោធា ។

៥.២ ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខា ដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគររូបនីយកម្ម និងសំណង់ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

## មាត្រា ៦ : គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬ សាលាក្រុង

៦.១ សមត្ថកិច្ច

អនុលោមតាមមាត្រា ១៨ នៃច្បាប់រៀបចំទឹកដី នគររូបនីយកម្ម និង សំណង់ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានបង្កើតឡើងក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង សំណង់ ។ គណៈកម្មការនេះ ត្រូវដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ។

គណៈកម្មការនេះពិនិត្យរាល់សំណុំលិខិតសុំអនុញ្ញាតសាងសង់ ។

ចំពោះលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគររូបនីយកម្ម និងសំណង់ ក្រោយពីគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ពិនិត្យសំណុំលិខិតហើយ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង និង អភិបាលខេត្ត-ក្រុង បញ្ជូនរបាយការណ៍ និង យោបល់ទៅគណៈកម្មាធិការជាតិរៀបចំទឹកដី នគររូបនីយកម្ម និង សំណង់ ដើម្បីសំរេច ។

៦.២ សមាសភាពរបស់គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ :

គណៈកម្មការមានសមាសភាពដូចតទៅ :

- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ជាប្រធាន
- មន្ទីរ សុរិយោដី សមាជិក
- មន្ទីរ រៀបចំក្រុង និង សំណង់ ឬ ការិយាល័យសំណង់ ក្នុងករណីដែលមាន សមាជិក
- មន្ទីរ សាធារណការ សមាជិក

- មន្ទីរ បរិស្ថាន                                        សមាជិក
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ                              សមាជិក
- តំណាងស្ថាប័នពាក់ព័ន្ធទៅលើគំរោងសំណង់នោះ                    សមាជិក
- ការិយាល័យ (មូលដ្ឋាន) កិច្ចការនគរូបនីយកម្ម                    សមាជិក

គណៈកម្មការមានសិទ្ធិកោះអញ្ជើញដើម្បីសាកសួរ ឬស្ដាប់រាល់បុគ្គលដែលបានដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និង ម្ចាស់កម្មសិទ្ធិ បើម្ចាស់កម្មសិទ្ធិនោះពុំមែនជាអ្នកដាក់ពាក្យសុំ នៅពេលដែលសំណុំលិខិតអនុញ្ញាតសាងសង់នោះ បានចុះបញ្ជីជាផ្លូវការរួចហើយ ។

## ជំពូក ៣

## ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៧ : គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយ អាចចេញអោយបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី (ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬ ប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាត ត្រូវអនុវត្តតាមបទបញ្ញាទូទៅស្ដីពីការប្រើប្រាស់ដីធ្លីវិញ ។

ជនទាំងឡាយដូចជា នីតិបុគ្គល សាធារណៈ ឬ ឯកជន ត្រូវគោរពវិធានការនេះជាចាំបាច់ ។

មាត្រា ៨ : សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញ និង ទីក្រុងដទៃទៀត ត្រូវដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់) ហើយ ចំពោះខេត្ត ត្រូវដាក់នៅសាលាស្រុក ឬ សាលាខេត្ត (មន្ទីរសំណង់) ។ បង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានចេញអោយអ្នកសុំ កាលណាសំណុំលិខិតពាក្យសុំមានគ្រប់គ្រាន់ហើយ ។

មាត្រា ៩ : **បណ្ដាឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្ដាប្លង់ដូចបញ្ជាក់ខាងក្រោមនេះ ជា១០ច្បាប់ បត់ទំហំ (២១×២៩,៧ស.ម) :

៩.១ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្ដោះអាសន្ន ។

៩.២ សលាកប័ត្រដីឡូតិ៍ :

ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬ ដោយវេខាគណិតឯកជន ។ ប្លង់នេះ ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និង អនុម័តដោយមន្ទីរសុរិយោដី ។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ទីតាំងនៃដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតាំងនៃដីឡូតិ៍ដែលនៅជាប់ផ្លូវ ផ្លូវចូលទៅដីឡូតិ៍នោះ ហើយនិងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬ ឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។
- ឈ្មោះ ឬ លេខ ផ្លូវធំ និង ផ្លូវតូច

- ផ្ទៃក្រឡាដីឡូតិ៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ ( ទីតាំង និង កំពស់ )
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ជាប់គ្នា ផ្ទៃបាត និងកំពស់របស់វា
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនឹងថ្កល់សំរាប់ជាគោលសំគាល់កំពស់ ដែលបោះនៅលើដីឡូតិ៍
- បន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ

៩.៣ ប្លង់ទីតាំងអគារក្នុងដីឡូតិ៍ :

មាត្រដ្ឋាន ១:២០០ (ឬ ១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូតិ៍ធំ ។ )។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការបញ្ជាក់អំពីចម្ងាយ រវាងអគារមួយឬច្រើន និង ព្រំប្រទល់ដីឡូតិ៍ ហើយនិងចំងាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់ ។

- រាល់ការរៀបចំផ្នែកផ្សេងៗ នៃដីទំនេរ ដោយបញ្ជាក់ប្រភេទដីនិងដំណាំមានស្រាប់ និង ទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កំពស់ និង ទីតាំង) ។

- បំពង់លូក្រៅអគារ (រូបធាតុ វិជ្ជមាត្រ ចំណោត កំរិតកំពស់ រណ្តៅពិនិត្យ) រហូតដល់ កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សំរាប់បញ្ចេញទឹកស្អុយ និងសំរាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង។

- ចំណុចនឹងថ្កល់នៃកំពស់ដីឡូតិ៍ ក្រោយការងាររៀបចំហើយ ។

៩.៤ ប្លង់អគារគ្រប់ជាន់ : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់នេះមានបញ្ជាក់ពី :

- គោលដៅប្រើប្រាស់រាល់បន្ទប់ និង ផ្ទៃក្រឡារបស់វា
- បណ្តាបន្ទប់ទឹកអនាម័យ និង កន្លែងដាក់បំពង់លូ
- ចំពោះការរៀបចំទីតាំងឧស្សាហកម្ម : របៀបរៀបចំទីតាំងគ្រឿងយន្ត

៩.៥ ប្លង់ផ្នែកបណ្តាញក្រោមដីនាទា និង អាងបង្គន់អនាម័យ មាត្រដ្ឋាន ១ : ១០០

៩.៦ ប្លង់មុខភាពនៃអគារ : (Façades) មាត្រដ្ឋាន ១ : ១០០

នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី :

- កំរិតកំពស់កំរាលនីមួយៗ កំរិតកំពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកំពស់ដីធម្មជាតិ ដីចាក់បំពេញ ឬ ដីចូកចេញ ។

- កំរិតកំពស់ដំបូល និង ព្រំដំបូល ឬ កំរិតកំពស់នៅពេលសង់ហើយនៃអ៊ីប៉ូលតែរ៉ាស និង ក្បាំងក្បាលជញ្ជាំង ។

- កំរិតកំពស់សង់ហើយនៃទ្រើងផ្សារ

- រូបធាតុសំរាប់មុខភាព (Matériaux de façade)

៩.៧ ប្លង់ពុះពីរយ៉ាងតិច : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់ពុះមានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញអាងបង្គន់អនាម័យ ។

៩.៨ តារាងផ្ទៃក្រឡាមួយសំរាប់ជាន់នីមួយៗ

៩.៩ សលាកប័ត្រគណនាផ្ទៃបាតផ្ទាល់ដី និង សន្ទស្សន៍នៃការប្រើប្រាស់ ។

ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើ ប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះផ្នែកមានពីមុន ការរុះរើ និង សភាពគ្រោងធ្វើ ។

សាលាក្រុង និង សាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និង ឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់ ។

អាចអោយអ្នកសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ការពារបេតិកភ័ណ្ឌ និង ទេសភាព ។

៩.១០ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និង ដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

មាត្រា ១០ : ភាសាផ្លូវការ

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬ បារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ ។

មាត្រា ១១ : ហត្ថលេខាលើពាក្យសុំ

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្តាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគំរោង ។

កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ ។

អ្នកធ្វើគំរោងត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយគណៈស្ថាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះ ត្រូវបានបង្កើតឡើង ។

ក្នុងករណីដែលសំណង់មានទំហំលើសពី ៥០០ ម៉ែត្រទ្វេគុណ គំរោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ ។

មាត្រា ១២ : ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និង អង្កេតសាធារណៈ

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណៈជន អំពីការដាក់ពាក្យសុំដោយបិទប្រកាសផ្សាយនៅសាលាខ័ណ្ឌ ស្រុក ខេត្ត និងនៅកន្លែង សាងសង់ គម្រោង ។

កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យស្នើសុំ ត្រូវចារក្នុងសំណុំលិខិត ហើយជូនដំណឹងដល់អ្នកស្នើ ។

ម៉្យាងទៀតចំពោះអគារ និង បណ្ដាការ្យធំៗ ឬ ដែលមានប្រភេទអាចធ្វើអោយរំខានដល់សុវត្ថិភាព សុខមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាននៅតាមមូលដ្ឋាន ។

ប្រកាសមួយរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ កំណត់បញ្ជីអគារ និង ការ្យដែលពាក់ព័ន្ធ ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់ ) ចំពោះក្រុងភ្នំពេញ និងសាលាស្រុក ឬសាលាខេត្ត (មន្ទីរសំណង់)ចំពោះខេត្ត ក្នុងរយៈពេល ២៥ ថ្ងៃ និងអាចធ្វើការតវ៉ា ឬ ទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច ។

បណ្ដឹងតវ៉ាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និង ធ្វើរបាយការណ៍មួយជូនទៅសាលាខេត្ត សាលាក្រុង ក្នុងរយៈពេល ៥ ថ្ងៃ ។ សាលាខេត្ត សាលាក្រុង ឬ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសំរេចអំពីសុពលភាពនៃបណ្ដឹងតវ៉ា ។

**មាត្រា ១៣ : អង្កេតនៅតាមបណ្ដាមន្ទីរមានសមត្ថកិច្ច**

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និង សំណង់ នៃបណ្ដាខេត្ត-ក្រុង ប្រមូលយោបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើសំយោគមួយ ។

យោបល់ និង សំយោគទាំងនោះជាលាយល័ក្ខអក្សរ ត្រូវដាក់ជូនអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និង សំរេច ។

បណ្ដាមន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់ ក្នុងពេលពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់រួមមាន :-

- មន្ទីរសុរិយោដី
- មន្ទីររៀបចំក្រុង និង សំណង់
- មន្ទីរសាធារណៈការ
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
- មន្ទីរហិរញ្ញវត្ថុ
- មន្ទីរបរិស្ថាន
- និងតំណាងស្ថាប័នពាក់ព័ន្ធ

**មាត្រា ១៤ : រយៈពេលពិនិត្យសំណុំលិខិត**

រយៈពេលសំរាប់ពិនិត្យសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ត្រឹម ៤៥ ថ្ងៃធ្វើការ ។ រយៈពេលនេះគិតចាប់ពីថ្ងៃ ដែលរាល់លិខិតស្នាមភ្ជាប់ជាមួយនឹងពាក្យសុំលិខិត អនុញ្ញាតសាងសង់បានបំពេញ

សព្វគ្រប់ ។ នៅចុងរយៈពេលកំណត់នេះ អ្នកស្នើសុំត្រូវបានទទួលដំណឹងអំពីសេចក្តីសម្រេច ជាលាយលក្ខណ៍អក្សរ ស្តីពីការអនុញ្ញាត ឬ ការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែរ តែស្នើសុំអោយកែសំរួលបន្ថែម ។

ក្នុងករណីគ្មានចម្លើយណាមួយពីអាជ្ញាធរ នោះត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន ។

កាលបរិច្ឆេទថ្ងៃទី ០១ នេះ ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ដោយមន្ទីររៀបចំក្រុង និង សំណង់ក្នុងករណីផ្សេងទៀត ។

បើអាជ្ញាធរមានសមត្ថកិច្ច បានស្នើដល់អ្នកសុំអោយធ្វើការកែប្រែតម្រូវនោះ រយៈពេល ៤៥ ថ្ងៃធ្វើការថ្មីមួយទៀត នឹងត្រូវគិតចាប់ពីថ្ងៃដាក់ពាក្យសុំមានការកែតម្រូវជាផ្លូវការ ។

ការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំអោយកែសំរួល ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកសុំ ដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូក ៤

## ទម្រង់បែបបទបន្ទាប់ពីបានលិខិតអនុញ្ញាតសាងសង់

**មាត្រា ១៥ : ការប្រគល់លិខិតអនុញ្ញាតសាងសង់**

លិខិតអនុញ្ញាតសាងសង់ ត្រូវប្រគល់អោយអ្នកសុំដោយអាជ្ញាធរដែលបានអនុញ្ញាតអោយ ។

លិខិតអនុញ្ញាតសាងសង់មួយច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្នាមជាឧបសម្ព័ន្ធផ្សេងៗ...) ត្រូវរក្សាទុកជាឯកសារជាច់ខាត ដោយសាលាខេត្ត ឬ សាលាក្រុង ។

ក្នុងករណីដែលលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ត្រូវរក្សាទុកជាឯកសារ ១ ច្បាប់ផងដែរ ។

**មាត្រា ១៦ : លិខិតអនុញ្ញាតសាងសង់ផុតកំណត់កាល និង ការងារបោះបង់ចោល**

១៦.១ លិខិតអនុញ្ញាតសាងសង់អស់សុពលភាព បើការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់ ។

លិខិតនេះ អាចអនុញ្ញាតពន្យារពេលបានមួយដង ។

សំណង់ដែលត្រូវចាត់ទុកថាបានចាប់ផ្តើមសាងសង់ កាលណាជើងគ្រឹះត្រូវបានធ្វើហើយ ។

ចំពោះការសាងសង់បន្ថែមជាន់ ត្រូវចាត់ទុកថាបានចាប់ផ្តើម កាលណាសសរទីមួយត្រូវបានធ្វើហើយ។

១៦.២ កាលណាការងារសាងសង់ ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬ ខេត្ត អាចបង្ខំអោយធ្វើបញ្ចប់ ឬបង្ខំអោយរុះរើសំណង់ដែលបានចាប់ផ្តើម និងអោយរៀបចំទីកន្លែងអោយបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ និងដោយសោហ៊ុយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់ ។

ក្នុងករណីពុំបានរើយកសំភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខ័ណ្ឌ ឬ សាលាស្រុកមានភារកិច្ច ចាត់ចែងដឹកជញ្ជូនចេញដោយស្វ័យប្រវត្តិ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

<u>មាត្រា ២០</u> : ការត្រួតពិនិត្យ និង ការបញ្ឈប់ការងារ

អាជ្ញាធរក្រុង ឬ ខេត្ត អាចចូលមើលនិងត្រួតពិនិត្យការដ្ឋានគ្រប់ពេលវេលា ហើយនិងពិនិត្យប្លង់ដែលបានអនុម័តរួច ។ បើពិនិត្យឃើញភាពមិនត្រឹមត្រូវ អាជ្ញាធរនោះជំរាបជាលាយល័ក្ខណ៍អក្សរទៅម្ចាស់សំណង់ អោយកែតម្រូវក្នុងរយៈពេលកំណត់មួយ ។

ក្នុងករណីពុំបានអនុវត្ត ឬ បានអនុវត្តពុំត្រឹមត្រូវតាមបញ្ជា ការផ្អាកការងារត្រូវចេញបញ្ជាជាបន្ទាន់ដោយអាជ្ញាធរ ក្រុង ឬ ខេត្ត ។

សាលាក្រុង ឬ សាលាខេត្ត អាចប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញដីកាកិច្ចការប្រញាប់ អោយផ្អាកការសាងសង់ ឬ ផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬគ្មានច្បាប់នោះ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

អនុលោមទៅតាមសភាពធ្ងន់ធ្ងរនៃការខុសឆ្គង បណ្តាសំភារៈនិងឧបករណ៍សំភារៈរបស់ការដ្ឋាន អាចត្រូវរឹបអូសតាមបង្គាប់តុលាការ ។

<u>មាត្រា ២១</u> : វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ

អ្នកសុំលិខិតអនុញ្ញាតសាងសង់ ត្រូវប្រកាសប្រាប់អំពីការចប់ការងារ ដល់សាលាខ័ណ្ឌ ឬសាលាស្រុក។

ពេលបញ្ចប់ការដ្ឋាន សាលាខ័ណ្ឌ ឬសាលាស្រុកជាមួយនិងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (បន្ទីរ រៀបចំក្រុង និង សំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នា រវាងសំណង់ដែលធ្វើរួចហើយ និង លិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ត្រូវចាត់ទុកថាពុំត្រឹមត្រូវ បើផ្ទៃបាតសំណង់ ឬ ផ្ទៃក្រឡាកម្រាលបានសាងសង់ លើសពីកំរិតអនុញ្ញាត។

អាចចាត់ទុកថាពុំត្រឹមត្រូវ បើទិដ្ឋភាពនៃអគារមានភាពងាយឃើញខុសគ្នា ពីលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីពុំត្រឹមត្រូវទេ អាជ្ញាធរក្រុង ឬ ខេត្តអាចបង្ខំម្ចាស់សំណង់ អោយកែតម្រូវអគារអោយបានត្រឹមត្រូវ ស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីមិនគោរពតាមទេ សាលាក្រុង ឬសាលាខេត្ត ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច អោយចេញសាលក្រម ឬ សាលដីកា ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ដែលចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ជានិច្ច ចំពោះបណ្តាអគារសំរាប់ទទួលសាធារណៈជន សណ្ឋាគារ ការិយាល័យ ក៏ដូចជាចំពោះបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ។ វិញ្ញាបនប័ត្រនេះ ត្រូវបានទទួលមុនការបើកប្រើប្រាស់កន្លែងធ្វើការនោះ ។

មាត្រា ១៧ : **ការចាប់ដំណើរការការដ្ឋាន**

ការដ្ឋាន ពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័ត លើប្លង់លំអិតគ្រឿងផ្គុំសំណង់ឡើយ ។

រាល់សហគ្រិនទទួលបន្ទុកស្ថាបនាសំណង់ ត្រូវបញ្ជាក់អោយដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ពីព្រោះជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់ ។

អ្នកកាន់លិខិតអនុញ្ញាតសាងសង់ ត្រូវតំកល់ទុកនៅការដ្ឋាន នូវសេចក្តីចម្លងឯកសាររដ្ឋបាលពីការចេញលិខិតអនុញ្ញាតសាងសង់មួយច្បាប់ សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

ប្លង់អនុវត្តការសាងសង់ និង ប្លង់លំអិតសំណង់មួយច្បាប់ ត្រូវតំកល់ទុកជាប្រចាំនៅការដ្ឋាន សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

មាត្រា ១៨ : **ដំណើរការទៅមុខនៃការងារ**

១៨.១ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ និង ប្លង់លំអិតគ្រឿងផ្គុំសំណង់ ហើយម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលាស្រុក-ខ័ណ្ឌ និង ចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច ។

មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋាន ពីមន្ទីររៀបចំក្រុង និងសំណង់ ឬការិយាល័យខេត្ត-ក្រុង ។

ស្ថាប័នសមត្ថកិច្ចបច្ចេកទេស ត្រូវតាមដានការអនុវត្តជាជំហាន ៗដូចតទៅ :

- ក្រោយការបោះបង្គោលកំណត់ទីតាំងសំណង់
- ក្រោយការងារផ្នែកគ្រឹះ និងមុនការធ្វើកម្រាលក្រោមនៃជាន់ផ្ទាល់ដី
- នៅទីបញ្ចប់នៃការងធំៗ (គ្រឹះ-សសរ-ជញ្ជាំង-កម្រាល...) ផ្នែកសំខាន់ៗ នៃសំណង់
- នៅពេលតភ្ជាប់ទៅបណ្តាញលូទឹកស្អុយ ទឹកស្អាត និង បណ្តាញអគ្គីសនី

១៨.២ រាល់ការផ្លាស់ប្តូរម្ចាស់សំណង់ ក្នុងពេលកំពុងដំណើរការសាងសង់ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ។

មាត្រា ១៩ : **ការរៀបចំការដ្ឋានសំណង់**

ការដាក់គរសំភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់ :

- កាលណាសំណង់ ត្រូវការកន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈ កន្លែងលយនោះត្រូវកំណត់ត្រឹម ២ម ទៅលើចិញ្ចើមផ្លូវ ។ កន្លែងនោះត្រូវធ្វើរបងហ៊ុំព័ទ្ធ ក្នុងរយៈពេលដំណើការរបស់ការដ្ឋាន ។
- រាល់កន្លែងតាំងការដ្ឋាន ត្រូវរុះរើចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការដ្ឋាន។
- ជំនរសំភារៈ កាកសំណល់បានមកពីការរុះរើ ឬពីការសាងសង់ ឬការជួសជុលត្រូវយកចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការងារ ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន មុនពេលបើកអោយប្រើប្រាស់ ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន និងទេសភាពធម្មជាតិ ឬ ក្រុង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភ័ណ្ឌ ឬនៅកន្លែងមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រណាមួយ ។

## ជំពូក ៥
## លិខិតអនុញ្ញាតរុះរើ

មាត្រា ២២ : រាល់ម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលសិទ្ធិតំណាងក្នុងអាណត្តិ ដែលមានបំណងរុះរើអគារណាមួយដែលមានស្រាប់ ក្រៅពីសំណង់បណ្តោះអាសន្នមិនឋិតថេរ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតរុះរើ នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ។

សំណុំពាក្យសុំលិខិតអនុញ្ញាតរុះរើត្រូវមាន :

ប្លង់ដីឡូតិ៍ និង ប្លង់អគារ រូបថតអគារ ឬឯកសារផ្សេង ៗ ទៀតដែលចាំបាច់ ។

ចំពោះរាល់អគារដែលមានចុះក្នុងបញ្ជីបេតិកភ័ណ្ឌ ពាក្យសុំអនុញ្ញាតរុះរើ ត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ។

លិខិតអនុញ្ញាតរុះរើ ត្រូវផ្សព្វផ្សាយភ្លាមជាសាធារណៈ ដោយការបិតប្រកាសនៅកន្លែងដែលអាចមើលឃើញពីផ្លូវសាធារណៈ នៅកន្លែងគ្រោងធ្វើការរុះរើ ។ ការងាររុះរើ ពុំអាចចាប់ផ្តើមក្នុងរយៈពេលតិចជាង ១៥ ថ្ងៃ បន្ទាប់ពីការចេញលិខិតអនុញ្ញាតឡើយ ។

លិខិតអនុញ្ញាតរុះរើ ត្រូវចាត់ទុកយល់ព្រម បើពុំមានចំឡើយណាមួយក្រោយពីថ្ងៃដាក់ពាក្យសុំ ៣ខែ ។

រាល់ជំទាស់ ត្រូវផ្តល់ដំណឹងទៅអ្នកសុំជាលាយល័ក្ខណ៍អក្សរ ។

មាត្រា ២៣ : បណ្តាបទបញ្ញត្តិពីសមត្ថកិច្ច និង ការពិនិត្យពាក្យសុំដែលអនុវត្តចំពោះលិខិតអនុញ្ញាតសាងសង់ ត្រូវអនុវត្តបានដូចគ្នាចំពោះពាក្យសុំលិខិតអនុញ្ញាតរុះរើ ។

## ជំពូក ៦
## បទល្មើស និង បណ្តឹងតវ៉ា

មាត្រា ២៤ : **ករណីបទល្មើស**

រាល់សំណង់ ដែលបានចាប់ផ្តើមដំណើរមុនចេញលិខិតអនុញ្ញាតសាងសង់ ដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់ទុកជាល្មើសច្បាប់ ។ ការដ្ឋានត្រូវបញ្ឈប់ជាបន្ទាន់ ។

បណ្តាបុគ្គល ដែលបានប្រព្រឹត្តល្មើសនឹងបញ្ជារបស់មន្ត្រី និង ភ្នាក់ងាររបស់រាជការ ត្រូវផាកពិន័យ ហើយឧបករណ៍ទាំងឡាយនៅក្នុងការដ្ឋានត្រូវរឹបអូស ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាបចលហុ ។ បើពុំព្រមបញ្ឈប់ការងារ ត្រូវបញ្ជូនជនល្មើសទៅតុលាការ ដែលត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

មាត្រា ២៥ : **បណ្តឹងតវ៉ា**

រាល់សេចក្តីសំរេចទាក់ទងនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ មុនឡើងទៅតុលាការមានសមត្ថកិច្ច អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុងមាត្រា ៤ និង ៥ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការពិនិត្យលើបណ្តឹងតវ៉ានេះ ។

អាជ្ញាធរមានសមត្ថកិច្ច មាននីតិសម្បទាសំរបសំរួលជាមួយម្ចាស់បណ្តឹង ។ ក្នុងករណីមិនបានសំរេច អ្នកប្តឹងអាចតវ៉ា ទៅដល់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ បើអាជ្ញាធរមានសមត្ថកិច្ចជាអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬនឹងទៅដល់នាយករដ្ឋមន្ត្រី បើអាជ្ញាធរមានសមត្ថកិច្ច ជា តំណាងរាជរដ្ឋាភិបាល ។

សំរាប់កិច្ចការនេះ ត្រូវបានបង្កើតថ្លៃកវិវាទមួយនៅគ្រប់សាលាខេត្ត ឬសាលាក្រុង និងក្នុងគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

## វគ្គទី ២

## **បទបញ្ជាទូទៅនៃការប្រើប្រាស់ដី-ធ្លី**

មាត្រា ២៦ : បទបញ្ជាទូទៅនៃការប្រើប្រាស់ដី-ធ្លីនេះ ត្រូវយកមកអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយតំរូវអោយរាល់បុគ្គលសាធារណៈ និង ឯកជន ជារូបវន្តបុគ្គលក្តី ឬ នីតិបុគ្គលក្តី គោរពប្រតិបត្តិតាមលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលដែលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង ប្លង់គោលនៅឡើយនោះ ។

### ជំពូក ១

### **ប្រភេទ ការកំណត់ទីតាំង និង ផ្លូវចាក់ចេញចូលរបស់ទីតាំងសំណង់**

មាត្រា ២៧ : **សុវត្ថិភាព និង សុខមាលភាពសាធារណៈ**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ឬ ទំហំ មានលក្ខណៈនាំអោយប៉ះពាល់ដល់សុខមាលភាព ឬ ដល់សុវត្ថិភាពសាធារណៈ នាំអោយរំខាន ឬ បណ្តាលអោយមានមហន្តរាយ ។

២៧.១ ទីដីគ្រោះថ្នាក់ ( ទីដីដែលអាចមានគ្រោះថ្នាក់ )

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះទីដីដែលអាចមានមហន្តរាយ តំបន់ជាក់ស្តែងរយៈ តំបន់ដីសើមដែលត្រូវការពារ តាមមាត់ច្រាំង ទន្លេ ព្រែក ស្ទឹង បឹងបួរ ដែលពុំមានភាពរឹងមាំគ្រប់គ្រាន់

ហើយអាចបណ្តាលអោយមានគ្រោះថ្នាក់ ចំពោះសុវត្ថិភាពរបស់មនុស្ស និងសម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោល ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីអាចលិចទឹក កាលណាសំណង់នោះស្ថិតតាមមាត់ច្រាំងទន្លេ ឃើព្រែក ស្ទឹង ឬបឹង បណ្តាលអោយថយចុះលទ្ធភាពរក្សាទឹកទុក ឬ លទ្ធភាពបង្ហូរទឹកពីទីដីនោះ និង ទីដីជិតខាង និងប៉ះពាល់ដល់គុណភាពទឹក ។

២៧.២ ធាតុរំខានដោយសម្លេង

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ឬអាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស បើសំណង់នោះអាចត្រូវទទួលរងធាតុរំខានដោយសំលេងខ្លាំង ៗ ឬ បើសំណង់នោះអាចបង្កធាតុរំខានដោយសំលេងខ្លាំង ៗ ។

**មាត្រា ២៨ : ការការពាររមណីយដ្ឋាន**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះមានប្រភេទ ទំហំ ឬ ទីតាំង អាចបណ្តាលអោយអន្តរាយដល់ការអភិរក្ស ឬ អន្តរាយដល់ការលើកតំលៃនៃរមណីយដ្ឋានធម្មជាតិ ឬក្រុង ឬ កេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ និងបុរាណវត្ថុ ឬ អាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស ។

**មាត្រា ២៩ : បណ្តាញផ្លូវតាក់ព័ន្ធ និង ចំណត**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីដែលពុំមានផ្លូវចេញ-ចូល ដូចជា : ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬ ផ្លូវឆ្លងកាត់ ដែលទទឹងត្រូវសមាមាត្រសមស្របទៅនឹងទំហំ និងការប្រើប្រាស់នៃអគារ ។

រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សំរាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬ ច្រើន ពុំអាចមានទទឹងតិចជាង ៣,៥០ម ដែលជាទំហំចាំបាច់សំរាប់អោយរថយន្តពន្លត់អគ្គីភ័យចូលបាន ។

ចំណតរថយន្ត ត្រូវមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់អគារ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ។

បទដ្ឋានចំណតរថយន្តត្រូវបានកំណត់ដោយបណ្តាសាលាក្រុង និងសាលាខេត្ត ប៉ុន្តែពុំអាចតិចជាង :

- ចំពោះសណ្ឋាគារ :
  - . ចំណតរថយន្តតូច ១កន្លែង សំរាប់ ៥ បន្ទប់
  - . ចំណតរថយន្តធំ ១កន្លែង សំរាប់ ៣០ បន្ទប់
- ចំពោះការិយាល័យឯកជន និង រដ្ឋបាលសាធារណៈ
  - . ចំណតរថយន្ត ១កន្លែង សំរាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ ២៥០ម៉ែត្រទ្រើតុណេ

- ចំពោះបណ្តាសកម្មភាព ឧស្សាហកម្ម សិប្បកម្ម និងឃ្លាំងស្តុកទំនិញ ចំនួនចំណតរថយន្តត្រូវមាន គ្រប់គ្រាន់សំរាប់ការលើកដាក់ ផ្ទុក និង ផ្ទេរទំនិញនៅក្រៅពីផ្លូវសាធារណៈ និងចំណតរថយន្តគ្រប់ប្រភេទ នៅក្នុងបរិវេណដីឡូត៍ ។

**មាត្រា ៣០: ការបោះទីតាំងសំណង់ តាមដងផ្លូវសាធារណៈ**

៣០.១ ការបោះទីតាំងសំណង់នៅតាមដងផ្លូវជាតិ និង ផ្លូវទំនប់ព័ទ្ធជុំវិញទីក្រុង អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ ត្រូវកំណត់ដោយមានការយល់ព្រម ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ នូវដីចំណីសាធារណៈ និងផ្លូតម្លូតនៃផ្លូវជាតិ ផ្លូវសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និង នគរោបនីយកម្ម ជាអាទិផ្លូវទំនប់ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ នៅក្នុងតំបន់ដែលបានរៀបរាប់ខាងលើ ។

៣០.២ ការបោះទីតាំងសំណង់ នៅតាមដងផ្លូវសាធារណៈក្នុងក្រុង

សំណង់ទាំងឡាយ ត្រូវបោះទីតាំងលើជួរតម្រង់ផ្លូវសាធារណៈ ឬឃ្លាតថយពីជួរតម្រង់យ៉ាងតិច ៤ម ។

នៅតាមច្រកផ្លូវ បណ្តាសំណង់អាចបោះទីតាំងលើជួរតម្រង់ផ្លូវច្រក ។

អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ កំណត់ជួរតម្រង់នៃផ្លូវសាធារណៈ និង ផ្លូតម្លូតលើប្លង់មួយហៅថា ប្លង់ជួរតម្រង់ ។ ប្លង់ជួរតម្រង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ចំពោះក្រុងទាំងឡាយណាដែលមានប្រជាជនលើសពី ២០.០០០នាក់ ។ ប្លង់ទាំងនោះ ត្រូវផ្សព្វផ្សាយអោយសាធារណៈជនបានដឹង ។

**<u>មាត្រា ៣១</u> : ការផ្គត់ផ្គង់ទឹកស្អាត និង ការបញ្ចេញចោលទឹកកខ្វក់**

៣១.១ ការផ្គត់ផ្គង់ទឹកស្អាត ត្រូវធានាអោយបានចំពោះរាល់សំណង់ ដែលតំរូវអោយមានលិខិតអនុញ្ញាតសាងសង់ ។

ក្នុងករណីដែលបណ្តាញទឹកស្អាត ពុំផ្គត់ផ្គង់អោយទៅដល់ទីដីដែលនៅលើទីដីនោះ មានសំណង់មួយត្រូវបានគ្រោងទុកនោះ អ្នកស្នើសុំត្រូវបង្ហាញភស្តុតាងថា ខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន និងបញ្ជាក់ថាតាមមធ្យោបាយអ្វី ទោះបីតាមការបន្តភ្ជាប់ទៅនឹងបណ្តាញទឹកស្អាតណាមួយដែលនៅជិត ឬជាអណ្តូងទឹកដែលមានស្រាប់នៅជិតនោះ ឬដែលត្រូវជីកថ្មីក្តី ។

អ្នកស្នើសុំត្រូវបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្តូង និងគុណភាពទឹក ។ ក្នុងករណីការប្រើប្រាស់អណ្តូងសមូហភាព សំណុំលិខិតនៃលិខិតអនុញ្ញាតសាងសង់ ត្រូវមានសេចក្តីយល់ព្រមឱ្យប្រើប្រាស់ទឹកជាលាយលក្ខណ៍អក្សរ ។

៣១.២ បណ្តាដីឡូត៍ ឬសំណុំលំនៅដ្ឋាន ត្រូវតែមានការផ្គត់ផ្គង់ដោយបណ្តាញចែកចាយទឹកស្អាត និងមានប្រព័ន្ធលូទឹកស្អុយ ដែលនាំបង្ហូរចេញដល់ទីដៅតែម្តង ដោយគ្មានកន្លែងណាមួយអាចអោយទឹកស្អុយដក់នៅបាន ។

៣១.៣ – ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយ ម្ចាស់សំណង់មានកាតព្វកិច្ចត្រូវគ្រោងសំអាត និងបញ្ចេញទឹកដែលប្រើប្រាស់ហើយទៅទីធម្មជាតិ តាមរយៈអាងបង្គន់អនាម័យ និងបណ្តាញបំពង់មានប្រហោងរាយកប់ក្នុងដី ។

បណ្តាញនេះបែងចែកទឹកដែលចេញពីបង្គន់អនាម័យ នៅក្រោមដីធ្វើអោយជ្រាប និង ជម្រះបាន ។

ម្ចាស់កម្មសិទ្ធនៅក្នុងក្រុង ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យ ហើយបន្តភ្ជាប់ទៅប្រព័ន្ធលូ ។

បទដ្ឋានអាងបង្គន់អនាម័យ កំណត់ដូចតទៅ :

ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យ ដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញ :

- ជាអប្បបរមា ៣ម៉ែត្រត្រីគុណសំរាប់លំនៅដ្ឋានមួយ ឬ ៣ម៉ែត្រត្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ ឬ ៣ម៉ែត្រត្រីគុណសំរាប់ផ្ទៃក្រឡាកំរាលសរុបទំហំ ៨០ម៉ែត្រទ្វេគុណ ។

ចំពោះសណ្ឋាគារ ២ ម៉ែត្រត្រីគុណ បូកបន្ថែម ០,៥ម៉ែត្រត្រីគុណក្នុងមួយបន្ទប់ :

- កំពស់អាងបង្គន់អនាម័យពុំអាចទាបជាង ១,៥០ម ។
- អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយបន្តខ្ពស់ទៅលើ ។
- មិនត្រូវអោយទឹកភ្លៀងហូរចូលទៅក្នុងអាងបង្គន់អនាម័យជាដាច់ខាត ។

៣១.៤ – សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និង ប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើពុំបង្ហាញការធានាគ្រប់គ្រាន់អំពីអនាម័យ និងសុខមាលភាពចំពោះសំណង់ដែលបានគ្រោង និងបណ្តាសំណង់នៅជុំវិញដែលមានស្រាប់ ។

**<u>មាត្រា ៣២</u> : តំបន់មិនអាចសាងសង់បាន**

ខេត្ត និង ក្រុង នីមួយៗ ត្រូវកំណត់ជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន ។

ប្លង់នេះ ត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និង រ៉ែ ដែលជាគោលដៅប្រើប្រាស់ពុំអាចផ្លាស់ប្តូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ច និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជា ឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួរ ដោយមូលហេតុផលប្រយោជន៍បេតិកភ័ណ្ឌ និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍ សំរាប់បង្ហូរទឹកភ្លៀងចេញ និង ការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ ។

អាជ្ញាធរតាមមូលដ្ឋានត្រូវចាត់វិធានការសមស្រប ដើម្បីការពារ និងបង្កើនគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ ។

រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំឱ្យជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់ ។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការផាកពិន័យ និង ចាត់អោយរុះរើ និងធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំអោយអ្នកល្មើសច្បាប់ ត្រូវតែចេញសោហ៊ុយចំណាយទាំងអស់នោះ ឬ ក្នុងករណីចាំបាច់ អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការ ដើម្បីអោយចេញដីការកិច្ចការប្រញាប់បញ្ជាអោយរុះរើ ។

ប្លង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការ ផ្នែករាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រីជំនាញទទួលខុសត្រូវលើ << តំបន់មិនអាចសាងសង់បាន >> ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីអោយមានការគោរពតំបន់ទាំងនោះទេ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន ។

## មាត្រា ៣៣ : ផលប៉ះពាល់ពីសំណង់ឧស្សាហកម្ម

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់សំណង់ឧស្សាហកម្ម ត្រូវបញ្ជាក់អំពីការបំពុលបណ្តាលមកពីសកម្មភាពឧស្សាហកម្ម និងវិធីដែលបានគ្រោងទុក ដើម្បីលុបបំបាត់ការបំពុលទាំងនោះ ។

គំរោងស្ថានីយសំរាប់ធ្វើសំរាតតាមយថាប្រភេទ ត្រូវមានបញ្ចូលក្នុងសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ។

រាល់កាកសំណល់ពីឧស្សាហកម្ម ត្រូវតែបានទទួលការសំរាតជាមុន ដើម្បីបង្ការកុំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬ សុខភាពសាធារណៈ ។ ទឹកកខ្វក់សំណល់ឧស្សាហកម្ម ពុំត្រូវឱ្យលាយឡំជាមួយទឹកភ្លៀង និងជាមួយទឹកកខ្វក់ដទៃទៀត ហើយក៏ពុំត្រូវបង្ហូរចូលត្រង់ៗទៅកន្លែងធម្មជាតិ ដោយពុំបានធ្វើការសំរាតជាមុនឡើយ ។

ចម្ងាយអប្បបរមា ដែលត្រូវគោរពរវាងសំណង់ឧស្សាហកម្មមួយដែលមានធាតុកខ្វក់ និង លំនៅដ្ឋាននៅជិតបំផុត ត្រូវបានរដ្ឋអំណាចមូលដ្ឋានអនុវត្ត ស្របទៅតាមការណែនាំផ្ទាល់របស់រាជរដ្ឋាភិបាល ។

ចំពោះឃ្លាំងស្តុកឧទ្ទការ និង អាងប្រេងឥន្ធនៈទាំងឡាយ ត្រូវគោរពបទបញ្ញត្តិអន្តរជាតិ អនុម័តដោយរាជរដ្ឋាភិបាល ។

រាល់អំពើល្មើសនឹងបណ្តាបទបញ្ញត្តិខាងលើនេះ រដ្ឋអំណាចមូលដ្ឋានអាចបញ្ឈប់ផ្អាកសកម្មភាពជាបន្ទាន់ ហើយត្រូវរាយការណ៍ជូនស្ថាប័នជំនាញ ។ រដ្ឋអំណាច ត្រូវជូនដំណឹងតាមផ្លូវច្បាប់ដល់ម្ចាស់សំណង់ នូវបណ្តាបទបញ្ញត្តិដែលត្រូវគោរពតាម ។

## ជំពូក ២

## ការបោះទីតាំង និង ទំរង់ទំហំ

### មាត្រា ៣៤ : ការបោះទីតាំងធៀបនឹងព្រំដីឡូត៍ជិតខាង

ធៀបនឹងព្រំដីឡូត៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឌ្ឍសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា ២ម ពីព្រំ ។ ចន្លោះ ២ម នេះ ត្រូវទុកអោយនៅទំនេរពុំមានសំណង់អ្វីឡើយ ។

ហាមមិនអោយចោះទ្វារ ឬ បង្អួច នៅលើជញ្ជាំងអឌ្ឍសិទ្ធិ ឬជញ្ជាំងជាប់ព្រំ ។

ចំពោះសំណង់ជាប់ព្រំ ឬ សំណង់ជាជញ្ជាំងអឌ្ឍសិទ្ធិ នឹងមានកំណត់ក្នុងសេចក្តីណែនាំអនុវត្ត របស់គណៈ-កម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ តាមសំណើរបស់ខេត្ត-ក្រុង ។

ត្រូវបានចាត់ទុកថាជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និង ចន្លោះដើរក្នុងអគារ ។ បទបញ្ញត្តិនេះ ត្រូវដាក់អោយអនុវត្តផងដែរចំពោះសណ្ឋាគារ ។

ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ទុកថាជាបន្ទប់រស់នៅ ។

បទបញ្ញត្តិនេះ ក៏ត្រូវដាក់អោយអនុវត្តផងដែរ ចំពោះកន្លែងធ្វើការ ។ ក្នុងករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬ រោងជាងប្រើប្រាស់ជាទម្លាប់ ឬជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិនត្រូវការជាចាំបាច់នូវពន្លឺថ្ងៃ តាមមុខងារយថាប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ ស្ទូឌីយោភាពយន្ត ។ ល ។

សាលាក្រុង ឬ សាលាខេត្ត អាចមានសិទ្ធិអោយបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ ។

ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទបញ្ញត្តិដូចបានរៀបរាប់ខាងលើនេះទេ សាលាក្រុង ឬ សាលាខេត្ត អាចទាមទារអោយបង្កើតរបាំងការពារ កុំអោយមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង ។

របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀត ដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលអោយមានគំហើញត្រង់ ឆ្ពោះទៅលើអ្នកជិតខាង ។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬបេតុង ស្លាបព្រិលចាក់ប៉ើក ធ្វើពីឈើ ឬ កញ្ចក់ស្រអាប់ និង ស្លាបព្រិលនៅនឹងថ្កល់ ។

### មាត្រា ៣៥ : ផ្ទៃបាត

ចំពោះផ្ទះល្វែង និង អគារលំនៅដ្ឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូត៍ ពុំអាចលើសពី ៧៥% ឡើយ ។

ចំពោះផ្ទះជាលំនៅដ្ឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដីឡូត៍ ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ ។

ចំពោះអគារដែលមានយ៉ាងតិច ១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និង អគារឧស្សាហកម្ម ផ្ទៃបាតសំណង់ពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ ។

សាលាក្រុង និង សាលាខេត្ត ត្រូវកំណត់តំបន់រៀបចំក្រុង ដែលត្រូវយកបទបញ្ញាខាងលើនេះមកអនុវត្ត ហើយនិងត្រូវកំណត់បទបញ្ញត្តិពិសេស ចំពោះស្ថានភាពជាក់ស្ដែង ។

ត្រា ៣៦ : ប្លង់កំពស់

សាលាក្រុង និង សាលាខេត្តនីមួយៗ នឹងលើកគំរោងប្លង់កំពស់ក្នុងរយៈពេលមួយឆ្នាំ ក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់អោយតំបន់នីមួយៗនៃក្រុងនូវកំពស់អតិបរិមានៃសំណង់ ។

ប្លង់កំពស់នេះត្រូវគិតដល់ :

. កំពស់មធ្យមបច្ចុប្បន្នតាមសង្កាត់នីមួយ ៗ ។

. លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅដ្ឋាន ឧស្សាហកម្មនៅកណ្ដាលក្រុង ឬជាយក្រុង ដីចាក់បំពេញ ឬរឹង ការប្រើប្រាស់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ។ ល ។) ។

. ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្ដុកទំនិញ និង អគារឧស្សាហកម្ម...។ ល ។) ។

ប្លង់កំពស់នេះ ត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៣៧ : ការការពារប្រាង្គប្រាសាទ និង ទេសភាព

សាលាក្រុង និង សាលាខេត្តនីមួយ ៗ អាចកំណត់កំពស់អតិបរិមាទាបជាងកំពស់អតិបរិមាក្នុង << ប្លង់កំពស់ >> ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្រ រមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិត ៗ ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ឬ ដើម្បីរក្សាទុកនូវទស្សនវិស័យ នៃប្រាង្គប្រាសាទ និង ទស្សនវិស័យដ៏ស្អិតស្អែ ។

ការបន្ថយកំពស់នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និង ប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ ។

## ជំពូក ៣

## ទិដ្ឋភាពនៃសំណង់

**មាត្រា ៣៨ :** លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំង ស្ថាបត្យកម្ម (Architecture) ទំហំ ឬ ទិដ្ឋភាពក្រៅអាចនាំអោយប៉ះពាល់ដល់លក្ខណៈ ឬ ផលប្រយោជន៍របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬទីក្រុង ភាពស្ងប់របស់ទីសក្ការបូជា រមណីយដ្ឋានប្រវត្តិសាស្ត្រ ឬ បុរាណសាស្ត្រ រាជវាំង និង រាជប្រាង្គប្រាសាទ ។

**មាត្រា ៣៩ :** លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើង បើលក្ខណៈសំណង់នោះមិនធានាសុខមាលភាព បន្ទប់ស្នាក់នៅ ឬ បន្ទប់ធ្វើការនីមួយ ៗ ត្រូវអោយមានខ្យល់ចេញ-ចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច ។

ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសំរាប់បន្ទប់នីមួយ ៗ ត្រូវមានយ៉ាងតិច ១,៥០ម$^{២}$ ។

**មាត្រា ៤០ :** បណ្តាសំណង់ឧស្សាហកម្ម អាចតម្រូវអោយគោរពល័ក្ខខ័ណ្ឌពិសេសចំពោះការរៀបចំ ឬការបោះទីតាំង ដើម្បីធានាការបញ្ចូលឱ្យបានល្អទៅក្នុងទេសភាព និង រមណីយដ្ឋានធម្មជាតិ ឬ ទីក្រុង ។

**មាត្រា ៤១ :** នៅតាមឆ្នេរសមុទ្រ តាមមាត់បឹង ស្ទឹង និងទន្លេ លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះធ្វើអោយខូចនូវសោភ័ណភាពរបស់ទេសភាព និង រមណីយដ្ឋាន ដោយសារទិដ្ឋភាព ឬ កំពស់របស់សំណង់ បើមើលពីមាត់ឆ្នេរ ពីមាត់ច្រាំង ពីសមុទ្រ ស្ទឹង ទន្លេ ឬបឹងបួរ និង ប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូក ៤

## សន្ទភាព ( ចង់ស៊ីតេ ) : កំរិតស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់

**មាត្រា ៤២ :** ការស្ថាបនាសំណង់មួយមានសន្ទភាព លើសពីកំរិតអតិបរមាស្របច្បាប់ តម្រូវអោយអ្នកទទួលលិខិតអនុញ្ញាតសាងសង់ បង់ប្រាក់ស្មើនឹងតំលៃដីដែលចាំបាច់ ដើម្បីអោយ << សន្ទស្សន៍ប្រើប្រាស់ >> សំណង់មិនលើស ពីកំរិតនេះ ។

**មាត្រា ៤៣ :** << សន្ទស្សន៍ប្រើប្រាស់ >> ត្រូវបានកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសរុបជាផ្លូវការ ( Hors oeuvre nette ) នៃសំណង់នោះ និងផ្ទៃក្រឡាដីដែលសំណង់នោះនឹងត្រូវ ឬបានតាំងនៅលើ ។

កាលណាសំណង់ថ្មីមួយ បានត្រូវសាងសង់លើដីមួយកន្លែងដែលមានអគារចាស់មួយ ឬច្រើន ហើយគ្មានគម្រោងរុះរើពេលនោះទេ សន្ទភាពត្រូវគណនាដោយថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ ទៅលើផ្ទៃក្រឡាកំរាលនៃសំណង់ថ្មី ។

<u>មាត្រា ៤៤</u> : កិរិតអតិបរមាស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់ ត្រូវកំណត់ដល់ (១) សំរាប់ទូទាំងដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា ។

<u>មាត្រា ៤៥</u> : ការផ្តល់លិខិតអនុញ្ញាតសាងសង់ នាំមកអោយអ្នកបានទទួលលិខិតអនុញ្ញាតសាងសង់ នូវកាតព្វកិច្ចអោយបង់ប្រាក់នោះ ។ ការបង់ប្រាក់ត្រូវធ្វើជាបីភាគស្មើៗ ភាគទី ១ នៅពេលបានទទួលលិខិតអនុញ្ញាតសាងសង់ ភាគទី ២ នៅពេលបើកការដ្ឋាន ភាគទី ៣ នៅពេលបញ្ចប់សំណង់ ។

<u>មាត្រា ៤៦</u> : តំលៃដីសំរាប់ការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់ដោយក្រសួងហិរញ្ញវត្ថុ ។

<u>មាត្រា ៤៧</u> : កិរិតស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និង ចំពោះអគាររដ្ឋបាលសាធារណៈសំរាប់បំរើផ្ទាល់មុខ ជាកន្លែងធ្វើការសំរាប់ស្ថាប័នសាធារណៈ ។

នាយករដ្ឋមន្ត្រី អាចសំរេចលើកលែងការអនុវត្តកិរិតស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ចំពោះបណ្តាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិ រៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ។

<< វាសនដ្ឋានសង្គម >> ទាំងឡាយអាចទទួលនូវការលើកលែងមិនអោយបង់ពន្ធអាករ តាមសេចក្តីសំរេចរបស់អភិបាលខេត្ត-ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ។

## ជំពូក ៥

## បទបញ្ញាពិសេស សំរាប់អនុវត្តលើភាគខ្លះ នៃដែនដី

<u>មាត្រា ៤៨</u> : ជាការបន្ថែមដល់បទបញ្ញាទូទៅនៃការប្រើប្រាស់ដី-ធ្លី ការណែនាំមួយចំនួនសំរាប់ការរៀបចំតំបន់ និងបទបញ្ញានគរោបនីយកម្មពិសេសមួយចំនួន អាចត្រូវដាក់តែងឡើងដោយអនុក្រឹត្យដែលអាច មានរហូតដល់ការហាមមិនអោយសាងសង់នៅក្នុង << តំបន់ចាប់អារម្មណ៍ >> ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និងបឹងធំ ៗ ។ រាល់ឯកសារ << នគរោបនីយកម្មមូលដ្ឋាន >> និង ប្លង់ខេត្តនៃ តំបន់ហាមមិនអោយមានសំណង់ ដែលចែងក្នុងមាត្រា ៣២ វគ្គទី ២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំ ទាំងនេះ និង ការហាមជាយថាហេតុមិនអោយសាងសង់ ។

<u>មាត្រា ៤៩</u> : បទបញ្ញត្តិទាំងឡាយមានពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

ប្រការ ៥០ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១

អ៊ឹង ហួត

នាយករដ្ឋមន្ត្រីទី ២

ហ៊ុន សែន

កន្លែងទទួល :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៥០
- ឯកសារ-កាលប្បវត្តិ

ជំរាបជូន :

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១

សម្តេចនាយករដ្ឋមន្ត្រីទី ២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ

រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់

វណ្ណ ម៉ូលីវណ្ណ

- - - - - - - - - - - - - - - - - - - - - - - - - - - - - - -

លេខ 059 សក.ចល

ថតចម្លងតាមច្បាប់ដើម

- ជូន ឯកឧត្តម រដ្ឋមន្ត្រី ស្តីទី
- - ឯកឧត្តម រដ្ឋលេខាធិការ
- - លេខាធិការ ដ៏.ន្ន ឧបនាយករដ្ឋមន្ត្រី
- - ... នគរូបនីយកម្ម និង សំណង់

"ដើម្បីជូនជ្រាបជាព័ត៌មាន"

ភ្នំពេញ ថ្ងៃទី 18 ខែ មករា ឆ្នាំ 1998

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រធានខុទ្ទកាល័យ

យី សុខផន

# ឧបសម្ព័ន្ធទី ៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

## <u>ពាក្យសុំលិខិតអនុញ្ញាតសាងសង់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............
មុខរបរ..............................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ.........ផ្លូវលេខ........ក្រុមទី..........សង្កាត់..............................
ខណ្ឌ......................................រាជធានីភ្នំពេញ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............
មុខរបរ..............................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ.........ផ្លូវលេខ........ក្រុមទិ..........សង្កាត់..............................
ខណ្ឌ......................................រាជធានីភ្នំពេញ។

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ** : - ចៅសង្កាត់..................................................................................
- អភិបាលខណ្ឌ..................................................................................
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំ..................................................... លើដីឡូត៍លេខ.......................ផ្លូវលេខ...............
ភូមិ....................សង្កាត់.....................................ខណ្ឌ.......................................រាជធានីភ្នំពេញ។
សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា:
......................................................................................................................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមឯកឧត្តម មេត្តាអនុញ្ញាតច្បាប់អោយដល់ខ្ញុំបាទ-នាងខ្ញុំ
កាន់កាប់ ....................................................................................................ដោយអនុគ្រោះ ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ-នាងខ្ញុំ។

<u>សូមជូនភ្ជាប់មកជាមួយនូវ :</u>

- ច្បាប់ថតចំលងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន.................ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន.................ច្បាប់
- សលាកប័ត្រដីឡូត៍ ចំនួន.................ច្បាប់
- កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចំនួន.................ច្បាប់
- កិច្ចសន្យាសាងសង់ ចំនួន.................ច្បាប់
- ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណ ចំនួន.................ច្បាប់

ភ្នំពេញ,ថ្ងៃទី..........ខែ..............ឆ្នាំ២០.....
**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

លេខ:.....................
បានឃើញ និង បញ្ជូនមក
លោកអភិបាលខណ្ឌ..............................
"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"
ភ្នំពេញ, ថ្ងៃទី..........ខែ..............ឆ្នាំ២០.......
**ចៅសង្កាត់**.........................

លេខ:.....................
បានឃើញ និង បញ្ជូនមក
លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។
"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"
ភ្នំពេញ, ថ្ងៃទី..........ខែ..............ឆ្នាំ២០.......
**អភិបាលខណ្ឌ**..........................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

## <u>កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន</u>

ខ្ញុំបាទ នាងខ្ញុំឈ្មោះ.................................................ភេទ..........អាយុ.........ឆ្នាំ ស្នាក់នៅផ្ទះលេខ.................
ផ្លូវលេខ...............ភូមិ..................សង្កាត់...............................ខណ្ឌ...................................រាជធានីភ្នំពេញ។
ខ្ញុំបាទ នាងខ្ញុំឈ្មោះ.................................................ភេទ..........អាយុ.........ឆ្នាំ ស្នាក់នៅផ្ទះលេខ.................
ផ្លូវលេខ...............ភូមិ..................សង្កាត់...............................ខណ្ឌ...................................រាជធានីភ្នំពេញ។
ខ្ញុំបាទ នាងខ្ញុំឈ្មោះ.................................................ភេទ..........អាយុ.........ឆ្នាំ ស្នាក់នៅផ្ទះលេខ.................
ផ្លូវលេខ...............ភូមិ..................សង្កាត់...............................ខណ្ឌ...................................រាជធានីភ្នំពេញ។

សូមធ្វើកិច្ចសន្យាជូនរដ្ឋអំណាច អំពីការដាក់សំភារៈសាងសង់ដែលមានទីតាំងលើដីឡូត៍លេខ...........................
ផ្លូវលេខ...............ភូមិ..................សង្កាត់...............................ខណ្ឌ...................................រាជធានីភ្នំពេញ។

១-ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់ ដាក់សំភារៈ និងធ្វើរបាំងឲ្យបានម៉ត់ចត់ពីក្រោមដល់លើ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ។
២-រក្សាទុកចិញ្ចើមថ្នល់ឲ្យបានទូលាយ ស្មើនិងពីភាគបី សំរាប់ឲ្យថ្មើរជើងធ្វើដំណើរទៅមកដោយសេរី។
៣-មិនយកទ្រូងថ្នល់ធ្វើជាកន្លែងលាយស៊ីម៉ងត៍ ចាក់សំរាម កំទេចកំទីសំភារៈសំណង់ និងចាក់ថ្ម គ្រួស ខ្សាច់ ធ្វើឲ្យប៉ះពាល់ដល់អនាម័យសណ្តាប់ធ្នាប់ ដាច់ខាត។
៤-មិនបង្កទំនាស់ មិនរំខានអ្នកជិតខាងជាប់ដីឡូត៍គ្នា។
ក្រែងពុំប្រាកដ យើងខ្ញុំ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាងស្រាប់។

ភ្នំពេញ,ថ្ងៃទី.........ខែ............ឆ្នាំ២០....
**ស្នាមមេដៃស្តាំ**

លេខៈ.......................
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងលើនេះ ពិតជាស្នាមមេដៃស្តាំរបស់ឈ្មោះ
........................................................ពិតប្រាកដមែន។
ភ្នំពេញ,ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**ចៅសង្កាត់**.........................

លេខៈ.........................
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងស្តាំនេះ ពិតជាស្នាមមេដៃស្តាំរបស់លោក
...........................ចៅសង្កាត់.......................ពិតប្រាកដមែន។
ភ្នំពេញ,ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**អភិបាលខណ្ឌ**.........................

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាសាងសង់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.........................................................................ភេទ..........អាយុ.........ឆ្នាំ សញ្ជាតិ................
ដែលមានទីលំនៅបច្ចុប្បន្នផ្ទះលេខ..................ផ្លូវលេខ..............ក្រុមទី............ភូមិ.......... សង្កាត់........................
ខណ្ឌ......................................រាជធានីភ្នំពេញ។

ប្ដី-ប្រពន្ធ ឈ្មោះ...........................................................................ភេទ..........អាយុ.........ឆ្នាំ សញ្ជាតិ................
ដែលមានទីលំនៅបច្ចុប្បន្នផ្ទះលេខ..................ផ្លូវលេខ..............ក្រុមទី............ភូមិ.......... សង្កាត់........................
ខណ្ឌ......................................រាជធានីភ្នំពេញ។

### <u>សូមធ្វើកិច្ចសន្យា ដូចតទៅ</u>

១-គោរពតាមខ្លឹមសារអនុក្រឹត្យ លេខ ៨៦ អនក្រ បានកំណត់។
២-ធានាសុវត្ថិភាពរបស់អ្នកជិតខាង ដែលមានទីតាំងសាងសង់ សំណង់មុន។
៣-ធានាមិនឱ្យកាកសំណល់ ទឹកកង្វក់ចូលទៅប៉ះពាល់ទីកន្លែងបរិស្ថានរបស់ប្រជាជនជុំវិញ ឬទីសាធារណៈ ឡើយ។
៤-ធានាការពារមិនឱ្យមានអគ្គីភ័យកើតមានឡើង ក្នុងករណីកើតមានជាយថាហេតុណាមួយនេះ ខ្ញុំបាទ-នាងខ្ញុំ យល់ព្រមចេញសងនូវការខូចខាតទាំងឡាយរបស់អ្នកដទៃនៅជិតខាងនោះ។
៥-ក្នុងករណីទៅថ្ងៃក្រោយ បើមានការប៉ះពាល់សោភ័ណ្ឌភាព សណ្ដាប់ធ្នាប់សាធារណៈបរិស្ថាន ឬការពង្រីកផ្លូវ នៅពេលអនាគត ខ្ញុំបាទ-នាងខ្ញុំ សុខចិត្តគោរពតាមគោលការណ៍កំណត់ របស់សមត្ថកិច្ចរដ្ឋ។

ខ្ញុំបាទ-នាងខ្ញុំសូមសន្យាថា នឹងគោរពតាមកិច្ចសន្យានេះទាំងស្រុង ហើយសូមទទួលខុសត្រូវចំពោះមុខច្បាប់ របស់រដ្ឋជាធរមាន ក្នុងករណីប្រព្រឹត្តខុសពីកិច្ចសន្យាខាងលើ។

ភ្នំពេញ,ថ្ងៃទី.........ខែ............ឆ្នាំ២០.....
**ស្នាមមេដៃស្ដាំ**

លេខៈ.......................
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងស្ដាំនេះ ពិតជាស្នាមមេដៃស្ដាំរបស់លោក
.........................ចៅសង្កាត់......................ពិតប្រាកដមែន។
ភ្នំពេញ,ថ្ងៃទី.........ខែ..............ឆ្នាំ២០......
**អភិបាលខណ្ឌ**.................................

លេខៈ.......................
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងលើនេះ ពិតជាស្នាមមេដៃស្ដាំរបស់ឈ្មោះ
....................................................ពិតប្រាកដមែន។
ភ្នំពេញ,ថ្ងៃទី.........ខែ..............ឆ្នាំ២០......
**ចៅសង្កាត់**..........................

*ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ.១៧៧.នណស/ប្រក.ចុះថ្ងៃទី....០៦......ខែ..ឧសភា.........ឆ្នាំ២០១៩.....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***

*សម្រាប់សមត្ថកិច្ចរបស់ក្រសួង*

**<u>ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់</u>**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ........................ភេទ...... សញ្ជាតិ..........ថ្ងៃខែឆ្នាំកំណើត............... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ....................... និងប្រពន្ធ/ ប្តីឈ្មោះ.................. សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ផ្លូវ........ភូមិ..........ឃុំ/ សង្កាត់................ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន.............................. ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ...............ឃុំ/ សង្កាត់..................... ក្រុង/ ស្រុក/ ខណ្ឌ.................រាជធានី/ ខេត្ត.....................។

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ**÷ -ប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ......ឆ្នាំ........ ជាប្រភេទសំណង់.........................សាងសង់អំពី................ កំពស់............ ម៉ែត្រ ស្មើនឹង...........ជាន់ ផ្ទៃក្រឡាសំណង់សរុប.....................ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ............... ផ្លូវលេខ............. ភូមិ................ ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត..................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់ខ្ញុំបាទ/ នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

<u>សូមគោរពជូនភ្ជាប់ជាមួយនូវ÷</u>

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន ០៣ ច្បាប់

៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ០៣ ច្បាប់

៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង ចំនួន ០៣ ច្បាប់

៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) ចំនួន ០៣ ច្បាប់

៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់

៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់

១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) ចំនួន ០៣ ច្បាប់

១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់

១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) ចំនួន ០៣ ច្បាប់

ថ្ងៃ.................... ខែ.......... ឆ្នាំ.................... ព.ស. .........

ធ្វើនៅ............. ថ្ងៃទី...... ខែ......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

**បញ្ជាក់៖** រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

*ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ.១៧៧ ដនសណ/ប្រក ចុះថ្ងៃទី...០៦......ខែ...ធ្នូ.........ឆ្នាំ២០.១៩....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***

*សម្រាប់សមត្ថកិច្ចរបស់រដ្ឋបាលរាជធានី/ខេត្ត*

# **ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ......................... ភេទ...... សញ្ជាតិ.......... ថ្ងៃខែឆ្នាំកំណើត............... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ....................... និងប្រពន្ធ/ ប្តីឈ្មោះ.................. សញ្ជាតិ........ ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ....... ផ្លូវ........ ភូមិ........... ឃុំ/ សង្កាត់................ ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន.............................. ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ............... ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ.................. រាជធានី/ ខេត្ត......................។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី/ខេត្ត..............**

**តាមរយៈ**÷ -ប្រធានអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី/ ខេត្ត...............

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី/ ខេត្ត...............

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី.... ខែ...... ឆ្នាំ........ ជាប្រភេទសំណង់......................... សាងសង់អំពី................ កំពស់............ ម៉ែត្រ ស្មើនឹង........... ជាន់ ផ្ទៃក្រឡាសំណង់សរុប........................ ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ............. ផ្លូវលេខ............. ភូមិ................ ឃុំ/ សង្កាត់....................... ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត...................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាពិនិត្យនិងសម្រេច ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

**<u>សូមគោរពជូនភ្ជាប់ជាមួយនូវ÷</u>**

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

| | |
|---|---|
| ៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) | ចំនួន ០៣ ច្បាប់ |
| ៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ | ចំនួន ០៣ ច្បាប់ |
| ៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ចំនួន ០៣ ច្បាប់ |
| ៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង | ចំនួន ០៣ ច្បាប់ |
| ៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) | ចំនួន ០៣ ច្បាប់ |
| ១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) | ចំនួន ០៣ ច្បាប់ |

ថ្ងៃ.................... ខែ.......... ឆ្នាំ.................... ព.ស. .........

ធ្វើនៅ............. ថ្ងៃទី...... ខែ......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

<u>បញ្ជាក់៖</u> រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម
នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***
*សម្រាប់សមត្ថកិច្ចរបស់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ*

## <u>ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់</u>

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ........................ភេទ...... សញ្ជាតិ.........ថ្ងៃខែឆ្នាំកំណើត............... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ...................... និងប្រពន្ធ/ ប្តីឈ្មោះ................. សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ផ្លូវ........ភូមិ...........ឃុំ/ សង្កាត់................ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន............................ ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ................. ភូមិ...............ឃុំ/ សង្កាត់..................... ក្រុង/ ស្រុក/ ខណ្ឌ.................រាជធានី/ ខេត្ត.....................។

**សូមគោរពជូន**

**លោក/លោកស្រីអភិបាល នៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ...........**

**តាមរយៈ÷** -ប្រធានការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង/ ស្រុក/ ខណ្ឌ...........
-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង/ស្រុក/ ខណ្ឌ..........

**កម្មវត្ថុ ÷** សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **លោក/លោកស្រីអភិបាល** មេត្តាផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ......ឆ្នាំ........ ជាប្រភេទសំណង់........................សាងសង់អំពី................ កំពស់............ ម៉ែត្រ ស្មើនឹង...........ជាន់ ផ្ទៃក្រឡាសំណង់សរុប......................ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ.............. ផ្លូវលេខ............. ភូមិ................ ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត..................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោក/លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេច ដោយក្តីអនុគ្រោះ។

សូម **លោក/លោកស្រីអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

<u>សូមគោរពជូនភ្ជាប់ជាមួយនូវ÷</u>

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

| | | |
|---|---|---|
| ៣. | លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) | ចំនួន ០៣ ច្បាប់ |
| ៤. | ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ | ចំនួន ០៣ ច្បាប់ |
| ៥. | សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ចំនួន ០៣ ច្បាប់ |
| ៦. | សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង | ចំនួន ០៣ ច្បាប់ |
| ៧. | របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៨. | ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៩. | ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១០. | ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១១. | ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) | ចំនួន ០៣ ច្បាប់ |
| ១២. | ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) | ចំនួន ០៣ ច្បាប់ |

ថ្ងៃ.................... ខែ.......... ឆ្នាំ.................... ព.ស. .........

ធ្វើនៅ............. ថ្ងៃទី...... ខែ.......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

<u>**បញ្ជាក់៖**</u> រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

# ឧបសម្ព័ន្ធទី ៤

KINGDOM OF CAMBODIA
NATION RELIGION KING

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF LABOUR
AND VOCATIONAL TRAINING
BOARD OF ENGINEERS, CAMBODIA

ក្រសួងការងារ
និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈវិស្វករកម្ពុជា

# វិញ្ញាបនបត្រវិស្វករចុះបញ្ជី

# CERTIFICATE OF REGISTERED ENGINEER

## អគ្គលេខាធិការគណៈវិស្វករកម្ពុជា

## THE SECRETARY GENERAL OF THE BOARD OF ENGINEERS, CAMBODIA

បានឃើញកំណត់ហេតុចុះថ្ងៃទី ១៨ សីហា ២០១៧
Having approved minutes dated 18 August 2017
របស់គណៈកម្មាធិការចុះបញ្ជីវិស្វករនៃគណៈវិស្វករកម្ពុជា
of the Engineers Register Committee of **BEC**

សូមបញ្ជាក់ថាឈ្មោះ **ទូច នន**
Certified that TOUCH NORN
ថ្ងៃ ខែ ឆ្នាំកំណើត ០៩ វិច្ឆិកា ១៩៨៩
Date of Birth 09 November 1989

បានបំពេញគ្រប់លក្ខខណ្ឌរបស់គណៈវិស្វករកម្ពុជា សម្រាប់ទទួលវិញ្ញាបនបត្រជា **វិស្វករចុះបញ្ជី**
Having fulfill all the requirements of the Board of Engineers, Cambodia for the award of the title of **REGISTERED ENGINEER**

ជំនាញ **អគ្គិសនី**
in the field of Electrical

វិញ្ញាបនបត្រនេះ ផ្តល់ជូនសាមីជនដើម្បីប្រើប្រាស់តាមច្បាប់ដែលអាចប្រើបាន។
This certificate given to the bearer with all rights and privileges thereto pertaining.

**ID:** 001562 **RE/**



រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧
Phnom Penh 21 August 2017

**អគ្គលេខាធិការគណៈវិស្វករកម្ពុជា**
**SECRETARY GENERAL OF BEC**

**លឹម សុថាវ**

ឧបសម្ព័ន្ធ ២ នៃប្រកាសលេខ ០៧៧ ដនសស/ប្រក ចុះថ្ងៃទី ០៦ ខែ ក ឆ្នាំ ២០១៥
ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចស្របតាមលិខិតអនុញ្ញាតសាងសង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION
លេខ/N°: ..................................

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# វិញ្ញាបនបត្រប្រើប្រាស់សំណង់
## CERTIFICATE OF OCCUPANCY

- សំណង់អំពី.................................កម្ពស់.....................ម៉ែត្រ ស្មើនឹង.....................ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប..........................................ម²
  CONSTRUCTION BUILT OF..........; HEIGHT.................M, ...................STORIES, TOTAL AREA ..........................................M²
- ទីតាំងសំណង់÷ ក្បាលដីលេខ.................. ផ្លូវ............ ភូមិ..................... ឃុំ/សង្កាត់................ ក្រុង/ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត.................
  LOCATION: LAND TITLE N°:........, ST.:........VILLAGE:........, COMMUNE/SANGKAT:..............., KRONG/SROK/KHAN:.............., CAPITAL/PROVINCE:..............
- ម្ចាស់សំណង់÷.......................................................................... -មុខងារប្រើប្រាស់សំណង់ ..........................................................
  OWNER: ........................................................................ USE OF THE CONSTRUCTION: ..............................................
- ថ្ងៃចាប់ផ្តើមសាងសង់....................ថ្ងៃបញ្ចប់ការសាងសង់.........................-សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ................. ចុះថ្ងៃទី..... ខែ........ឆ្នាំ..........
  CONSTRUCTION DATE: STARTED:......................; COMPLETED:..................AS BUILT DRAWING N°....................DATED:...................................
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី............ខែ................ ឆ្នាំ.......... អនុវត្តដោយ .................................................
  CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:......................... DONE BY:...................................................

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ................................ ខែ.............ឆ្នាំ................ ព.ស. ..........

រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ............ ឆ្នាំ .............
PHNOM PENH, DATE ...............................................

ជ.រដ្ឋមន្ត្រី
FOR THE MINISTER

២ ក្បូ ៤-២

ឧបសម្ព័ន្ធទី ៣ នៃប្រកាសលេខ០៧៧ ស.ស.ស.រ.ក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១៥

និមិត្តសញ្ញា រាជធានី-ខេត្ត

រដ្ឋបាលរាជធានី/ខេត្ត.................................
........................ CAPITAL/PROVINCIAL ADMINISTRATION
លេខ/N°: ....................................

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# វិញ្ញាបនបត្រប្រើប្រាស់សំណង់
# CERTIFICATE OF OCCUPANCY

- សំណង់អំពី...................................កម្ពស់......................ម៉ែត្រ ស្មើនឹង......................ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប........................................ម²
CONSTRUCTION BUILT OF..........; HEIGHT..................M, ....................STORIES, TOTAL AREA ............................................ M²
- ទីតាំងសំណង់÷ ក្បាលដីលេខ.................. ផ្លូវ............ ភូមិ.................... ឃុំ/សង្កាត់................. ក្រុង/ស្រុក/ខណ្ឌ................. រាជធានី/ខេត្ត..................
LOCATION: LAND TITLE N°:........, ST.:.........VILLAGE:........., COMMUNE/SANGKAT:.........., KRONG/SROK/KHAN:.............., CAPITAL/PROVINCE:...............
- ម្ចាស់សំណង់÷..........................................................................-មុខងារប្រើប្រាស់សំណង់ .........................................................................
OWNER: .......................................................................... USE OF THE CONSTRUCTION: ..................................................
- ថ្ងៃចាប់ផ្តើមសាងសង់.....................ថ្ងៃបញ្ចប់ការសាងសង់.........................-សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ.................ចុះថ្ងៃទី.....ខែ........ឆ្នាំ...........
CONSTRUCTION DATE: STARTED:....................; COMPLETED:....................AS BUILT DRAWING N°.....................DATED:..................................
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី............ខែ................ ឆ្នាំ.......... អនុវត្តដោយ ............................................................
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:.......................... DONE BY:...............................................................

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ.................................... ខែ............... ឆ្នាំ................. ព.ស. ..........

រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ ............. ឆ្នាំ ..............
PHNOM PENH, DATE ................................................

ជ.អភិបាល
FOR THE GOVERNOR

ឧបសម្ព័ន្ធទី ៤ នៃប្រកាសលេខ ១៣៧ .ដនសស/ប្រក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១៩
ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

និមិត្តសញ្ញា ក្រុងស្រុក ខណ្ឌ

រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ..................................
................................ KRONG/SROK/KHAN ADMINISTRATION
លេខ/N°: ......................................

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# វិញ្ញាបនបត្រប្រើប្រាស់សំណង់
# CERTIFICATE OF OCCUPANCY

- សំណង់អំពី.................................. កម្ពស់...................... ម៉ែត្រ ស្មើនឹង...................... ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប.................................................... ម២
CONSTRUCTION BUILT OF...........; HEIGHT.................M, ...................STORIES, TOTAL AREA ................................................ M²
- ទីតាំងសំណង់÷ ក្បាលដីលេខ.................. ផ្លូវ............ ភូមិ..................... ឃុំ/សង្កាត់................. ក្រុង/ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត.................
LOCATION: LAND TITLE N°:........, ST.:........VILLAGE:........., COMMUNE/SANGKAT:..........., KRONG/SROK/KHAN:.............., CAPITAL/PROVINCE:................
- ម្ចាស់សំណង់÷........................................................................ - មុខងារប្រើប្រាស់សំណង់ .....................................................
OWNER: ........................................................................ USE OF THE CONSTRUCTION: ............................................
- ថ្ងៃចាប់ផ្តើមសាងសង់..................... ថ្ងៃបញ្ចប់ការសាងសង់......................... - សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ................. ចុះថ្ងៃទី..... ខែ........ ឆ្នាំ..........
CONSTRUCTION DATE: STARTED:...........................; COMPLETED:.......................AS BUILT DRAWING N°......................DATED:...........................
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី............ ខែ................ ឆ្នាំ.......... អនុវត្តដោយ ..................................................
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:......................... DONE BY:................................................

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ.................................. ខែ............... ឆ្នាំ................. ព.ស. ..........

រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ ............. ឆ្នាំ ..............
PHNOM PENH, DATE ..................................................

ជ.អភិបាល
FOR THE GOVERNOR